**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្ដាល

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ កញ្ញា **ចាន់ សុវណ្ណនីស្សា** | បណ្ឌិត **ឌី ពុទ្ធារ៉ា** |
| កញ្ញា **ម៉ាន់ យ៉ានុត** | |


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | ឆ្នាំចូលរៀន ២០២០ |
| ជំនាន់ទី១៧ | ឆ្នាំសរសេរសារណា ២០២៤ |

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# ការរៀបចំសណ្តាប់ធ្នាប់
# និងសោភ័ណភាពខេត្តកណ្តាល

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


| | |
|---|---|
| ស្រាវជ្រាវដោយ | ណែនាំដោយ |
| និស្សិតឈ្មោះ កញ្ញា **ចាន់ សុវណ្ណនីស្សា** | បណ្ឌិត **ឌី ពុទ្ធារ៉ា** |
| កញ្ញា **ម៉ាន់ យ៉ានុត** | |


| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** | ឆ្នាំចូលរៀន ២០២០ |
| ជំនាន់ទី១៧ | ឆ្នាំសរសេរសារណា ២០២៤ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ចាន់ សុវណ្ណនីស្សា** និងនាងខ្ញុំឈ្មោះ **ម៉ាន់ យ៉ានុត** ជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មុខជំនាញ រដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១៧។

នាងខ្ញុំទាំងពីរនាក់ សូមធ្វើការគោរពថ្លែងអំណរអរគុណ និងសម្តែងនូវការដឹងគុណ និងកត្តញ្ញូតាធម៌ចំពោះ**លោកឪពុកអ្នកម្តាយ**នៃនាងខ្ញុំទាំងពីរនាក់ ដែលលោកមានគុណក្រៃលែងចំពោះកូនៗ ដែលមានតម្លៃពុំអាចកាត់ថ្លៃបាន ព្រោះលោកទាំងទ្វេបានផ្តល់កំណើត ចិញ្ចឹមមើលថែដោយក្តីស្រឡាញ់ ពិសេសគឺបានប្រមើលមើលនូវអនាគតកូនៗ ដោយឱ្យកូនៗបានសិក្សារៀនសូត្រតាំងពីថ្នាក់មតេយ្យរហូតដល់ថ្នាក់ឧត្តមសិក្សាព្រមទាំងផ្គត់ផ្គង់ការសិក្សាដោយពុំមានចន្លោះត្រង់ណាឡើយ។ លើសពីនេះ កូនៗបានមកដល់ចំណុចនេះបានក៏ដោយសាតែពាក្យអប់រំល្អៗ ណែនាំល្អ និងព្យាយាមធ្វើជាស្ពានចម្លងកូនៗឱ្យទទួលបានជោគជ័យក្នុងការសិក្សា។

នាងខ្ញុំទាំងពីរនាក់ក៏សូមថ្លែងអំណរអរគុណចំពោះ **ឯកឧត្តម បណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រង ព្រមទាំងលោកគ្រូ អ្នកគ្រូ** ដែលជាសាស្ត្រាចារ្យ ដោយលោកបានយកចិត្តទុកដាក់បណ្តុះបណ្តាលនូវចំណេះដឹង ព្រមទាំងណែនាំ តម្រង់ទិសដៅជីវិតដល់និស្សិតទាំងឡាយទទួលបាននូវមេរៀនជីវិត ទទួលបានឱកាសការងារល្អៗ។

ក្នុងឱកាសនេះ នាងខ្ញុំក៏សូមថ្លែងអំណរគុណដល់សាស្ត្រាចារ្យ **បណ្ឌិត ឌី ពុទ្ធារ៉ា** ដែលលោកគ្រូបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំការសរសេរសារណារបស់នាងខ្ញុំទាំងពីរនាក់ ដោយយកចិត្តទុកដាក់ ក្នុងការណែនាំ កែប្រែចំណុចខ្វះខាត និងឆ្លាំឆ្លងលើប្រធានបទរបស់នាងខ្ញុំទាំងពីរ។

បន្ថែមពីនេះ នាងខ្ញុំទាំងពីរក៏សូមថ្លែងអំណរគុណដល់លោកអភិបាលខេត្ត អភិបាលខេត្តរង និងមន្ត្រីគ្រប់ជាន់ថ្នាក់ ដែលលោកបានជួយក្នុងការផ្តល់ឱកាសឱ្យនាងនាងខ្ញុំទាំងពីនាក់បានចុះស្រាវជ្រាវឯកសារដែលពាក់ព័ន្ធនឹងប្រធានបទ **ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល** នៅឯរដ្ឋបាលខេត្តកណ្តាលដោយផ្ទាល់ ដោយការស្វាគមន៍យ៉ាងកក់ក្តៅ និងយកចិត្តទុកដាក់មកលើរូបនាងខ្ញុំទាំងពីរ។

ជាចុងក្រោយ នាងខ្ញុំទាំងពីរនាក់ សូមគោរពជូនពរដល់អ្នកមានគុណអ្នកឡាយឱ្យមានសុខភាពល្អជាម្លប់ដល់កូនចៅ ជាម្លប់នៃនិស្សិតទាំងអស់ ព្រមទាំងជួបនូវពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**អារម្ភកថា**

សូមស្វាគមន៍មិត្តនិស្សិតទាំងឡាយ ដែលចូលមកកាន់សៀវភៅថ្មី ទំព័រថ្មីនៃឆ្នាំទី៤ របស់នាងខ្ញុំ។ នាងខ្ញុំជានិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្នាក់ P4A1 ជំនាន់ទី១៧ ជំនាញរដ្ឋបាលសាធារណៈ។ នាងខ្ញុំទាំងពីរមានសេចក្តីរីករាយសោមនស្ស ដែលបានមានឱកាសបានសរសេរសារណាបញ្ចប់ឆ្នាំលើប្រធានបទ **ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល** ដែលបានធ្វើឱ្យនាងខ្ញុំបានសិក្សាបន្ថែមពីមេរៀនដែលបានសិក្សាគន្លងមក និងបានចែករំលែកនូវចំណេះដឹងដែលនាងខ្ញុំបានស្រាវជ្រាវបានមកជាឯកសារមួយជំនួយបន្ថែមពីលើកម្មវិធីសិក្សាក្នុងថ្នាក់រៀន ។

សៀវភៅមួយក្បាលនេះ នាងខ្ញុំទាំងពីរបានរៀបរាប់ពីការរៀបចំនូវសណ្តាប់ធ្នាប់ ព្រមទាំងការរៀបចំសោភ័ណភាពក្នុងដែនដីនៃខេត្តកណ្តាល ដោយបានបង្ហាញតាំងពីសាវតានៃខេត្តកណ្តាល ព្រមទាំងមូលហេតុជាច្រើនដែលចាំបាច់ត្រូវមានការរៀបចំ។ មូលហេតុដែលនាងខ្ញុំជ្រើសរើសប្រធានបទមួយនេះ ពីព្រោះដើម្បីបង្ហាញដល់អ្នកសិក្សាទាំងឡាយឱ្យឃើញពីគុណតម្លៃនៃការចូលរួមថែរក្សាសម្បត្តិនៃខេត្តរបស់យើង ព្រមទាំងតម្លៃនៃសាមគ្គីភាព ការចូលរួមគោរព និងអនុវត្តនូវរាល់ច្បាប់ វិធានការ គោលការណ៍ដែលអាជ្ញាធរបានរៀបចំពិសេសនោះគឺខំប្រឹងប្រែងរបស់អាជ្ញាធរដើម្បីទីក្រុងស្អាត និងចង់ឱ្យយុវជនទាំងឡាយសាមគ្គីជាធ្លុងមួយជួយថែរក្សានូវទ្រព្យរបស់ខេត្តមិនថាជារដ្ឋ ឬឯកជននោះទេ។

នាងខ្ញុំទាំងពីរសង្ឃឹមថា ឯកសារស្រាវជ្រាវមួយនេះនឹងមានសារៈសំខាន់ទៅដល់មិត្តនិស្សិតទាំងអស់ដែលបានអាននូវការសិក្សាស្រាវជ្រាវមួយនេះ។ ជាចុងក្រោយ នាងខ្ញុំទាំងពីរសូមអរគុណ ដល់មិត្តនិស្សិតទាំងឡាយដែលបានចំណាយពេលដ៏មានតម្លៃមកអានសៀវភៅដែលបានចងក្រង ហើយនាងខ្ញុំទាំងពីរក៏រីករាយនឹងទទួលយកនូវការរិះគន់ដើម្បីស្ថាបនានូវកំហុសដែលកើតមានឡើង។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃខេត្តកណ្តាល**

**១.១. បរិបទទូទៅនៃខេត្តកណ្តាល** ........ ៤

១.១.១. ប្រវត្តិនៃខេត្តកណ្តាល ........ ៤

១.១.២. ទីតាំងភូមិសាស្ត្រ ........ ៥

១.១.៣. ស្ថានភាពប្រជាជន ........ ៧

១.១.៤. វិស័យសំខាន់ៗក្នុងខេត្តកណ្តាល ........ ៧

១.១.៤.១. វិស័យទេសចរណ៍ ........ ៧

១.១.៤.២. វិស័យអប់រំ ........ ១១

១.១.៤.៣. វិស័យសុខាភិបាល ........ ១១

១.១.៤.៤. វិស័យធម្មការ និងសាសនា ........ ១៣

**១.២. រចនាសម្ព័ន្ធខេត្តកណ្តាល** ........ ១៣

១.២.១. ក្រុមប្រឹក្សាខេត្តកណ្តាល ........ ១៣

១.២.១.១. ការបង្កើតក្រុមប្រឹក្សាខេត្ត ........ ១៣

១.២.១.២. តួនាទី មុខងារ និងភារកិច្ចក្រុមប្រឹក្សាខេត្ត ........ ១៤

១.២.១.៣. កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្ត ........ ១៥

១.២.១.៤. ការបង្កើតគណៈកម្មាធិការ ........ ១៧

១.២.២. គណៈអភិបាល ........ ១៩

១.២.២.១. ការបង្កើតគណៈអភិបាលខេត្ត ........ ១៩

១.២.២.២. តួនាទី-ភារកិច្ចរបស់គណៈអភិបាលខេត្ត ........ ១៩

១.២.២.៣. នាយករដ្ឋបាលសាលាខេត្ត ........ ២២

១.២.២.៤. ទីចាត់ការចំណុះនានា ........ ២២

## ជំពូកទី២

## ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល

**២.១. បុព្វហេតុនៃការរៀបចំសណ្តាប់ធ្នាប់ខេត្តកណ្តាល** ........ ២៤

២.១.១. កំណើនប្រជាជន ........ ២៤

២.១.២. ភាពក្រីក្រ ........ ២៥

២.១.៣. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ........ ២៥

២.១.៤. ការបំពុលទាំង៥ ........ ២៧

២.១.៤.១. ការបំពុលដី ........ ២៧

២.១.៤.២. ការបំពុលទឹក ........ ២៩

២.១.៤.៣. ការបំពុលដោយសំណល់រឹង រាវ ........ ៣០

២.១.៤.៤. ការបំពុលសំឡេង ........ ៣២

២.១.៤.៥. ការបំពុលខ្យល់ ........ ៣៣

**២.២. ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល** ........ ៣៥

២.២.១. ការរៀបចំសណ្តាប់ធ្នាប់ ........ ៣៥

២.២.១.១. ការរៀបចំសន្តិសុខ ........ ៣៥

២.២.១.២. ភាពស្ងប់ស្ងៀម ........ ៤០

២.២.១.៣. គ្មានការបំពុល ........ ៤០

២.២.២. ការរៀបចំសោភ័ណភាពខេត្តកណ្តាល ........ ៤២

២.២.២.១. សោភ័ណភាពពេលថ្ងៃ ........ ៤២

២.២.២.២. សោភ័ណភាពពេលយប់ ........ ៤៧

២.២.៣. ផលវិបាក និងដំណោះស្រាយនៃការរៀបចំ ........ ៤៨

២.២.៣.១. ផលវិបាក ........ ៤៨

២.២.៣.២. ដំណោះស្រាយ ............................................................................................................ ៥០

## ជំពូកទី៣

## កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្តកណ្តាល

**៣.១. ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខេត្ត** ........................................................ ៥២
៣.១.១. ស្ថានភាពសេដ្ឋកិច្ច ............................................................................................ ៥២
៣.១.២. ស្ថានភាពសង្គមកិច្ច............................................................................................ ៥២
៣.១.៣. ការប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ បរិស្ថាន និងការប្រែលប្រួលអាកាសធាតុ ..................... ៥៣
៣.១.៤. រដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ........................................................ ៥៣
**៣.២. គោលចំណង និងទិសដៅសំខាន់ៗនៅឆ្នាំខាងមុខ**............................................... ៥៤
៣.២.១. ផ្នែកសេដ្ឋកិច្ច ................................................................................................. ៥៤
៣.២.២. ផ្នែកសង្គមកិច្ច................................................................................................. ៥៥
៣.២.៣. ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ............................................... ៥៧
៣.២.៤. រដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ........................................................ ៥៨
សេចក្តីសន្និដ្ឋាន ..................................................................................................... ៥៩
អនុសាសន៍ .............................................................................................................. ៦១
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលលាតសន្ធឹងនៅប៉ែកអាស៊ី ដោយបានឆ្លងកាត់នូវរបបគ្រប់គ្រងជាច្រើនសវត្ស។ ការចងចាំដ៏អាប់អួររបស់ប្រជាជនកម្ពុជានៅរបបប្រជាធិបតេយ្យ ឬជាទូទៅមនុស្សគ្រប់គ្នាស្គាល់ថាជារបបពលពត ដែលបានសម្លាប់នូវធនធានមនុស្សអស់ជាច្រើននាក់ និងបានបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធស្ទើរទូទាំងប្រទេស។ លុះក្រោយមក កម្ពុជាក៏បានរួចផុតពីសុបិន្តអាក្រក់ក្រោមការរំដោះដោយ សម្ដេច **តេជោ ហ៊ុនសែន** នៅឆ្នាំ១៩៧៩ និងបានខិតខំកសាងប្រទេសឡើងវិញដោយការសហការពីបណ្ដាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ ការរៀបចំប្រទេសធ្វើទៅតាមបណ្ដាខេត្តនានានៃប្រទេសកម្ពុជាដើម្បីស្ដានូវមុខមាត់ប្រទេស ហេដ្ឋារចនាសម្ព័ន្ធ សណ្ដាប់ធ្នាប់ ដើម្បីឱ្យកម្ពុជាឈានទៅរកសន្តិភាព សុវត្ថិភាព ព្រមទាំងសណ្ដាប់ធ្នាប់ល្អ អមដោយហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍ។

ប្រទេសកម្ពុជារបស់យើងសព្វថ្ងៃកំពុងតែធ្វើការរៀបចំ កែប្រែ កែលម្អរាជធានី ខេត្ត ទីក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ឱ្យស្របទៅតាមការកំណត់នៃប្លង់គោលដែលបានរៀបចំដោយគណៈកម្មការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ដែលបានរៀបចំ និងអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុងនានា។ ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាព គឺជាកត្តាដ៏សំខាន់មួយដើម្បីកែលម្អតំបន់នានានៃប្រទេសកម្ពុជាឱ្យល្អប្រសើរជាមុនស្របទៅតាមផែនការនៃប្លង់គោល ប្លង់ប្រើប្រាស់ដីធ្លី និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលឱ្យធ្វើយ៉ាងណាដើម្បីរាជធានី ខេត្ត ក្រុង មានរបៀបរៀបរយសណ្ដាប់ធ្នាប់សោភ័ណភាពទាក់ទាញ។ ហើយភាពស្រស់ស្អាតនៃរាជធានី ខេត្ត ក្រុង តំបន់នានានៃប្រទេសជាសេចក្ដីសុខផ្លូវចិត្តរបស់ប្រជាពលរដ្ឋ និងជាកត្តាទាក់ទាញនូវភ្ញៀវទេសចរឱ្យមកទស្សនានៅប្រទេសរបស់យើង។ សណ្ដាប់ធ្នាប់ សំដៅដល់ធាតុបីសំខាន់ គឺសន្តិសុខ ភាពស្ងៀមស្ងាត់ និងសុវត្ថិភាពចំណីអាហារ។ ចំពោះសោភ័ណភាព គឺសំដៅដល់ភាពល្អស្អាតហ្មត់ហ្មង ភាពស្រស់ស្អាត។ ក្នុងនោះផងដែរ តាមបណ្ដាខេត្តនានានៃព្រះរាជាណាចក្រកម្ពុជាក៏នៅមានកង្វះខាត និងកើតមានបញ្ហាប្រឈមផងដែរ រីឯលោកឯកឧត្ដមអភិបាលខេត្ត និងបណ្ដាអ្នកក្រោមឱវាទក៏កំពុងតែខិតខំប្រឹងប្រែងដោះស្រាយនូវបញ្ហាប្រឈមដែលកំពុងតែកើតឡើង។ ដោយហេតុខាងលើក្រុមនាងខ្ញុំក៏បានធ្វើការសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលស្ដីអំពី **ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្ដាល** ដើម្បីសិក្សា និងស្វែងរកនូវចំណុចខ្វះខាតនានា និងធ្វើការស្វែងរកដំណោះស្រាយ ហើយក៏ទទួលបានជាបទពិសោធន៍ ដើម្បីចែករំលែកដល់សិស្សប្អូន និងបណ្ដាអ្នកអាននានាដែលបានអានកិច្ចការសារណាមួយនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ខេត្តកណ្តាលរបស់យើង គឺគ្រប់គ្រងដោយគណៈអភិបាល អភិបាលរងខេត្ត គណៈអភិបាលក្រុង គណៈអភិបាលរងក្រុង ព្រមទាំងមន្ត្រីរាជការទាំងអស់នៅខេត្តកណ្តាលកំពុងមានតួនាទីក្នុងការដឹកនាំអភិវឌ្ឍន៍ និងរៀបចំទឹកដីនៃខេត្តកណ្តាលឱ្យមានភាពរីកចម្រើន។

ដើម្បីជាមាគ៌ាឈានទៅរកការបកស្រាយនូវប្រធានបទឱ្យយល់កាន់តែច្បាស់ យើងគប្បីស្វែងរកនូវដើមហេតុនៃការស្រាវជ្រាវជាមុនសិន៖

- ហេតុអ្វីចាំបាច់ត្រូវរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅខេត្តកណ្តាល?
- តើការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅខេត្តកណ្តាលប្រព្រឹត្តិទៅយ៉ាងដូចម្តេចខ្លះ?
- តើការរៀបចំទាំងនេះមានផលវិបាក និងមានដំណោះស្រាយដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

មានដើមតែងមានហេតុ មានហេតុតែងមានផល មូលហេតុដែលបណ្តាលឱ្យនាងខ្ញុំទាំងពីរនាក់ធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ **ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល** ព្រោះតែនាងខ្ញុំមានគោលបំណងដូចខាងក្រោម៖

- សិក្សាពីដំណើរការ និងប្រព័ន្ធគ្រប់គ្រងក្នុងខេត្តកណ្តាល
- សិក្សាលើបញ្ហាដែលកើតមានចំពោះបរិស្ថាននៅខេត្តកណ្តាល
- សិក្សាពីផែនការសកម្មភាព និងការអនុវត្តក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល
- ដើម្បីសិក្សាពីបញ្ហាដែលកើតមានឡើង ព្រមទាំងដំណោះស្រាយ
- ដើម្បីចងក្រងជាឯកសារដើម្បីជាព័ត៌មានមួយទាក់ទងនឹងខេត្តកណ្តាល
- ដើម្បីលើកទឹកចិត្តដល់សិស្សានុសិស្ស ប្រជាពលរដ្ឋឱ្យជួយថែរក្សា និងចូលរួមអភិវឌ្ឍន៍ខេត្តកណ្តាលឱ្យរីកចម្រើន។

## ៤. ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ

ទំហំ និងដែនកំណត់នៃការស្រាវជ្រាវប្រធានបទមួយនេះ គឺគ្របដណ្តប់លើការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពនៅក្នុងដែនសីម៉ានៃទឹកដីខេត្តកណ្តាល ហើយក្រុមនាងខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវនូវឯកសារ

ដែលពាក់ព័ន្ធ ធ្វើការបកស្រាយនូវរាល់ព័ត៌មានដែលទទួលបានពីការស្រាវជ្រាវឱ្យមានខ្លឹមសារ និងអត្ថន័យសម្រាប់សារណារបស់នាងខ្ញុំទាំងពីរនាក់។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ដល់នាងខ្ញុំទាំងពីរនាក់ ពិសេសដល់មិត្តនិស្សិត សិស្សប្អូន អ្នកស្រាវជ្រាវជំនាន់ក្រោយ និងសាធារណៈជនទាំងអស់ឱ្យយល់កាន់តែច្បាស់លាស់អំពីខេត្តកណ្តាលនូវរាល់រឿងរ៉ាវដូចជា កំណើត ឬប្រវត្តិនៃទឹកដីខេត្តកណ្តាល ការខិតខំក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធបញ្ហាដែលកើតមានលើបរិស្ថាន បញ្ហាប្រឈមនានានិងដំណោះស្រាយ ពិសេសនោះគឺការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល បណ្តាថ្នាក់ដឹកនាំនៃរដ្ឋបាលខេត្តកណ្តាល អាជ្ញាធរបានធ្វើសកម្មភាពដើម្បីភាពរីកចម្រើននៃទឹកដីខេត្តកណ្តាល។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវ និងបកស្រាយនូវប្រធានបទខាងលើ នាងខ្ញុំទាំងពីរនាក់បានធ្វើការស្រាវជ្រាវនូវរាល់ឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាលនៅឯសាលាខេត្តកណ្តាលផ្ទាល់ និងឯកសារមួយចំនួនទៀតក៏ទទួលបានពីបណ្តាវេបសាយ ឬប្រព័ន្ធផ្សព្វផ្សាយនានា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងប្រធានបទមួយនេះ គឺបានធ្វើការបែងចែកជា ៣ជំពូកធំៗគឺៈ

- **ជំពូកទី១ សញ្ញាណទូទៅនៃខេត្តកណ្តាល** ក្នុងនោះក៏មានការបែកចែកជាពីរផ្នែកធំៗទៀតគឺ ផ្នែកទី១ បរិបទទូទៅនៃខេត្តកណ្តាល និងផ្នែកទី២ រចនាសម្ព័ន្ធខេត្តកណ្តាល
- **ជំពូកទី២ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល** ក្នុងនោះក៏មានការបែកចែកជាពីរផ្នែកធំៗទៀតគឺ ផ្នែកទី១ អំពីបុព្វហេតុនៃការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល និងផ្នែកទី២ អំពីការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល។
- **ជំពូកទី៣ កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្តកណ្តាល** ក្នុងជំពូកនេះមានការបែងចែកជាពីរផ្នែកធំៗគឺ ផ្នែកទី១ ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចខេត្ត និងផ្នែកទី២ គោលបំណង និងទិសដៅសំខាន់ៗនៅឆ្នាំខាងមុខ។

# ជំពូកទី១

# សញ្ញាណទូទៅនៃខេត្តកណ្ដាល

# ជំពូកទី១

# សញ្ញាណទូទៅនៃខេត្តកណ្ដាល

## ១.១. បរិបទទូទៅនៃខេត្តកណ្ដាល

### ១.១.១. ប្រវត្តិនៃខេត្តកណ្ដាល

ខេត្តកណ្ដាល ជាឈ្មោះខេត្តមួយក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនៃប្រទេសកម្ពុជា ពាក្យនេះពុំដឹងជាមានប្រវត្តិនិងប្រភពដើមយ៉ាងណាទេ។ ក្នុងផែនដីព្រះបាទនរោត្តម ១៨៦០ ដល់១៩០៤ និងផែនដីព្រះបាទស៊ីសុវត្ថិ ១៩០៤ ដល់១៩២៧ ព្រះរាជាណាចក្រកម្ពុជាចែកចេញជាច្រើនខេត្តក្នុងនោះពុំមានឈ្មោះខេត្តកណ្ដាលទេ។ បើតាមឯកសារមហាបុរសខ្មែរបានឱ្យដឹងថាកាលណោះឈ្មោះខេត្តមួយចំនួន គឺជាឈ្មោះស្រុកនាពេលបច្ចុប្បន្ននេះរួមមានដូចជា ស្រុកល្វាឯម ស្រុកស្អាង ស្រុកកោះធំ និងស្រុកកណ្ដាលស្ទឹងជាដើម។ បើតាមកំណត់ត្រាចារឹកនៅចេតិយព្រះអង្គឌួង និងចេតិយបុរាណជាច្រើនទៀតលើភ្នំព្រះរាជទ្រព្យ ស្រុកពញាឮ យើងយល់ថា ក្នុងរាជព្រះបាទនរោត្តម ស៊ីសុវត្ថិ ភ្នំព្រះរាជទ្រព្យនេះស្ថិតក្នុង ស្រុកសំរោងទងជាឈ្មោះស្រុកមួយរបស់ខេត្តកំពង់ស្ពឺសព្វថ្ងៃ តែក្រោយមកក្នុងរាជ្យព្រះបាទស៊ីសុវត្ថិមុនីវង្ស ឆ្នាំ១៩២៧ ដល់១៩៤១ មានការរៀបចំព្រំប្រទល់ខេត្តជាថ្មីទើបបានជាភ្នំព្រះរាជទ្រព្យ ត្រូវស្ថិតនៅក្នុងខេត្តកណ្ដាលវិញកំណត់ត្រាចារឹកចេតិយព្រះស៊ីសុវត្ថិ យើងអាចសន្និដ្ឋានបានថា ខេត្តកណ្ដាលកើតមានក្នុងរចនាសម្ព័ន្ធរដ្ឋបាលចាប់តាំងពីរាជ្យព្រះបាទស៊ីសុវត្ថិមុនីវង្ស សម័យដែលអាណានិគមបារាំងគ្រប់គ្រង។[១]

ក្រសួងមហាផ្ទៃបានសម្រេចបង្កើត និងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាខេត្តកណ្ដាលជាផ្លូវការ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ កន្លងទៅ។ យោងតាមប្រកាសស្ដីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់និមិត្តសញ្ញាខេត្តកណ្ដាលបានបង្ហាញពីអត្ថន័យដូចខាងក្រោមៈ

- រង្វង់មូលពណ៌មាសព័ទ្ធជុំវិញ តំណាងឱ្យទឹកដីខេត្តកណ្ដាល ដែលហ៊ុមព័ទ្ធជុំវិញរាជធានីភ្នំពេញ
- មហាចេតិយចំនួន៣ តំណាងឱ្យជាតិ សាសនា ព្រះមហាក្សត្រ និងតំណាងឱ្យអំណាចទាំង៣របស់រដ្ឋ គឺ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ
- ព្រះសក្យមុនីចេតិយ តំណាងឱ្យទីតម្កល់នូវព្រះសារីរិកធាតុជាទីគោរពសក្ការៈរបស់ប្រជាជនកម្ពុជាចំពោះព្រះពុទ្ធសាសនា

[១] គេហទំព័រវិទ្យុវាយោ VAYO FM RADIO https://www.vayofm.com/news/detail/114617-954.html, ដកស្រង់ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៤

- កំពូលចេតិយ តំណាងឱ្យអរិយធម៌ និងភាពខ្ពង់ខ្ពស់នៃប្រជាជាតិកម្ពុជា តាំងពីបុរាណសម័យ
- ក្បូរក្បាច់រចនា តំណាងឱ្យភាពស៊ីវិល័យ ភាពរីកចម្រើន ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការប្រែក្លាយទឹកដីជនបទទៅជាទីក្រុង
- ឆ័ត្រត្រូត ៧ជាន់ តំណាងឱ្យថ្ងៃទាំង៧ នៃសប្តាហ៍ និងថ្ងៃជ័យជំនះ ៧មករា
- ភ្នំព្រះរាជទ្រព្យ តំណាងឱ្យមណ្ឌលដែនដី និងការគ្រប់គ្រងទឹកដីនៃខេត្តកណ្ដាល
- ដើមឈើពណ៌បៃតង តំណាងឱ្យបរិស្ថានល្អសំបូរទៅដោយធនធានធម្មជាតិ រុក្ខជាតិគ្រប់ប្រភេទ និងភាពរីកចម្រើននៃវិស័យកសិកម្ម
- ពពក តំណាងឱ្យភាពត្រជាក់ត្រជុំសុខដុមរមនារបស់ប្រជាជនដែលរស់ក្រោមដំបូលនៃសុខសន្តិភាពនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។[២]

### ១.១.២. ទីតាំងភូមិសាស្ត្រ

ខេត្តកណ្តាលជាខេត្តមួយក្នុងចំណោមខេត្តទាំង២៥ រាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជាដែលលាតសន្ធឹងហ៊ុំព័ទ្ធដោយរាជធានីភ្នំពេញ។ ខេត្តកណ្តាល មានព្រំប្រទល់ខាងជើងជាប់ខេត្តកំពង់ចាម និងកំពង់ឆ្នាំង ខាងលិចជាប់នឹងខេត្តកំពង់ស្ពឺ ខាងត្បូងជាប់នឹងខេត្តតាកែវ និងខេត្តអានយ៉ាងព្រំប្រទល់វៀតណាម ខាងកើតជាប់ព្រៃវែង។ ខេត្តកណ្តាលមានផ្ទៃដីសរុប **៣ ២១១.៤៦០ គីឡូម៉ែត្រការ៉េ** មាន១០ស្រុក និង០៣ក្រុង ចែកជា**១២៧ឃុំ-សង្កាត់** និងមាន**១០១០ភូមិ**។ ខេត្តនេះ មានទន្លេចំនួនបីឆ្លងកាត់មានដូចជា ទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ដោយទន្លេមេគង្គមានប្រវែង **៩៧ គីឡូម៉ែត្រ** ហើយហូរកាត់ស្រុកខ្សាច់កណ្តាល ស្រុកមុខកំពូល ស្រុកល្វាឯម ស្រុកគៀនស្វាយ និងស្រុកលើកដែក រីឯទន្លេសាបវិញមានប្រវែង **២៥ គីឡូម៉ែត្រ** ដោយហូរកាត់ស្រុកពញាឮ និងស្រុកមុខកំពូល ចំពោះទន្លេបាសាក់មានប្រវែង **៧៥,៧៥ គីឡូម៉ែត្រ** ដោយហូរកាត់ក្រុងតាខ្មៅ ស្រុកស្អាង ស្រុកគៀនស្វាយ និងស្រុកកោះធំ។[៣] ខេត្តកណ្តាល មានច្រកព្រំដែនចំនួន០៤ គឺច្រកទ្វេភាគីជ្រៃធំ ច្រកទ្វាព្រំដែនអន្តរជាតិក្អមសំណ ច្រកទ្វាតំបន់ជាប់សាធារណៈរដ្ឋប្រជាមានិតវៀតណាម ព្រែកជ្រៃ-ព្រៃទន្លា និងច្រកទ្វាតំបន់ព្រែកស្បូវ។[៤]

---

[២] ប្រកាស ស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តកណ្តាល, លេខ ៨៨៦៣ ប្រក, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩, ប្រការ២

[៣] របាយការណ៍ ស្តីពីផលប៉ះពាល់ដោយសារគ្រោះមហន្តរាយក្នុងខេត្តកណ្តាលប្រចាំឆ្នាំ២០២៣

[៤] គេហទំព័រ Kampuchea Thmey Daily https://images.app.goo.gl/yJ2sggPRet2Eo5REA, ដកស្រង់ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៤

ខេត្តកណ្តាល ជាខេត្តដំបូងគេដែលមានក្រុងចំនួន៣ មានដូចជា៖

- **ក្រុងតាខ្មៅ** កាលពីសម័យដើម ស្ថិតនៅក្នុងរដ្ឋបាលថ្នាក់ខេត្តហៅថា ខេត្តតាខ្មៅលុះដល់ចំណេរកាលតមកក៏បានដាក់ក្នុងរដ្ឋបាលថ្នាក់ស្រុក ក៏មានការផ្លាស់ប្តូរស្រុកតាខ្មៅទៅជា ក្រុងតាខ្មៅ និងបានប្តូរឃុំចំនួន០៦ ទៅជាសង្កាត់នៃក្រុងតាខ្មៅ មានដូចជា ឃុំតាក្តុលទៅជាសង្កាត់តាក្តុល ឃុំព្រែកឫស្សីទៅជាសង្កាត់ព្រែកឫស្សី ឃុំដើមមៀនទៅជាសង្កាត់ដើមមៀន ឃុំតាខ្មៅទៅជាសង្កាត់តាខ្មៅ ឃុំព្រែកហូរទៅជាសង្កាត់ព្រែកហូរ និងឃុំកំពង់សំណាញ់ទៅជាសង្កាត់កំពង់សំណាញ់។ ចំពោះការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុងតាខ្មៅត្រូវអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[៥] លុះមកដល់ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩ ក៏មានការប្តូរឃុំចំណុះក្រុងតាខ្មៅខេត្តកណ្តាលទៅជាសង្កាត់មានដូចជា ឃុំស្វាយរលំទៅជាសង្កាត់ស្វាយរលំ ឃុំកោះអន្លង់ចិនទៅជាសង្កាត់កោះអន្លង់ចិន ឃុំសិត្បូទៅជាសង្កាត់សិត្បូ និងឃុំរកាខ្ពស់ទៅជាសង្កាត់រកាខ្ពស់។[៦] ជារួម បច្ចុប្បន្ននេះ ក្រុងតាខ្មៅមានសង្កាត់ចំនួន ១០។
- **ក្រុងអរិយក្សត្រ** អរិយក្សត្រជាក្រុងទី២ របស់ខេត្តកណ្តាលបន្ទាប់ពីក្រុងតាខ្មៅ។ ក្រុងអរិយក្សត្រនៃខេត្តកណ្តាលត្រូវបានកាត់យកឃុំចំនួន០៦ពីស្រុកខ្សាច់កណ្តាល រួចឃុំទាំងនោះបានក្លាយទៅជាសង្កាត់ដែលមានដូចជា ឃុំបាក់ដាវ ឃុំកោះឧកញ៉ាតី ឃុំព្រែកអំបិល ឃុំព្រែកលួង ឃុំព្រែកតាកូវ ឃុំស្វាយជ្រុំ និងឃុំចំនួន០៥ទៀតពីស្រុកល្វាឯម មានឃុំអរិយក្សត្រ ឃុំសារិកាកែវ ឃុំពាមឧកញ៉ាអុង ឃុំព្រែកក្មេង ឃុំបារុង។ ក្រុងអរិយក្សត្រមានសង្កាត់ចំនួន១១ គឺសង្កាត់បាក់ដាវ សង្កាត់កោះឧកញ៉ាតី សង្កាត់ព្រែកអំបិល សង្កាត់ព្រែកលួង សង្កាត់ព្រែកតាកូវ សង្កាត់ស្វាយជ្រុំ សង្កាត់អរិយក្សត្រ សង្កាត់សារិកាកែវ សង្កាត់ពាមឧកញ៉ាអុង សង្កាត់ព្រែកក្មេង និងសង្កាត់បារុង។ ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុងអរិយក្សត្រត្រូវអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[៧]
- **ក្រុងសំពៅពូន** ក្រុងសំពៅពូន ជាក្រុងទី៣ របស់ខេត្តកណ្តាល ក្រុងសំពៅពូនបង្កើតឡើងដោយកាត់យកឃុំចំនួន០៥ពីស្រុកកោះធំ គឺឃុំឈើខ្មៅ ឃុំព្រែកជ្រៃ ឃុំព្រែកស្តី ឃុំជ្រោយតាកែវ និងឃុំសំពៅពូន ហើយឃុំទាំង០៥ពីស្រុកកោះធំនេះនឹងក្លាយជាសង្កាត់ឈើខ្មៅ សង្កាត់ព្រែកជ្រៃ សង្កាត់ព្រែកស្តី

[៥] អនុក្រឹត្យ ស្តីពីការប្តូរស្រុកតាខ្មៅទៅជាក្រុងតាខ្មៅ, លេខ ២២៨ អនក្រ.បក, ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨, មាត្រា២-៣

[៦] អនុក្រឹត្យ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងតាខ្មៅជាមួយស្រុកស្អាងនិងស្រុកកណ្តាលស្ទឹងនៃខេត្តកណ្តាល, លេខ ០៩ អនក្រ.បក, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩, មាត្រា២

[៧] អនុក្រឹត្យ ស្តីពីការបង្កើតក្រុងអរិយក្សត្រខេត្តកណ្តាល, លេខ ២៧២ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២, មាត្រា១-៣

សង្កាត់ជ្រោយតាកែវ និងសង្កាត់សំពៅពូន។ សម្រាប់ទីតាំងរដ្ឋបាល ក្រុងសំពៅពូន ត្រូវស្ថិតក្នុងសង្កាត់សំពៅពូន។ ចំពោះការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុងសំពៅពូនត្រូវអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ។ ជាមួយគ្នានេះផងដែរ ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាក្រុងសំពៅពូន និងក្រុមប្រឹក្សាស្រុកកោះធំ ត្រូវអនុលោមតាមមាត្រា១៨ថ្មីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។[៨]

### ១.១.៣ ស្ថានភាពប្រជាជន

ខេត្តកណ្តាល មានប្រជាពលរដ្ឋរស់នៅសរុបប្រមាណ **១ ៣៤៩ ៨៧៦ នាក់** (ស្រ្តី ៦៨៨ ៩៣៥ នាក់) ស្មើនឹង **៣០៧ ៩៧៩ គ្រួសារ**។ មានដង់ស៊ីតេប្រមាណ **៤២០នាក់** ក្នុងមួយគីឡូម៉ែត្រក្រឡា។ ប្រជាពលរដ្ឋប្រកបរបរកសិកម្មប្រមាណ ៤៦.៣% សិប្បកម្ម ១.១% សេវាកម្ម ៥២.៦% រកការងារធ្វើក្នុងប្រទេស ៣.៧% រកការងារក្រៅប្រទេស ០.៩% និងមន្ត្រីរាជការ ៤.១%។[៩]

គ្រួសារមានអគ្គីសនីប្រើប្រាស់ចំនួន ៣១០ ៧៧៥ គ្រួសារ ស្មើរនឹង ៩៨.៩៧% និងគ្រួសារស្នើរសុំភ្ជាប់ថ្មីមាន ១៧២៨គ្រួសារ។ ដោយឡែក ចំពោះគ្រួសារប្រើប្រាស់ទឹកស្អាតមានចំនួន ១៧៨ ០៩០គ្រួសារស្មើរនឹង ៩៥៤ភូមិ លើ១០១០ភូមិ ស្មើនឹង ៩៥.៥៤% និងមិនទាន់មានបណ្តាញទឹកស្អាតចំនួន ៥៦ភូមិ។[១០]

### ១.១.៤. វិស័យសំខាន់ៗក្នុងខេត្តកណ្ដាល

#### ១.១.៤.១. វិស័យទេសចរណ៍

វិស័យទេសចរណ៍ ឬតំបន់ទាក់ទាញ សំដៅដល់តំបន់ដែលទាក់ទាញយកនូវភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិជាច្រើនមកកំសាន្តទស្សនានូវទស្សនីយភាពដ៏កម្រមាន និងប្លែកៗពីតំបន់នីមួយៗ។ ជាធម្មតា ទីតាំងនីមួយៗតែងតែមាននូវភាពល្អឯកពិសេសៗរៀងៗខ្លួន ហើយក៏ក្លាយជាតំបន់ដែលទាក់ទាញនូវចិត្តរបស់ប្រជាជនឱ្យទៅទស្សនា ហើយទីតាំងនោះក៏ក្លាយជាតំបន់ទេសចរណ៍ដែលរួមចំណែកដល់ប្រទេសជាតិ និងជួយបង្កើនមុខរបរការងារដល់ប្រជាពលរដ្ឋក្នុងតំបន់។ ចំណែកឯ ខេត្តកណ្តាលរបស់យើងវិញ ក៏មិនខុសពីបណ្តាខេត្តដទៃនោះទេ ខេត្តកណ្តាលក៏សម្បូរទៅដោយតំបន់ទាក់ទាញជាច្រើនដែលមានដូចជា៖

[៨] អនុក្រឹត្យ ស្តីពីការបង្កើតក្រុងសំពៅពូន នៃខេត្តកណ្តាល, លេខ ២៧៩ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២, មាត្រា១-៤

[៩] របាយការណ៍ ស្តីពីផលប៉ះពាល់ដោយសារគ្រោះមហន្តរាយក្នុងខេត្តកណ្តាលប្រចាំឆ្នាំ២០២៣

[១០] របាយការណ៍ ស្តីពីផលប៉ះពាល់ដោយសារគ្រោះមហន្តរាយក្នុងខេត្តកណ្តាលប្រចាំឆ្នាំ២០២៣

- **រមណីយដ្ឋានស្នាងភ្នំ** គឺជារមណីយដ្ឋានទេសចរណ៍បែបធម្មជាតិ និងវប្បធម៌ដែលនៅទីនោះមានវត្តមួយសាងសង់នៅលើកំពូលភ្នំខ្ពស់ជាងគេ ដែលគេមើលឃើញពីទិដ្ឋភាពល្អប្លែកជុំវិញតំបន់នោះ។ រមណីយដ្ឋានស្នាងភ្នំពុំសូវសំបូរដើមឈើដូចនៅភ្នំធនមន្តទេ ប៉ុន្តែនៅជុំវិញវត្តមានបឹងយ៉ាងធំមួយដែលមានដុះទៅដោយផ្ការំចង់ និងព្រលិត។ លើសពីនេះ នៅក្នុងបឹងជុំវិញភ្នំនេះសំបូរត្រីណាស់អ្នកទេសចរណ៍អាចស្ទូចត្រី និងជិះទូកលេង។ រលកនៃខ្យល់បោកបក់មកប៉ះជើងភ្នំ ធ្វើឱ្យអ្នកកំសាន្តបំបាត់នូវភាពនឿយហត់។ បច្ចុប្បន្ន មន្ទីរទេសចរណ៍បានសហការជាមួយអាជ្ញាធរមូលដ្ឋានដាំកូនឈើ និងធ្វើសណ្តាប់ធ្នាប់ អនាម័យ សន្តិសុខនៅតំបន់នោះបានយ៉ាងល្អប្រសើរជូនភ្ញៀវទេសចរ។ ស្នាងភ្នំស្ថិតនៅភូមិពាមសាលា ឃុំស្នាងភ្នំ ស្រុកស្អាងមានចម្ងាយ ២៣គីឡូម៉ែត្រពីតាខ្មៅ។ ដើម្បីទៅកាន់ភ្នំនេះអ្នកដំណើរត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ២១។[១១]
- **វត្តទួលរាជា** គឺជាវត្តអារាមព្រះពុទ្ធសាសនាមួយដ៏មានសក្តានុពលដែលសម្បូរទៅដោយសមិទ្ធផល និងមានរូបព្រះពុទ្ធរូបដ៏ធំស្កឹមស្កៃជាងគេនៅប្រទេសកម្ពុជាដែលផុសចេញនៅលើទីទួលមួយដ៏ខ្ពស់តាមវាលស្រែ។ រូបសំណាក់ដ៏ធំនេះហើយដែលអ្នកនឹងមើលឃើញពីចម្ងាយនៅឡើមៗ ខណៈធ្វើដំណើរទៅកាន់ទីអារាមមួយនេះ។ វត្តទួលរាជា មានទីតាំងនៅទីខ្ពស់មួយតាមមាត់ទន្លេបាសាក់នាត្រើយខាងកើតក្នុងភូមិពោធិបាន ឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល។ វត្តទួលរាជាមានចម្ងាយ៣០គីឡូម៉ែត្រពីភ្នំពេញធ្វើដំណើរពីតាខ្មៅទៅស្រុកស្អាងដោយឆ្លងដកំពង់ផែសំប៉ាន។[១២]
- **រមណីយដ្ឋានគៀនស្វាយក្រៅ** គឺជាតំបន់ទេសចរណ៍ធម្មជាតិដែលមានខ្ទះមាត់ទឹកជាច្រើន និងមានផ្សារមួយផងដែរ។ រមណីយដ្ឋានគៀនស្វាយក្រៅស្ថិតនៅក្នុងឃុំភូមិធំ និងមានចម្ងាយ ១៧គីឡូម៉ែត្រពីរាជធានីភ្នំពេញ។[១៣]
- **រមណីយដ្ឋានភ្នំព្រះរាជទ្រព្យ (ភ្នំឧត្តុង្គ ឬភ្នំអដ្ឋរស្ស)** គឺជាអតីតរាជធានីនាសតវត្សរ៍ទី១៧ ចាប់ពីឆ្នាំ១៦១៨ ដល់ឆ្នាំ១៨៦៦ ហើយត្រូវបានប្តូររាជធានីទៅកាន់រាជធានីភ្នំពេញដោយព្រះបាទនរោត្តមនៅឆ្នាំ១៨៦៦។ ភ្នំនេះជាទីកន្លែងសម្រាប់បញ្ចុះសពនៃព្រះរាជវង្សានុវង្ស និងជាកន្លែងដែលព្រះរាជាទ្រង់ព្រះរាជាអនុញ្ញាតឱ្យសាងសង់វត្ត និងព្រះវិហារ។ ការដែលគេហៅ **"ភ្នំព្រះរាជទ្រព្យ"** ដោយសារព្រះមហាក្សត្រជំនាន់នោះយល់ថាភ្នំនេះមិនខ្ពស់ពេក ហើយស្ថិតនៅក្បែរឧត្តុង្គដែលជារាជវាំងស្រាប់ព្រះរាជាក៏ទ្រង់ចាត់ឱ្យកសាងព្រះចេតិយធំៗ ព្រមទាំងមានចម្លាក់លម្អសម្រាប់បញ្ចុះព្រះបរមអដ្ឋិ និង

[១១] គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://demo.cambodia.gov.kh/tourism/, ដកស្រង់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៤

[១២] គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://demo.cambodia.gov.kh/tourism/, ដកស្រង់ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៤

[១៣] គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://demo.cambodia.gov.kh/tourism/, ដកស្រង់ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៤

ព្រះអដ្ឋិនៃព្រះរាជវង្សនុវង្សដោយចាប់សាងបូជនីយស្ថាននោះ ដោយកម្លាំងព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ទើបសន្មតថា **"ភ្នំព្រះរាជទ្រព្យ"**។ ភ្នំព្រះរាជទ្រព្យ ឬភ្នំឧត្តុង្គជារមណីយដ្ឋានទេសចរណ៍ដែលមាន សណ្ឋានបែបប្រវត្តិសាស្ត្រ ដែលអាចឱ្យភ្ញៀវទេសចរសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រកម្ពុជា ព្រោះតែទី នោះធ្លាប់ជារាជវាំងចាស់អំឡុងឆ្នាំ១៦១៨ និងឆ្នាំ១៨៦៦។ **រមណីយដ្ឋានភ្នំព្រះរាជទ្រព្យ** ស្ថិតនៅតាម បណ្ដោយផ្លូវជាតិលេខ៥ (ចូលទៅក្នុងជម្រៅ ៣គីឡូម៉ែត្រ) ស្ថិតនៅក្នុង ឃុំផ្សារលើកដែក ឃុំភ្នំបាត ស្រុកពញាឮ។ បន្ថែមពីនេះរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ ជារមណីយដ្ឋានបែបវប្បធម៌ប្រវត្តិសាស្ត្រ និង ធម្មជាតិ និងមានចម្ងាយ ៥២គីឡូម៉ែត្រពីក្រុងតាខ្មៅ ឬ៤០គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ ចំពោះការ ចូលទស្សនាសម្រាប់ភ្ញៀវជាតិ រថយន្តតូច១គ្រឿង បង់តម្លៃ ២.០០០រៀល និងរថយន្ត Van ១គ្រឿង បង់តម្លៃ ៤.០០០រៀល និងសម្រាប់ភ្ញៀវអន្តរជាតិក្នុង១នាក់បង់តម្លៃ ១$/១លើក។[១៤]

- **វត្តវិហារសួគ៌** គឺជារមណីយដ្ឋានបែបវប្បធម៌ប្រវត្តិសាស្ត្រជំនឿសាសនា និងវត្ថុស័ក្តសិទ្ធិ។ ជាទីកន្លែង ដែលមានព្រឹត្តិការណ៍វប្បធម៌ប្រពៃណីដូចជាការប្រណាំងសេះ ក្របី ការប្រកួតចាំបាប់ និងគុនដំបង ខ្មែរជាដើម។ **វត្តវិហារសួគ៌** ស្ថិតក្នុងឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាលនៅតាមបណ្ដោយផ្លូវជាតិលេខ ៨A មានចម្ងាយ ៤០គីឡូម៉ែត្រពីរាជធានីភ្នំពេញ។[១៥]

- **រមណីយដ្ឋានព្រែកលាប និងបាក់ខែង** គឺជារមណីយដ្ឋានប្របនឹងមាត់ទឹក ដោយអ្នកនឹងឃើញមាន កញ្ចុះ ឬតូបស្បូវលើទឹកជាច្រើនតាមដងទន្លេ សម្រាប់ទទួលភ្ញៀវទេសចរអាចសម្រាកលំហែអារម្មណ៍ ស្រូបយកខ្យល់អាកាសបរិសុទ្ធតាមបណ្ដោយមាត់ដងទន្លេមេគង្គ។ ព្រែកលាប និងបាក់ខែង ជា រមណីយដ្ឋាននៅក្បែរៗគ្នា ដោយមានចម្ងាយពីភ្នំពេញប្រមាណ ២៥គីឡូម៉ែត្រ ចុះពីស្ពានជ្រោយចង្វារ ទៅត្រង់តាមផ្លូវជាតិលេខ 6A។[១៦]

- **រមណីយដ្ឋានឆ្នេរខ្សាច់កោះដាច់** ជារមណីយដ្ឋានទេសចរណ៍បែបធម្មជាតិ។ នៅទីនេះមានបម្រើសេវា កម្សាន្ត ភោជនីយដ្ឋាន និងគ្រែអង្គុយតាមមាត់ទឹក និងជាទីតាំងដ៏ស្រស់ត្រកាលដែលពោរពេញទៅ ដោយឆ្នេរខ្សាច់សក្បោះ ទឹកទន្លេដ៏ត្រជាក់ថ្លាយង់ ដែលអាចផ្តល់នូវអារម្មណ៍ស្រស់ថ្លាដល់ភ្ញៀវទេសចរ ទាំងអស់ ដែលបានទៅកម្សាន្តនៅទីនោះ។ ក្រៅពីនេះ តំបន់នេះត្រូវបានគេចាត់ទុកថា ជាមជ្ឈមណ្ឌល សិប្បកម្មដែលស្ថិតនៅចំកណ្ដាលនៃដងទន្លេមេគង្គមានបណ្ដោយប្រវែង ១២គីឡូម៉ែត្រ។ នៅទីនេះមាន សិប្បកម្មត្បាញក្រមា មុង សារុងសូត្រ ហូល ផាមួង ក្រមា សូត្រ និងជំនួញដូរខ្មាតតូចជាច្រើន

[១៤] គេហទំព័រ រដ្ឋបាលខេត្តកណ្ដាល https://demo.cambodia.gov.kh/tourism/, ដកស្រង់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៤

[១៥] គេហទំព័រ រដ្ឋបាលខេត្តកណ្ដាល https://demo.cambodia.gov.kh/tourism/, ដកស្រង់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤

[១៦] គេហទំព័រ រដ្ឋបាលខេត្តកណ្ដាល https://demo.cambodia.gov.kh/tourism/, ដកស្រង់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤

ផ្សេងទៀត។ ជាក់ស្តែង ស្ទើរគ្រប់លំនៅឋានរបស់ប្រជាពលរដ្ឋ គេតែងតែឃើញមានបន្សល់ទុកនូវកីតម្បាញនៅក្រោមផ្ទះ។ ផ្អែកតាមលក្ខណៈសម្បត្តិរបស់កោះដាច់ ដែលសម្បូរទៅដោយធនធានធម្មជាតិយ៉ាងក្រាស់ក្រែល និងប្រពៃណីផងនោះបានធ្វើឱ្យតំបន់នេះប្រែក្លាយទៅ ជារមណីយដ្ឋានដ៏មានប្រជាប្រិយភាព និងជាទីចាប់អារម្មណ៍របស់ភ្ញៀវទេសចរក្នុងស្រុក។ រមណីយដ្ឋាននេះ មានទីតាំងស្ថិតនៅក្នុងភូមិក្បាលកោះ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារដែលមានចំងាយប្រមាណជា ៨គីឡូម៉ែត្រពីរាជធានីភ្នំពេញ។[១៧]

- **រមណីយដ្ឋានភ្នំប្រសិទ្ធី** ជារមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ និងធម្មជាតិ។ ស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៥ មានចម្ងាយ ២៣គីឡូម៉ែត្រពីរាជធានីភ្នំពេញ បែកចូលទៅក្នុងគ្រង់ផ្សារព្រែកព្នៅ (រាជធានីភ្នំពេញ)ចម្ងាយ ១៣គីឡូម៉ែត្រ។ តួមណីយដ្ឋានគឺជាកូនភ្នំពីរទន្ទឹមគ្នាខ័ណ្ឌដោយជ្រលងផ្លូវកណ្តាលមានចម្ងាយ ១គីឡូម៉ែត្រពីគ្នា។ ប្រសិទ្ធីត្រៃត្រឹង្ស ឬប្រសិទ្ធីខាងកើតស្ថិតក្នុងឃុំឈ្វាំង ស្រុកពញាឮ។ នៅទីនោះមានវត្តខ្មែរបុរាណសង់នៅលើកំពូលភ្នំ និងមានប្រាសាទបុរាណ (ប្រាសាទនាងគ្រប់លក្ខណ៍កសាងនៅ ស.វ ទី៧)។ ចំពោះប្រសិទ្ធីខាងលិចស្ថិតនៅក្នុង ឃុំម្កាក់ ស្រុកអង្គស្នួល។ នៅចង្កេះភ្នំបែកខាងជើងមានវត្តបុរាណខ្មែរមួយហើយនៅលើកំពូលភ្នំមានវត្តមានព្រះពុទ្ធសាសនាមហាយាននិកាយគង់ស៊ីអឹម ឬវត្តចិន។[១៨]
- **សួនសត្វភ្នំពេញសាហ្វារី** គឺមានសត្វជាច្រើនចម្រុះគ្នារហូតដល់ប្រមាណ ៨៩ប្រភេទ ដែលអាចឱ្យអ្នកទស្សនាបានប្លែកភ្នែក សប្បាយចិត្ត ថែមទាំងបានទស្សនានូវការសម្តែងពិសេសពីសត្វបួនប្រភេទរួមមានដូចជា សត្វក្រពើ សត្វបក្សី សត្វខ្លា និងសត្វអ៊ូរ៉ង់អ៊ូតងជាដើម ដែលសុទ្ធសឹងតែត្រូវបានបង្ហាត់បង្រៀនដោយយកចិត្តទុកដាក់ពីគ្រូជំនាញ។ **សួនសត្វភ្នំពេញសាហ្វារី** ដែលមានទីតាំងស្ថិតនៅ ភូមិព្រែកតារត្ន័ ឃុំព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ។ សម្រាប់កន្លែងកំសាន្តមួយនេះចាំបាច់ត្រូវការចំណាយ សម្រាប់ក្មេងសំបុត្រ ៦ដុល្លារ ទៅ ៨ដុល្លារ និងមនុស្សធំតម្លៃ ១០ ទៅ ១២ដុល្លារអាមេរិក អាចទស្សនាកម្សាន្តពេញមួយថ្ងៃតែម្តង សួនកំសាន្តនេះបើករៀងរាល់ 8:00 ព្រឹកដល់ម៉ោង 5:00 ល្ងាច។[១៩]

[១៧] គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://demo.cambodia.gov.kh/tourism/, ដកស្រង់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤

[១៨] គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://demo.cambodia.gov.kh/tourism/, ដកស្រង់ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤

[១៩] គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://demo.cambodia.gov.kh/tourism/, ដកស្រង់ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៤

បន្ថែមពីនោះ ខេត្តកណ្ដាលមានសណ្ឋាគារ ៩កន្លែង នៅក្រុងតាខ្មៅ២កន្លែង និងនៅតាមតំបន់ព្រំដែន ចំនួន ៧កន្លែង គឺស្ថិតនៅក្នុងស្រុកលើកដែក២ និងស្រុកកោះធំ៥។[២០]

### ១.១.៤.២. វិស័យអប់រំ

ផ្នែកវិស័យអប់រំនៅខេត្តកណ្ដាលមានដូចជា៖

- សាលារៀនមានចំនួន ៧៦១ និងសាលារៀនក្នុងវត្តចំនួន ២១៣
- សិស្សសរុបប្រមាណ ២៦៣ ៧៨៦នាក់
- គ្រូបង្រៀនសរុបប្រមាណ ៧ ២៩៩នាក់ (មិនបង្រៀនចំនួន១ ៥១៦នាក់)
- ថ្នាក់រៀន ៦៨១០ថ្នាក់ និងក្នុងវត្តចំនួន ១៧៥ថ្នាក់
  - សាលាមតេយ្យចំនួន ២៤៨សាលា, ៥១៧ថ្នាក់រៀន, ១៨ថ្នាក់រៀនក្នុងវត្ត, សិស្សសរុប ១៥ ៨២២ នាក់, គ្រូបង្រៀនសរុប ៥២៨នាក់
  - សាលាបឋមសិក្សាចំនួន ៣៧៣សាលា, ៤ ៣២៣ថ្នាក់រៀន, ៩៧ថ្នាក់រៀនក្នុងវត្ត, សិស្សសរុប ១៦១ ៧០០នាក់, គ្រូបង្រៀនសរុប ៣ ២៤១នាក់
  - អនុវិទ្យាល័យចំនួន ១០០សាលា, ៧៥៩ថ្នាក់រៀន, ៣៨ថ្នាក់រៀនក្នុងវត្ត, សិស្សសរុប ៣២ ០៧៣ នាក់, គ្រូបង្រៀនសរុបប្រមាណ ១ ៩០៤នាក់
  - វិទ្យាល័យមានចំនួន ៤០សាលា, ១ ២១១ថ្នាក់រៀន, ២២ថ្នាក់រៀនក្នុងវត្ត, សិស្សសរុប ៥៤ ១៩១ នាក់, គ្រូបង្រៀនចំនួន ៣ ១៤២នាក់
  - វិទ្យាល័យមានតែថ្នាក់ទី១០ដល់ទី១២ មានចំនួន ២សាលា, ៧៣ថ្នាក់រៀន, ក្នុងវត្ត0, សិស្សសរុប ចំនួន ២ ៩៩៧នាក់, គ្រូបង្រៀនចំនួន ១៨៥នាក់។[២១]

### ១.១.៤.៣. វិស័យសុខាភិបាល

បញ្ជីមូលដ្ឋានសុខាភិបាលខេត្តកណ្ដាលមានចំនួន២១ ក្នុងនោះមន្ទីរបង្អែកមានចំនួន១០មន្ទីរពេទ្យ មណ្ឌលសុខភាពចំនួន ០៨ និងមូលដ្ឋានសុខាភិបាលឯកជន មន្ទីរសម្រាកព្យាបាល និងមន្ទីរពហុព្យាលបាល ចំនួន០៣។

[២០] របាយការណ៍ លទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២០ និងទិសដៅការងារបន្តរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ខេត្តកណ្ដាល

[២១] ស្ថិតិ និងសូចនាករអប់រំសាធារណៈ ២០២១-២០២២, ក្រសួងអប់រំ យុវជន និងកីឡា, នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

- មន្ទីរពេទ្យបង្អែកមានដូចជា មន្ទីរពេទ្យបង្អែកជ័យជំនះ មន្ទីរពេទ្យបង្អែកស្អូល មន្ទីរពេទ្យបង្អែកកោះធំ មន្ទីរពេទ្យបង្អែកស្រុកស្អាង មន្ទីរពេទ្យបង្អែកប៊ុនរ៉ានីហ៊ុនសែនរកាកោង មន្ទីរពេទ្យបង្អែកខ្សាច់កណ្ដាល មន្ទីរពេទ្យបង្អែកលើកដែក មន្ទីរពេទ្យបង្អែកកៀនស្វាយ មន្ទីរពេទ្យបង្អែកល្វាឯម ព្រមទាំងមន្ទីរពេទ្យបង្អែកកណ្ដាលស្ទឹង
- មណ្ឌលសុខភាពមានដូចជា មណ្ឌលសុខភាពព្រែកអញ្ចាញ មណ្ឌលសុខភាពវិហាសួគ៌ មណ្ឌលសុខភាពសំរោងធំ មណ្ឌលសុខភាពបែកចាន មណ្ឌលសុខភាពឈើទាល មណ្ឌលសុខភាពសៀមរាប មណ្ឌលសុខភាពគគីរធំ មណ្ឌលសុខភាពដំណាក់អំពិល
- មន្ទីរសម្រាកព្យាបាល និងមន្ទីរពហុព្យាលបាលមានដូចជា មន្ទីរសម្រាកព្យាបាលទេពមង្គល មន្ទីរសម្រាកព្យាបាលសុខាបែកចាន មន្ទីរសម្រាកព្យាបាលសុខលាភមេត្រី។[២២]

ក្នុងនោះ មូលដ្ឋានសុខាភិបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គមមានចំនួន ១០ គឺមន្ទីរពេទ្យបង្អែកចំនួន០៦ និងមណ្ឌលសុខភាពចំនួន០៤ រួមមានដូចជា មន្ទីរពេទ្យបង្អែកជ័យជំនះ មន្ទីរពេទ្យបង្អែកស្អូល មន្ទីរពេទ្យបង្អែកកោះធំ មន្ទីរពេទ្យបង្អែកស្រុកស្អាង មន្ទីរពេទ្យបង្អែកប៊ុនរ៉ានីហ៊ុនសែនរកាកោង មន្ទីរពេទ្យបង្អែកខ្សាច់កណ្ដាល មណ្ឌលសុខភាពបែកចាន មណ្ឌលសុខភាពព្រែកអញ្ចាញ មណ្ឌលសុខភាពវិហាសួគ៌ មណ្ឌលសុខភាពសំរោងធំ។[២៣]

ការដាក់សម្ពោធឱ្យប្រើប្រាស់អគារវះកាត់ និងអគារសម្ភពក្នុងមន្ទីរពេទ្យបង្អែកជ័យជំនះ ដែលស្ថិតនៅក្រុងតាខ្មៅ ខេត្តកណ្ដាល។ អគារវះកាត់ និងអគារសម្ភពនេះជាការសម្រេចឧបត្ថម្ភរបស់អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុន្នីរដ្ឋ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលអគារនេះមានកម្ពស់៨ជាន់ មាន ១២៨បន្ទប់ ចំណាយថវិកាប្រមាណ ៦លានដុល្លារ។ ពិធីដាក់សម្ពោធឱ្យប្រើប្រាស់នេះបានប្រារព្ធនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២២។[២៤]

---

[២២] គេហទំព័រ Open development Mekong https://data.opendevelopmentmekong.net/dataset/9c0daca4-3148-46b0-b81f-67fb78bccd41/resource/ea2db792-ad1f-4794-a021-2451faf06418\, ដកស្រង់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤

[២៣] គេហទំព័រ បេឡាជាតិសន្តិសុខ https://www.nssf.gov.kh/, ដកស្រង់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤

[២៤] គេហទំព័រ Fresh news https://freshnewsasia.com/index.php/en/localnews/229655-2022-01-30-05-38-05.html, ដកស្រង់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៤

#### ១.១.៤.៤. វិស័យធម្មការ និងសាសនា

ផ្នែកពុទ្ធសាសនា មានចំនួន ៣៥៣វត្ត បានចុះបញ្ជីដីគរុកភ័ណ្ឌវត្តចំនួន ១៩២វត្ត ប្លង់រឹងចំនួន ៦៤វត្ត បង្កាន់ដៃចំនួន ២៤វត្ត និងវាស់វែងរួចបានចំនួន ១០៤វត្ត។ មានសាលាពុទ្ធិកបឋម ៨៤ស្មើរ ១២៧ថ្នាក់ និង សាលាពុទ្ធិកអនុវិទ្យាល័យ ៦ស្មើរនឹង១៧ថ្នាក់ សាលាពុទ្ធិកវិទ្យាល័យ១ ស្មើរ៣ថ្នាក់។[២៥]

តាមសង្ឃដីការព្រះវិន័យខេត្តកណ្ដាលមាន សម្ដេចព្រះកិត្តិយស ២អង្គ ព្រះរាជាគណៈថ្នាក់ទោ ៣អង្គ ព្រះរាជាគណៈថ្នាក់ចត្វា ១អង្គ ព្រះរាជាគណៈថ្នាក់កិត្តិយស ៧២អង្គ មន្ត្រីសង្ឃ ខេត្ត ៦អង្គ ព្រះអនុគណក្រុង-ស្រុក ១១អង្គ ព្រះគ្រូ ១៥៣អង្គ ជំនួយការសាលាគណខេត្ត ៤អង្គ។[២៦]

## ១.២. រចនាសម្ព័ន្ធខេត្តកណ្ដាល

### ១.២.១. ក្រុមប្រឹក្សាខេត្តកណ្ដាល




#### ១.២.១.១. ការបង្កើតក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តដែលបានបង្កើតដោយការបោះឆ្នោត ស្របតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈជាអ្នកការពារ និងជាអ្នកបម្រើអោយផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[២៧]

[២៥] របាយការណ៍ លទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២០ និងទិសដៅការងារបន្តរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកណ្ដាល

[២៦] រដ្ឋបាលខេត្តកណ្ដាល https://www.kandal.gov.kh/detail/23391, ដកស្រង់ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤

[២៧] អនុក្រឹត្យ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៦

ក្រុមប្រឹក្សាខេត្ត ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលចូលជាធរមាន។[២៨]

### ១.២.១.២. តួនាទី មុខងារ និងភារកិច្ចក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តមានតួនាទីចាត់ចែងកិច្ចការនានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើតការជំរុញ និងការធ្វើអោយមានភាពរីកចម្រើនដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដើម្បីបំពេញមុខងារ ភារកិច្ច ដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្ម ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[២៩]

ក្រុមប្រឹក្សាខេត្ត ត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ សេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកា សេចក្តីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចនោះ ត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវណែនាំ ឬអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាកែតម្រូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះឡើងវិញ។[៣០]

ប្រធានក្រុមប្រឹក្សាខេត្ត ក្នុងនាមក្រុមប្រឹក្សាខេត្តរបស់ខ្លួន មានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលខេត្តលើ៖

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខេត្ត
- កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សាខេត្ត បានអនុម័តរួច
- សំណើដកហូតអភិបាល ឬអភិបាលរងខេត្តចេញពីមុខតំណែង តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខេត្ត
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាខេត្ត
- ប្រតិទិនប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តសម្រាប់រយៈពេល១២ខែ

---

[២៨] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៧

[២៩] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៨

[៣០] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា១០

- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាខេត្ត
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលខេត្ត ត្រូវជួយក្រុមប្រឹក្សាខេត្តរបស់ខ្លួន ក្នុងការរៀបចំឯកសារខាងលើនេះលើកលែងតែឯកសារសម្រាប់រៀបចំកិច្ចប្រជុំទាក់ទងនឹងសំណើដកហូតអភិបាល ឬអភិបាលរងខេត្តចេញពីមុខតំណែង។[៣១]

### ១.២.១.៣. កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្ត

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាខេត្តមាន ២ប្រភេទ៖

- **កិច្ចប្រជុំសាមញ្ញ** ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងហោចណាស់ចំនួន១២ដងក្នុងមួយឆ្នាំ
- **ការប្រជុំវិសាមញ្ញ** ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេស។

កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តអាចយកជាការបាន លុះត្រាតែកិច្ចប្រជុំទាំងនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខេត្ត។ សេចក្តីសម្រេចណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាខេត្ត រដ្ឋធម្មនុញ្ញ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត សេចក្តីសម្រេចពុំមានសុពលភាពឡើយ។[៣២]

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលខេត្ត និងជាវិធានការ បែបបទ នីតិវិធីចាត់ចែងការងារតាមការចាំបាច់ដែលទាក់ទងទៅនឹង៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាខេត្ត
- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលខេត្ត

[៣១] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា១៣

[៣២] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា១១

- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាខេត្ត ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្ត
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជន ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានា។[៣៣]

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាខេត្តត្រូវធ្វើការសម្រេចដូចរៀបរាប់ខាងលើ ក្រុមប្រឹក្សាខេត្តអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមានៈ

- ការកោះអញ្ជើញអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬគណៈអភិបាលខេត្ត ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ឬហេតុការណ៍ណាមួយដែលកើតមានក្នុងខេត្ត ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធ
- ការសម្រេចឱ្យសិក្សាស្រាវជ្រាវ ឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាខេត្តយល់ថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋ ដែលខ្លួនជាតំណាង និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឬការធ្វើអង្កេតនេះ និងណែនាំដល់គណៈអភិបាលខេត្តអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ការពិនិត្យស្រាវជ្រាវ និងធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ ដែលប្រព្រឹត្តិដោយក្រុមប្រឹក្សាខេត្ត ឬសមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត អភិបាលខេត្ត អភិបាលរងខេត្ត ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋាន ស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន

[៣៣] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា១៤

- ការពិនិត្យ ដោះស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលខេត្ត
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តយល់ឃើញថាចាំបាច់។[៣៤]

### ១.២.១.៤. ការបង្កើតគណៈកម្មាធិការ

ក្រុមប្រឹក្សាខេត្ត ត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី ដែលតម្រូវអោយបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។[៣៥]

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាខេត្តអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់។ គណៈកម្មាធិការដែលបង្កើតបន្ថែមមិនត្រូវមានតួនាទី និងភារកិច្ចត្រួតគ្នាជាមួយនឹងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការទាំងបីខាងលើឡើយ។ ជាមួយនេះដែរ ក្រុមប្រឹក្សាខេត្តអាចបង្កើតអនុគណៈកម្មាធិការ ក្រុមការងារផ្សេងៗទៀតតាមការស្នើសុំរបស់គណៈកម្មាធិការនានា ឬគណៈអភិបាលខេត្ត។

អនុគណៈកម្មាធិការ ឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការ ឬគណៈអភិបាលខេត្ត។[៣៦]

ក្នុងការរៀបចំបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាខេត្តត្រូវពិនិត្យពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម៖

- ក្រុមប្រឹក្សាខេត្តអាចតែងតាំងសមាជិកក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត អភិបាលរងខេត្ត បុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត តំណាងក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ខេត្ត តំណាងសហគមន៍

---

[៣៤] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា១៥

[៣៥] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា១៨

[៣៦] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា១៩

ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង

- ក្រុមប្រឹក្សាខេត្ត ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ការតែងតាំងប្រធាន អនុប្រធាន និងការកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង
- គណៈកម្មាធិការ អនុគណៈកម្មាធិការ ក្រុមការងារនីមួយៗ ត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងតំណែងប្រធាន អនុប្រធានគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារផង
- ក្រុមប្រឹក្សាខេត្តអាចរំសាយគណៈកម្មាធិការ អនុគណៈកម្មាធិការ ក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ អនុគណៈកម្មាធិការ ក្រុមការងារដែលខ្លួនបានបង្កើតឡើងតាមការចាំបាច់ ឬតាមសំណើរបស់គណៈកម្មាធិការ ឬគណៈអភិបាលខេត្ត
- គណៈអភិបាលខេត្តអាចស្នើសុំក្រុមប្រឹក្សាខេត្ត ដើម្បីឱ្យគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារណាមួយ ដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត
- ក្រុមប្រឹក្សាខេត្តត្រូវទទួលខុសត្រូវរាល់ការសម្រេច និងសកម្មភាពរបស់គណៈកម្មាធិការនានា និងទទួលខុសត្រូវចំពោះផលវិបាកនានា ដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ
- ក្រុមប្រឹក្សាខេត្ត ត្រូវណែនាំឱ្យគណៈអភិបាលខេត្តឱ្យផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋានការគាំទ្រផ្នែកច្បាប់ និងបច្ចេកទេស ការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី ដល់គណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង
- គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។ សេចក្តីរាយការណ៍ទាំងនេះត្រូវចម្លងជូនគណៈអភិបាលខេត្តដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រុមប្រឹក្សាខេត្ត
- ក្រុមប្រឹក្សាខេត្ត អាចតម្រូវឱ្យគណៈកម្មាធិការណាមួយធ្វើសេចក្តី រាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេស និងបន្ទាន់ណាមួយក្នុងកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់។[៣៧]

[៣៧] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា២០-២៤

### ១.២.២. គណៈអភិបាល




#### ១.២.២.១. ការបង្កើតគណៈអភិបាលខេត្ត

ខេត្តនីមួយៗ ត្រូវមានគណៈអភិបាលខេត្តមួយដែលរួមមាន អភិបាលខេត្ត អភិបាលរងខេត្ត ដែលត្រូវបានតែងតាំងឡើងស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ប៉ុន្តែ អភិបាលខេត្ត អភិបាលរងខេត្ត មិនមែនជាសមាជិកក្រុមប្រឹក្សាឡើយ។ បន្ថែមពីនោះ គណៈអភិបាលខេត្តត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។[៣៨]

#### ១.២.២.២. តួនាទី-ភារកិច្ចរបស់គណៈអភិបាលខេត្ត

គណៈអភិបាលខេត្ត មានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សាខេត្ត និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។[៣៩]

[៣៨] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា២៥-២៧

[៣៩] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា២៨

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងខេត្ត អភិបាលខេត្តមានភារកិច្ចៈ

- ណែនាំដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ឱ្យអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងមន្ទីរ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ។
- សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័ន ដែលប្រចាំនៅខេត្តក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យអភិបាលខេត្តត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរ អង្គភាព និងទីភ្នាក់ងារដែលពាក់ព័ន្ធដើម្បីរួមគ្នាអនុវត្តកិច្ចការនោះដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាខេត្ត អភិបាលខេត្តត្រូវធ្វើការសម្របសម្រួល និងតម្រង់ទិសដល់ មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួនទៅក្នុង ផែនការនិងថវិការបស់ក្រុមប្រឹក្សាខេត្ត
- ពិនិត្យវាយតម្លៃផ្តល់មូលវិចារ និងដាក់ពិន្ទុដល់ប្រធានមន្ទីរ អង្គភាពរបស់ក្រសួងស្ថាប័ននានា តាមគោលការណ៍កំណត់។
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្តជាមុន ក្នុងការផ្តល់យោបល់ដល់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នលើបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានាដែលប្រចាំនៅខេត្ត។ ក្នុងករណី មិនគាំទ្រចំពោះបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពណាមួយ អភិបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់លាស់អំពីហេតុផលដែលមិនគាំទ្រនោះជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីដើម្បីពិនិត្យពិចារណា។ ក្នុងករណីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីឯកភាពតាមរបាយការណ៍របស់អភិបាលខេត្ត រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវផ្លាស់ប្តូរបេក្ខភាពដែលបានស្នើឡើងឱ្យបានសមស្រប។ ក្នុងករណីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីស្រាវជ្រាវឃើញថា ហេតុផលដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់អភិបាលខេត្តពុំមានមូលដ្ឋានច្បាស់លាស់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវបញ្ជាក់ជូនអភិបាលខេត្ត ដើម្បីទទួលយកបេក្ខភាពដែលបានស្នើតែងតាំងនោះ។ ក្នុងករណីមិនមានការឯកភាព រវាងអភិបាលខេត្ត ជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីទៅលើបេក្ខភាពដែលស្នើតែងតាំងនោះទេ នោះរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យសម្រេច។ អភិបាលខេត្តត្រូវ រាយការណ៍ករណីនេះជូនក្រុមប្រឹក្សារបស់ខ្លួន និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

- ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីក្នុងមន្ទីរ អង្គភាព និងទីភ្នាក់ងារណាមួយរបស់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយ អភិបាលខេត្តត្រូវធ្វើការណែនាំជាបន្ទាន់ដល់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះឱ្យធ្វើការកែលម្អឡើងវិញជាបន្ទាន់។ ក្នុងករណីប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះមិនបានកែប្រែ ឬក្នុងករណីភាពមិនប្រក្រតី ឬការប្រព្រឹត្តខុសឆ្គងខាងលើមានលក្ខណៈធ្ងន់ធ្ងរ អភិបាលខេត្តត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ ទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីនៃមន្ទីរ អង្គភាព និងទីភ្នាក់ងារទាំងនោះ។ រដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ដើម្បីដោះស្រាយទៅតាមច្បាប់។
- អភិបាលខេត្ត មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន ដើម្បីដកហូតពីមុខតំណែងនូវប្រធានមន្ទីរ អង្គភាព ឬអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយដែលប្រព្រឹត្តខុសឆ្គង ហើយដែលមិនអាចធ្វើយុត្តិកម្មបាន។

ដើម្បីធានាឱ្យអភិបាលខេត្តអនុវត្តនូវតួនាទីភារកិច្ចខាងលើនេះសេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ទៅរដ្ឋមន្ត្រី ឬប្រធានស្ថាប័ន សាមី ត្រូវដាក់ជូនអភិបាលខេត្តដើម្បីពិនិត្យ ផ្តល់យោបល់ជាមុន។ ប្រសិនបើឯកភាព អភិបាលខេត្តត្រូវចុះហត្ថលេខា លើរបាយការណ៍នេះជាមួយប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។ ចំពោះសេចក្តីរាយការណ៍ក្រៅពីនោះរបស់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅខេត្ត ត្រូវចម្លងជូនសាលាខេត្ត។[៤០]

បន្ថែមពីនោះអភិបាលខេត្តត្រូវជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល ក្នុងការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ព្រមទាំងធានាឱ្យមានការការពារ គោរពសិទ្ធមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្ត។ អភិបាលខេត្ត គឺជាប្រធានគណៈបញ្ជាការឯកភាពខេត្ត ក្នុងការដឹកនាំ សម្របសម្រួលមន្ទីរ អង្គភាពពាក់ព័ន្ធនានា រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងខេត្ត។[៤១]

ក្នុងករណីអភិបាលខេត្តអវត្តមាន អភិបាលខេត្តត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងខេត្តមួយរូប ឱ្យទទួលជាអភិបាលខេត្តស្តីទី។ ប៉ុន្តែប្រសិនបើអភិបាលខេត្តអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរង

[៤០] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៣៥

[៤១] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៣៦

ខេត្តដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃ អនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលខេត្ត ត្រូវធ្វើជាអភិបាលខេត្តស្តីទី។ ក្នុងករណីអភិបាលខេត្តស្តីទីអវត្តមាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាស ដើម្បីប្រគល់ភារកិច្ចជូន អភិបាលរងខេត្តមួយរូបឱ្យទទួលជាអភិបាលខេត្តស្តីទី។ អភិបាលខេត្តស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលខេត្ត នៅពេលដែលអភិបាលខេត្តមានវត្តមានវិញ។ ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្ទេរសិទ្ធិនេះ។[៤២]

### ១.២.២.៣. នាយករដ្ឋបាលសាលាខេត្ត

ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្ត ត្រូវមាននាយករដ្ឋបាលមួយរូប ហៅថានាយករដ្ឋបាលសាលាខេត្តដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើរពីគណៈអភិបាលខេត្ត យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ហើយស្ថិតក្នុងឋានន្តរស័ក្តិចាប់ពីអនុមន្ត្រីនៃក្របខណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ។ ចំពោះនាយករដ្ឋបាលសាលាខេត្តត្រូវមាននាយករងរដ្ឋបាលពីររូបជាជំនួយការ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើរពីគណៈអភិបាលខេត្ត យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត និងត្រូវស្ថិតក្នុងឋានន្តរស័ក្តិចាប់ពីនាយក្រមការនៃក្របខណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។[៤៣]

នាយករដ្ឋបាលសាលាខេត្ត មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងគណៈអភិបាលរងខេត្តក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខេត្ត។ បន្ថែមពីនេះ នាយករដ្ឋបាលសាលាខេត្តត្រូវធ្វើរបាយការណ៍ និងមានគណនេយ្យភាពចំពោះគណៈអភិបាលខេត្ត អភិបាលខេត្ត និងក្រុមប្រឹក្សារបស់ខ្លួន។[៤៤]

### ១.២.២.៤. ទីចាត់ការចំណុះនានា

សាលាខេត្តត្រូវមានទីចាត់ការចំណុះចាំបាច់ដូចជា ទីចាត់ការរដ្ឋបាល ទីចាត់ការគ្រប់គ្រងធនធានមនុស្ស ទីចាត់ការហិរញ្ញវត្ថុ ទីចាត់ការផែនការ និងវិនិយោគ និងទីចាត់ការអន្តរវិស័យ។ ទីចាត់ការនីមួយៗនៃសាលាខេត្តត្រូវមាននាយកទីចាត់ការមួយរូប និងនាយករងទីចាត់ការយ៉ាងច្រើនពីររូបជាជំនួយការ។ ទីចាត់ការនីមួយៗ ត្រូវមានប្រធានការិយាល័យមួយរូប និងអនុប្រធានការិយាល័យយ៉ាងច្រើនពីររូបជាជំនួយការ។ ចំពោះការតែងតាំងនាយកទីចាត់ការ នាយករងទីចាត់ការ ប្រធានការិយាល័យមួយរូប អនុប្រធានការិយាល័យ មន្ត្រី

[៤២] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៤០

[៤៣] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៤២

[៤៤] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៤៤

និងបុគ្គលិកនៃទីចាត់ការនីមួយៗ ត្រូវធ្វើឡើងដោយផ្អែកតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។[៤៥]

ក្រៅពីទីចាត់ការដែលមាន គណៈអភិបាលខេត្តអាចស្នើសុំទៅក្រុមប្រឹក្សាខេត្ត ដើម្បីបង្កើតទីចាត់ការ ឬការិយាល័យបន្ថែមទៀតតាមការចាំបាច់ដូចជា ទីចាត់ការច្រកចេញចូលតែមួយ អង្គភាពលទ្ធកម្ម ការិយាល័យប្រជាពលរដ្ឋ។ ប៉ុន្តែ ទីចាត់ការ ឬការិយាល័យដែលបង្កើតបន្ថែមនោះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយការិយាល័យ ឬទីចាត់ការដែលបានបង្កើតដោយអនុក្រឹត្យនោះទេ។[៤៦]

[៤៥] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៥៥ និងមាត្រា៥៧

[៤៦] អនុក្រឹត្យលេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩, មាត្រា៦០

# ជំពូកទី២
# ការរៀបចំសណ្តាប់ធ្នាប់
# និងសោភ័ណភាពខេត្តកណ្តាល

# ជំពូកទី២
# ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល

## ២.១. បុព្វហេតុនៃការរៀបចំសណ្តាប់ធ្នាប់ខេត្តកណ្តាល

បុព្វហេតុនៃការរៀបចំក្រុងមួយចាំបាច់ត្រូវធ្វើឡើងប្រកបដោយសនិទានកម្ម ពោលគឺមានការគិតគូរហ្មត់ចត់ សព្វគ្រប់ជ្រុងជ្រោយ។ ដូច្នេះ ខេត្តមួយកើតឡើងពុំមែនដោយសារកត្តាចៃដន្យនោះទេពោលគឺកើតឡើងដោយសារមូលហេតុជុំវិញពីក្រោយជាច្រើនដូចជា កំណើនប្រជាជន ភាពក្រីក្រ សន្តិសុខ សណ្តាប់ធ្នាប់ និងការបំពុលទាំង៥ ដែលបានជម្រុញឱ្យមានការយកចិត្តទុកដាក់ និងកែលម្អ។

### ២.១.១. កំណើនប្រជាជន

ជាទូទៅមាននូវសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុង៣សំខាន់ៗ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មីដែលពីមុនមកតំបន់នេះជាទីជនបទប៉ុណ្ណោះ។ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិបានធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ចំណែកកំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋានដីនៃក្រុងថ្មី ដែលពីមុនមកតំបន់នេះជាទីជនបទគ្រាន់តែជាធាតុចូលបន្ទាប់បន្សំប៉ុណ្ណោះ។ ចំនួនប្រជាជនពិភពលោកបានកើនឡើងដល់ចំនួន ៦,១ពាន់លាននាក់ក្នុងពាក់កណ្តាលឆ្នាំ២០០០ ទៅហើយ ដោយឡែកបច្ចុប្បន្ន កំពុងកើនឡើងជាមធ្យមចំនួន ៧,៧លាននាក់ក្នុងមួយឆ្នាំ។ នៅក្នុងឆ្នាំ២០២៥ ខាងមុខចំនួនប្រជាជនពិភពលោកនឹងមានការកើនឡើងខ្លាំងនៅចន្លោះពីចំនួន ៧,៩ ទៅ ១០,៩ពាន់លាននាក់។[៤៧]

បើយើងក្រឡេកមកមើលខេត្តកណ្តាលយើងវិញ អត្រានៃកំណើនប្រជាជនក៏មានការកើនឡើងដែរ។ បើយោងទៅតាមសៀវភៅសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកណ្តាលបានឱ្យដឹងថាគិតត្រឹមត្រីមាសទី៤ ឆ្នាំ២០២២ ខេត្តកណ្តាលមានប្រជាជនប្រមាណ ១ ៣៣០ ៤៣២នាក់ (ស្ត្រី ៦៧៩ ១៨៤ នាក់) ចំណែកឯ របាយការណ៍ស្តីពីផលប៉ះពាល់ដោយសារគ្រោះមហន្តរាយក្នុងខេត្តកណ្តាលប្រចាំឆ្នាំ២០២៣ បានបង្ហាញឱ្យឃើញថា ប្រជាពលរដ្ឋក្នុងខេត្តកណ្តាលមានចំនួនប្រមាណ ១ ៣៤៩ ៨៧៦ នាក់ (ស្ត្រី ៦៨៨ ៩៣៥ នាក់)។ អាស្រ័យតាម របាយការណ៍ទាំងពីរនេះ បានឱ្យយើងឃើញថា ក្នុងរយៈពេលមួយឆ្នាំប្រជាពលរដ្ឋខេត្តកណ្តាលកើនឡើងចំនួន ១៩ ៤៤៤នាក់ (ស្ត្រី ៩៧៥១នាក់)។

[៤៧] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣-២០២៤, ទំព័រទី១៩

### ២.១.២. ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកនៅក្នុងការកំណត់ណាស់ តែជាទូទៅភាពក្រីក្រសំដៅដល់ការ ដែលតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួម ប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាប ដែលពួកគេមិនអាចចាយវាយគ្រប់គ្រាន់ក្នុងជីវភាពប្រចាំថ្ងៃឡើយ។ តម្រូវការរូបកាយ ចំណីអាហារ លំនៅដ្ឋាន ការងារធនធានទឹក អគ្គិសនី អនាម័យសុខមាលភាពសង្គមមានការខ្វះខាត។ លើសពីនេះសិទ្ធិសេរីភាពផ្នែកស្មារតីនិយាយជារួម និងនិយាយដោយឡែកសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតដែរ។ ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាប របស់បុគ្គលមួយរូបៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជា ចំនួននៃករណីឧក្រិដ្ឋកម្ម អំពើហិង្សា តាមរយៈប្រាក់ចំណូលនេះឡើយ ឬអាយុសង្ឃឹមរស់ជាមធ្យមមិនអាចយកមកជំនួសដោយការវាស់ស្ទង់ ដែលជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មតថាជាជនក្រីក្រ។ យ៉ាងហោចណាស់ជាង២០% នៃចំនួនប្រជាជនពិភពលោករស់នៅក្នុងបន្ទាត់នៃភាពក្រីក្រ ហើយ៩០%ក្នុងចំនួននេះកំពុងស្ថិតក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ដូច្នេះ ភាពក្រីក្រជាមូលហេតុមួយ ដែលជម្រុញឱ្យមានការរៀបចំទីក្រុង។[៤៨]

### ២.១.៣. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ជាកត្តាដ៏សំខាន់មួយដែលបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ការរស់នៅរបស់ប្រជាពលរដ្ឋ សន្តិសុខសំដៅដល់សេចក្តីសុខសាន្ត។ ហេតុនេះ សន្តិសុខនិងសណ្តាប់ធ្នាប់ក៏ជាបុព្វហេតុមួយនៃការរៀបសណ្តាប់ និងសោភ័ណភាពផងដែរ។ ដូចនេះ យើងអាចមើលឃើញពីរូបភាពអសន្តិសុខតាមរយៈ៖

- តំបន់ដែលមានចោរកម្ម
- តំបន់ដែលមានចរាចរណ៍គ្រឿងញៀន
- តំបន់ដែលមានក្មេងទំនើងដែលរំខានដល់ប្រជាពលរដ្ឋ
- តំបន់ដែលមានកន្លែងលេងល្បែងស៊ីសង
- ការប្រើអំពើហិង្សា។ល។

ឯសណ្តាប់ធ្នាប់សារធារណៈសំដៅដល់ការមានរបៀបរៀបរយល្អ ការដែលមិនមានភាពរញ៉េរញ៉ៃ។ យើងអាចដឹងពីភាពគ្មានសណ្តាប់ធ្នាប់ដែលបានកើតឡើងបានតាមរូបភាពដូចជា៖

- ការលក់ដូរលើចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើង គ្មានរបៀបរៀបរយល្អ

[៤៨] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣-២០២៤, ទំព័រទី១៩

- ការចតយានជំនិះគ្មានសណ្តាប់ធ្នាប់
- ការធ្វើដំណើរតាមដងផ្លូវមិនគោរពតាមច្បាប់ចរាចរណ៍ផ្លូវគោក ជិះបញ្ច្រាស់
- ការចោលសំរាមផ្តេសផ្តាស
- ការចតរ៉ឺម៉ក ផាស្អាប ( Pass App ) ដែលបង្កការកកស្ទះចរាចរណ៍
- ការលក់ដូរលើសួនច្បារសាធារណៈ
- ការដែលគ្មានបន្ទប់ទឹកសាធារណៈនាំឱ្យបន្ទោរបង់ពាសវាលពាសកាល។

ហេតុនេះ សន្តិសុខ និងសណ្តាប់ធ្នាប់ក៏ជាកត្តាដ៏សំខាន់មួយសម្រាប់ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពផងដែរ ដើម្បីឱ្យខេត្តកណ្តាលមានសណ្តាប់ធ្នាប់ និងសោភ័ណភាពល្អឈានទៅរកខេត្តដែលអភិវឌ្ឍន៍។

យោងតាមគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀត មានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់ការរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីយើងមានសន្តិភាព ស្ថិរភាពយ៉ាងរឹងមាំ ប៉ុន្តែ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បញ្ហាសុខមាលភាពរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាចាំបាច់នានា នៅតែជាបញ្ហាអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឱ្យជនគ្រប់រូប និងសង្គមទាំងមូល មានសុវត្ថិភាពយ៉ាងល្អប្រសើរ ជីវភាពរុងរឿង និងសុខដុមរមនា។

លក្ខណៈសម្បត្តិរបស់ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពមានដូចជា៖

- ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត
- គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ
- មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍
- គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រី និងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង
- ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព
- មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ

➢ ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយនិងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព។[៤៩]

### ២.១.៤. ការបំពុលនានា

នៅប្រទេសកម្ពុជា កំណើនប្រជាជន និងការរីកចម្រើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស កំពុងបង្កឱ្យមានការបំពុលបរិស្ថាន។ សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច បានបង្កើតជាផលវិបាកផ្នែកបរិស្ថានសំខាន់ៗ រួមទាំងការបំពុលខ្យល់ ការបំពុលទឹក ការបំពុលសំឡេង និងបញ្ហាសំណល់រឹង។

#### ២.១.៤.១. ការបំពុលដី

ការបំពុលដី គឺជាកាធ្វើឱ្យដីខូចបាត់បង់ជីវជាតិបណ្ដាលឱ្យមនុស្ស សត្វ និងរុក្ខជាតិពិបាកនឹងរស់រានមានជីវិត ឬក៏ឈានទៅដល់ការបាត់បង់ជីវិតក៏មានដែរ។ ឧស្សាហកម្ម គឺជាវិស័យមួយដ៏សំខាន់ក្នុង ចំណោមវិស័យដទៃទៀតចំពោះសេដ្ឋកិច្ចកម្ពុជា។ ទោះជាយ៉ាងនេះក្ដី ក្រុមអ្នកបរិស្ថានបានបង្ហាញថា សកម្មភាពឧស្សាហកម្មចម្បង ០៤ ដែលបណ្ដាលឱ្យមានការបំពុលបរិស្ថានមានដូចជា ឧស្សាហកម្មកាត់ដេរ ឡឥដ្ឋ រោងម៉ាស៊ីនកិនស្រូវ និងឧស្សាហកម្មកែច្នៃកៅស៊ូ។

នៅក្នុងខេត្តកណ្ដាលបានជួបនូវបញ្ហាបរិស្ថានចម្បងគឺ ការចោល និងការគ្រប់គ្រងសំណល់រឹង។ ការបញ្ចេញសំណល់ មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងកំណើនប្រជាជន ដែលវានាំឱ្យមានការព្រួយបារម្ភពីបញ្ហាបរិស្ថាន និងសុខភាពមនុស្ស។ ដោយសារកង្វះខាតនៃការអនុវត្តការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវ ការយល់ដឹងជាសាធារណៈនៅមានកម្រិតបញ្ហាសំណល់រឹងនៅតែជាសម្ពាធបរិស្ថានមួយដ៏ធំមួយ។ មូលហេតុនៃការបំពុលដីមានៈ

➢ ការបំពុលដោយឧស្សាហកម្ម ដោយសារតែឧស្សាហកម្ម ជាកន្លែងដែលបញ្ចេញថាមពលច្រើន និងមានផ្ទុកសារធាតុគីមីការបំពុលដោយសំណល់អាចបង្កគ្រោះថ្នាក់ដល់សតិបញ្ញារបស់កុមារ និងធ្វើឱ្យការលូតលាស់យឺតជាងធម្មតា។ សហគ្រាសធនធំក្នុងខេត្តកណ្ដាលឆ្នាំ២០២២ សរុបទាំងអស់មាន ៣០៥មូលដ្ឋានក្នុងនោះមាន ផ្នែកវាយនភ័ណ្ឌ ១៣មូលដ្ឋាន ផ្នែកសម្លៀកបំពាក់ ១៤២មូលដ្ឋាន ផ្នែកផលិតផលស្បែកចំនួន ៥៤មូលដ្ឋាន ផ្នែកផ្សេងៗទៀត ៩៦មូលដ្ឋាន។ ចំពោះសហគ្រាសធុនតូច-មធ្យម និងសិប្បកម្មដែលសុំប្រកាសពីក្រសួងមាន បង្កើតថ្មី ០៦មូលដ្ឋាន ស្នើសុំវិញ្ញាបនបត្រដំណើរការ

[៤៩] គោលនយោបាយ ស្ដីពី ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព, លេខ ០១ គនប, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២១

០១មូលដ្ឋាន និងឈប់ដំណើរការថ្មី ០២មូលដ្ឋាន (សិប្បកម្មទឹកពិសាដប ០១មូលដ្ឋាន សិប្បកម្មកែច្នៃស្បែកគោ ០១មូលដ្ឋាន)។[៥០]

- ការបំពុលដោយកសិកម្ម កសិកម្មក្នុងខេត្តកណ្ដាលជាវិស័យសេដ្ឋកិច្ចស្នូលរបស់ខេត្ត។ ដើម្បីធ្វើស្រែចំការ ដាំដំណាំ បន្លែផ្លែឈើឱ្យទទួលបានផ្លែផ្កាល្អកសិករត្រូវការប្រើថ្នាំគីមី សម្លាប់សត្វល្អិតចង្រៃដូចជាដង្កូវ និងសត្វល្អិតជាដើម។ (ការប្រើជី និងថ្នាំសម្លាប់សត្វល្អិតជាកត្តាដែលបំពុលបរិស្ថានយ៉ាងធ្ងន់ធ្ងរ កសិដ្ឋានចិញ្ចឹមសត្វជ្រូកបង្កើតឱ្យមានលាមក និងទឹកនោមដែលបញ្ចេញនូវឧស្ម័នពុលទៅក្នុងខ្យល់ ហើយជ្រាបចូលក្នុងដីបំពុលទឹកផងដែរ)។ ការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្ម គោ ០៤កន្លែង ចំនួន ៤៩២ក្បាល ជ្រូកសរុប ១៣កន្លែង ចំនួន ១៤ ០៥៥ក្បាល ពពែ ០១កន្លែង ចំនួន ៩០០ក្បាល មាន់ ២៩កន្លែង សរុប ៥៧០ ០០០ក្បាល។ ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ គោ ៤៧ ៤៩២ក្បាល ក្របី ២ ៥១៥ក្បាល សេះ ១៣០ក្បាល ចៀម ៤៤៦ក្បាល ពពែ ៣ ៥០១ក្បាល ជ្រូក ១៧ ០០០ក្បាល ស្វា ៩ក្បាល ទន្សាយ ៥៧ក្បាល ឆ្កែ ៥៧ ៩៥២ក្បាល ឆ្មា ៨ ៨២៦ក្បាល មាន់ ១ ១៣៤ ២០៥ក្បាល ទា ៣១៨ ៣៩៧ក្បាល កប្បីផ្សេងៗ ៧ ០៣១ក្បាល។[៥១]
- ការបំពុលដោយវិទ្យុសកម្ម ខេត្តកណ្ដាលមានក្រុមហ៊ុនផ្គត់ផ្គង់ និងចែកចាយអគ្គីសនី (រដ្ឋ និងឯកជន) ចំនួន ៦២ក្រុមហ៊ុន។ បច្ចុប្បន្នទូទាំងខេត្តកណ្ដាលមាន ការវិនិយោគពីសំណាក់រដ្ឋ និងឯកជនដែលទទួលបានអាជ្ញាបណ្ណពីអាជ្ញាធរអគ្គិសនីកម្ពុជាឱ្យបញ្ជូន និងចែកចាយអគ្គិសនីមានចំនួន ៦៥អាជ្ញាបណ្ណបានគ្របដណ្ដប់លើភូមិចំនួន ១ ០១០ភូមិ។[៥២]
- ការបំពុលដោយសំណល់ផ្សេងៗ ការបោះចោលសំណល់ដូចជា ថង់ប្លាស្ទិក កាតុង ក្រដាស កែវ សំណល់ សរីរាង្គ សំបកដប សំបកកង់ឡាន សំបកកង់ម៉ូតូ វត្ថុទាំងអស់នេះមិនងាយរលាយទៅក្នុងធម្មជាតិទេទោះជារលាយក៏មានរយៈពេលយូរដែរធ្វើឱ្យបរិស្ថានមិនស្រស់ស្រាយ។ មិនតែប៉ុណ្ណោះ ការបោះចោលសំរាមពាសវាលពាសកាលនាំឱ្យស្ទះលូ និងត្រីងាប់ផងដែរ។ ប៉ុន្តែ ប្រសិនបើយើងទាំងអស់គ្នាធ្វើឱ្យមានការធ្លាក់ចុះនូវការបំពុលដីយើងនៅតែមានពេលវេលា និងឱកាសដើម្បីកែខ្លួន។
- ការបោះចោលសំរាមផ្ដេសផ្ដាសជាកត្តាមួយដ៏ចម្បង។ សព្វថ្ងៃនេះ បរិស្ថានយើងកំពុងរងគ្រោះនូវការបំផ្លាញយ៉ាងខ្លាំងក្លាពីមនុស្ស សត្វ និងគ្រោះធម្មជាតិ។ មនុស្សយើងពុំបានដឹងថាយើងកំពុងតែបំផ្លាញ

[៥០] សៀវភៅ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកណ្ដាល, ទំព័រទី៦៨

[៥១] សៀវភៅ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកណ្ដាល, ទំព័រទី៦៣

[៥២] សៀវភៅ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកណ្ដាល, ទំព័រទី៧០

បរិស្ថានម្តងតិចៗនោះទេ។ ការបំពុលដីដែលធ្វើឱ្យបង្កគ្រោះថ្នាក់ដល់ប្រពន្ធ័អេកូឡូស៊ីទាំងមូល ឬចំណែកណាមួយ។ មនុស្សយើងតែងចោលសំរាមមិនត្រូវនឹងកន្លែងដែលត្រូវបោះចោល។[៥៣]

### ២.១.៤.២. ការបំពុលទឹក

ជាទូទៅ ការបំពុលទឹកគឺជាការធ្វើឱ្យកង្វក់ដល់ទឹកនៅពេលដែលសារធាតុបំពុលនានាបានហូរចូលទៅក្នុងប្រភពទឹកដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តកម្ម (ការដកយកសារធាតុបំពុលចេញ)។

ការបំពុលទឹក អាចត្រូវបានបង្កឡើងតាមរយៈវិធីមួយចំនួនដូចខាងក្រោម៖

- ការធ្វើអាជីវកម្មរ៉ែ
- ការបូមយកខ្សាច់
- ការបំពុលសរីរាង្គ គឺមានទំហំធំខ្លាំងណាស់ព្រោះវាត្រូវបានរួមបញ្ចូលទាំងកាកសំណល់ពីការប្រើប្រាស់ដីសម្រាមក្រដាស និងកាកសំណល់សរីរាង្គផ្សេងៗ។ កាកសំណល់ទាំងអស់នេះហើយដែលបង្កឱ្យមានការបំពុលទឹក
- ការចាក់ចោលនូវសំណល់រាវពីលំនៅដ្ឋានចូលទៅក្នុងប្រព័ន្ធផ្លូវទឹក គឺបានធ្វើឱ្យគុណភាពទឹកលើដី និងទឹក ក្រោមដីដែលស្ថិតនៅក្បែរទីក្រុងបានថយចុះជាលំដាប់។ ហើយដើមហេតុដែលធ្វើឱ្យមានបញ្ហានៃការចាក់ចោលសំណល់រាវមានដូចជា រោងចក្រតម្បាញ រោងចក្រក្រដាស រោងចក្រគីមី និងរោងចក្រផលិតម្ហូបអាហារជាដើម
- ប្រជាជនដែលរស់នៅតាមទីជនបទបន្ទោរបង់នៅតាមទីវាល ឬបន្ទោរបង់ចូលទៅក្នុងទឹកដែលបណ្តាលឱ្យមានការបំពុលដល់ប្រភពទឹក
- ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងជីគីមីក្នុងវិស័យកសិកម្ម
- សំណឹកដី កើតមានឡើងក្នុងពេលលើកដី និងឈូសឆាយដីនៅតាមច្រាំង ឬប្រព័ន្ធស្រោចស្រពដំណាំដែលមានស្រាប់។ សំណឹកដីនឹងបណ្តាលឱ្យទឹកបាត់បង់គុណភាព និងប៉ះពាល់ដល់ជីវៈចម្រុះដែលរស់នៅក្នុងទឹក
- ការបំពុលទឹក បណ្តាលមកពីសកម្មភាពរបស់ផ្សេងៗរបស់មនុស្សដូចជា ការបោះចោលសំណល់រឹង ការចាក់ ឬបង្ហូរសំណល់រាវ និងសំណល់ផ្សេងៗពីរោងចក្រចូលទៅក្នុងប្រភពទឹកដូចជា ស្រះ ត្រពាំង ស្ទឹង បឹង និងទន្លេជាដើម

[៥៣] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣-២០២៤, ទំព័រទី២៦

- ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនិងជីគីមីក្នុងវិស័យកសិកម្ម ការប្រើប្រាស់ជីគីមីបានធ្វើឱ្យមានផលប៉ះពាល់គុណភាពទឹកផងដែរ។ ឧទាហរណ៍ នៅពេលដែលប្រជាកសិករប្រើប្រាស់ជីគីមីទៅលើដំណាំ នោះសារធាតុគីមីដែលមាននៅក្នុងជីនឹងហូរទៅតាមទឹកចាក់ទៅក្នុងបឹង ស្ទឹង ឬទន្លេធ្វើឱ្យប៉ះពាល់ទៅដល់សត្វមានជីវិតដែលរស់នៅក្នុងទឹក។ សារធាតុពុល និងជាតិគីមីនឹងធ្វើឱ្យជីវៈចម្រុះត្រូវបាត់បង់ធ្វើឱ្យទឹកត្រូវបាត់បង់គុណភាពមិនអាចឱ្យប្រជាជនបរិភោគ និងប្រើប្រាស់បាន។

យោងតាមរបាយការណ៍បូកសរុបលទ្ធផលការងារបរិស្ថាន គ.ស ២០១៧ ទិសដៅ គ.ស ២០១៨ ការបំពុលទឹកដោយសារការបង្ហូរចេញពីរោងចក្រនៅក្នុងប្រទេសកម្ពុជា មានប្រភពមកពី៖

- រោងចក្រភាគច្រើនមានត្រឹមអាងស្តុក ដោយមិនដឹងច្បាស់ថាជាអាងចម្រោះ (សិបទិក) ឬអត់
- រោងចក្រមួយចំនួនបានលួចបង្ហូរសំណល់រាវដោយផ្ទាល់ចូលទៅក្នុងលូ
- រោងចក្របោកគក់សម្អាតសម្លៀកបំពាក់ជ្រលក់ពណ៌ និងបោះពុម្ពមួយចំនួនគ្មានខ្សែសង្វាក់ផលិតកម្មអាងប្រព្រឹត្តកម្មសំណល់រាវទេគ្រាន់តែបង្ហូរចូលស្រះស្តុកទុករួចបូមចេញបង្ហូរចូលលូ។ រីឯ រោងចក្រមួយចំនួនទៀតមានខ្សែសង្វាក់ផលិតកម្មអាងប្រព្រឹត្តកម្មសំណល់រាវតែពុំបានផ្អែកលើលក្ខណៈបច្ចេកទេសសមស្របឱ្យឆ្លើយតបទៅនឹងស្តង់ដារដែលបានកំណត់ ព្រមទាំងមិនមានវិស្វករជំនាញទទួលខុសត្រូវរាល់ដំណើរការ អាងប្រព្រឹត្តកម្មសំណល់រាវច្បាស់លាស់។[៥៤]

### ២.១.៤.៣. ការបំពុលដោយសំណល់រឹង រាវ

សំណល់រឹង គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល របស់កម្ទេចកំទីដែលលែងត្រូវការប្រើប្រាស់ ហើយត្រូវបានគេបោះបង់ចោលមានបំណងនឹងបោះបង់ចោល ឬតម្រូវឱ្យបោះបង់ចោល។ នៅក្នុងចំណុចសំណល់រឹងជាចំណុចសំខាន់ក្នុងការសិក្សាដើម្បីធ្វើឱ្យទីក្រុងមានសោភណ្ឌភាព។ សំណល់រឹងចែកចេញជាពីរប្រភេទគឺ៖

- **សំរាម** គឺជាផ្នែកមួយនៃសំណលីរឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅស្ថាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹក ជញ្ជូន កន្លែងកំសាន្ត។ល។
- **សំណល់ប្រកបដោយគ្រោះថ្នាក់** គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កឱ្យមានជំងឺមហារីក ចំលងជំងឺ ធ្វើឱ្យរលាក ធ្វើអុកស៊ីតកម្ម ឬសារធាតុគីមីដទៃទៀត ដែលអាចនាំឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ សំណល់

[៥៤] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣-២០២៤, ទំព័រទី៤៩

ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម សេវាកម្ម និងអាជីវកម្មរ៉ែ។ ប្រភេទសំណល់ប្រកដោយគ្រោះថ្នាក់មានចែងក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៣៦ អ.ន.ក្រ.បក, ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៩។

សំណល់រាវ គឺជាវត្ថុរាវ ដែលជាផលិតផល និងជាសារធាតុរួមផ្សំជាមួយនឹងសារធាតុរឹងខ្លះ ដែលត្រូវបានគេបញ្ចេញចោលជាប្រចាំទៅតាមបណ្តាញប្រព័ន្ធលូទឹកស្អុយផ្សេងៗ។ អត្ថន័យមួយទៀត គឺសំដៅទៅលើវត្ថុរាវដែលបញ្ចេញពីប្រភពបំពុលចូលទៅក្នុងទឹកសាធារណៈ ឬក៏ចូលទៅក្នុងបណ្តាញលូសាធារណៈទោះបានធ្វើប្រព្រឹត្តកម្ម ឬមិនបានធ្វើប្រព្រឹត្តកម្មក្តី។ មូលហេតុដែលនាំឱ្យមានកាកសំណល់រឹង រាវមានដូចជា៖

**ក. កាកសំណល់រឹង**

សព្វថ្ងៃកំណើនចំនួនប្រជាជនកើនឡើងយ៉ាងខ្លាំងនៅលើសកលលោកតម្រូវការជីវភាពរស់នៅមានការកើនឡើង និងសម្បូរបែប ការរីកដុះដាលនៃនគរូបនីយកម្ម និងសំណង់ ការរីកចម្រើនខាងវិស័យឧស្សាហកម្ម និងកសិកម្មជាដើមហេតុដែលនាំឱ្យមានកាកសំណល់ជាច្រើនសន្ធឹកសន្ធាប់ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍។ កាកសំណល់រឹងមានប្រភពមកពីច្រើនកន្លែង តែយើងលើកឡើងតែប្រភពធំៗដូចខាងក្រោម៖

- **សំណល់ផ្ទះបាយ** សំណល់ផ្ទះបាយភាគច្រើនជាសំណល់សើមដូចជា បាយ ត្រី សាច់ បន្លែ ផ្លែឈើ និងសំណល់ផ្សេងៗដែលទ្រទ្រង់គ្រឿងឧបភោគបរិភោគ។ សំណល់នេះមានប្រភពមកពី ភោជនីយដ្ឋាន លំនៅដ្ឋាន អាហារដ្ឋាន តំបន់ ទេសចរណ៍ បៀរហ្គាឌិនជាដើម។ កាកសំណង់ផ្ទះបាយជាកាកសំណល់មានក្លិនស្អុយ ហើយអាចបំបែកភាគល្អិតសរីរាង្គលឿន។
- **រោងចក្រ និងសិប្បកម្ម** សំណល់ចេញពីរោងចក្រ និងសិប្បកម្មជាសំណល់ដែលសល់ពីផលិតកម្ម ហើយភាគច្រើនជាសំណល់ប្រកបដោយគ្រោះថ្នាក់មានដូចជា សរសៃអំបោះ កម្ទេចក្រណាត់ សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡឧស្សាហកម្ម។
- **មន្ទីរពេទ្យ** ជាសំណល់ស្ងួតដូចជា សម្ភារៈរុំរបួស ស៊ីរ៉ែន ប្លាស្ទិក អាលុយមីញ៉ូម បរិក្ខាពេទ្យផ្សេងទៀត សំណល់ប្រភេទនេះមិនសូវមានគ្រោះថ្នាក់ ប៉ុន្តែផ្ទុកទៅដោយមេរោគជាច្រើនប្រភេទ។
- **អគារពាណិជ្ជកម្ម** អគារពាណិជ្ជកម្មភាគច្រើនជាការិយាល័យតំណាងក្រុមហ៊ុនផ្សេងៗ សំណល់ទាំងនោះហើយជាសំណល់ស្ងួត មិនមានគ្រោះថ្នាក់ ឬផ្ទុកមេរោគឡើយដូចជាក្រដាស សម្ភារៈការិយាល័យ ឧបករណ៍អេឡិចត្រូនិចជាដើម។
- **សំណល់ពីសំណង់** ប្រទេសកំពុងអភិវឌ្ឍន៍ កំពុងជួបប្រឈមជាខ្លាំងចំពោះសំណង់ប្រភេទនេះ ព្រោះវាមានការរីកដុះដាលនៃសំណង់មួយថ្ងៃច្រើនជាងមួយថ្ងៃ។ ឧទាហរណ៍ នៅក្នុងខេត្តកណ្តាលមាន

សំណង់កំពុងរីកដុះដាលគ្រប់ទីកន្លែង ហើយវាបង្កឱ្យមានការហុយដី សម្លេងរំខាន កកស្ទះចរាចរណ៍ ជាដើម។ សំណង់ នេះមានដូចជា ដែក ស៊ីម៉ង់ ថង់ប្លាស្ទិកថ្នាំពណ៌ជាដើម។ (ការសិក្សាពីប្រភព និង មូលហេតុនៃសំណល់រឹងនេះ គឺមានអត្ថប្រយោជន៍ណាស់ក្នុងការវិភាគ វាយតម្លៃ បែងចែក ឈានដល់ ការគ្រប់គ្រង និងដំណោះស្រាយឱ្យបានប្រសិទ្ធភាព។ មុនឈានទៅដល់ដំណោះស្រាយ គឺយើងត្រូវ សិក្សារទៅលើគុណវិបត្តិដែលកើតឡើងពីសំណល់រឹងនេះ)។[៥៥]

**ខ. កាកសំណល់រាវ**

កាកសំណល់រាវ បានបង្ហាញរូបរាងពីសកម្មភាពផ្សេងៗដូចជា កាកសំណល់ពីរោងចក្រ សិប្បកម្ម ភោជនីយដ្ឋាន ជាពិសេសប្រជាពលរដ្ឋដែលមានលំនៅដ្ឋាននៅតាមដងទន្លេ បានទំលាក់កាកសំណល់រាវចូល ក្នុងទន្លេជាហេតុធ្វើឱ្យទឹកទន្លេរទទួលការបបំពុល និងបានបង្កគុណវិបត្តិជាច្រើនដល់ជីវិតសត្វក្នុងទឹក និង មនុស្ស។[៥៦]

### ២.១.៤.៤. ការបំពុលសំឡេង

សំឡេង គឺមានតួនាទីនៅក្នុងជីវិតមនុស្សជារៀងរាល់ថ្ងៃ។ ប្រភពនៃសំឡេងអាចមានដូចជា ការ និយាយ សម្លេងសត្វផ្សេងៗទៀត។ នៅពេលដែលមានសំឡេងដែលមិនត្រូវការ ហើយប៉ះពាល់ដល់សកម្មភាព ធម្មតាវា គឺការបំពុលដោយសំឡេង។ មនុស្សយើងមិនសូវទទួលស្គាល់សំឡេងជាការបំពុលទេដោយសារយើង មិនអាចឃើញ ឬធុំក្លិនវាដូចជាការបំពុលទឹក ការបំពុលដី និងការបំពុលខ្យល់។

មូលហេតុទីមួយដែលបង្កឱ្យបំពុលសំឡេងគឺការដ្ឋាន។ នៅទីកន្លែងសាងសង់ សំឡេងគឺភាគច្រើន ចេញមក ពីម៉ាស៊ីនធំៗដូចជា ម៉ាស៊ីនឈូសដី និងម៉ាស៊ីនលាយបេតុង។ សំឡេងពីឧបករណ៍បច្ចេកវិទ្យា គឺជា មូលហេតុទីពីរដែលបំពុលបរិស្ថាន។ សំឡេងនេះ គឺអាចមកពីម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបោកខោអាវ ម៉ាស៊ីនភ្លើង ម៉ាស៊ីនបូមសំរាម ទូរទស្សន៍។ល។ ឯសម្រាប់មូលហេតុទីបីវិញ គឺសំឡេងចរាចរណ៍ ដែលកើតឡើងនៅពេល ដែលមានរថយន្តច្រើនដូចជាសំឡេងពីឡាន ម៉ូតូ ឡានក្រុង រថភ្លើង និងរថយន្តផ្សេងៗទៀត។ នេះជាមូល ហេតុសំខាន់ដែលបង្កឱ្យមានការបំពុលសំឡេងពីព្រោះវារំខានដល់មនុស្សជាច្រើន។ សំឡេងដែលមកពីកម្មវិធី បុណ្យ ពិធីរៀបការ ពិធីខួបកំណើត និងពិធីជប់លៀងគឺជាមូលហេតុចុងក្រោយដែលបង្កឱ្យមានការបំពុល ដោយសំឡេង។ នាពេលបច្ចុប្បន្ននេះមានកត្តាជាច្រើនដែលបណ្តាលឱ្យមានការរំខានដោយសំឡេង។ កត្តា ទាំងនោះមានដូចជា៖

[៥៥] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣-២០២៤, ទំព័រទី៣៣

[៥៦] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣-២០២៤, ទំព័រទី៣៤

- ការប្រើប្រាស់នូវម៉ាស៊ីនភ្លើង
- ការប្រើប្រាស់នូវយានយន្តជជុះ ដែលមានសំឡេងលាន់ឮខ្លាំង
- ការប្រើប្រាស់នូវគ្រឿងចក្រ គ្រឿងយន្តដូចជា ត្រាក់ទ័រ រថយន្តសម្រាប់ដឹកជញ្ជូនសម្ភារៈ ឧបករណ៍ គ្រឿងចក្រសម្រាប់កិនបង្ហាប់ និងគ្រឿងចក្រធុន់ៗផ្សេងៗទៀត នៅតាមការដ្ឋានសាងសង់
- សំឡេងចេញពីក្លឹបកំសាន្ត ខារ៉ាអូខេ ដែលមិនបានបំពាក់នូវឧបករណ៍ទប់សំឡេង៖
  - ការបើកនូវសំឡេងទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ធុងបាស់ លាន់ឮសំឡេងខ្លាំង
  - សំឡេងចេញពីយន្តហោះ រថភ្លើង។
- សំឡេងចេញពីរោងចក្រ៖
  - ការប្រើប្រាស់នូវឧបករណ៍បំពងសំឡេងគ្រប់ប្រភេទជាដើម។[៥៧]

### ២.១.៤.៥. ការបំពុលខ្យល់

ការបំពុលនេះកើតចេញពីសកម្មភាពប្រចាំថ្ងៃរបស់មនុស្សដែលរស់នៅទីក្រុងដូចជា ផ្សែងដែលចេញពីយានយន្តគ្រប់ប្រភេទ ការបូជាសព ផ្សែងចេញពីរោងចក្រសហគ្រាស សិប្បកម្ម អាហារដ្ឋាន។ល។ មួយទៀត ធូលីដីដែលនៅលើដងមហាវិថីនានាក្នុងទីក្រុង។ សំណួរមួយចោទសួរថា តើធូលីដីទាំងនោះមកពីណា និងត្រូវដោះស្រាយបែបណាទាំងនេះជាចំណុចសំខាន់ដែលត្រូវដោះស្រាយ។ មួយទៀត ការបំពុលខ្យល់ក៏បានកើតឡើងដោយកត្តាធម្មជាតិផងដែរដូចជាខ្យល់ព្យុះ ភ្លៀងអាស៊ីតជាដើម។

យោងតាមអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង មាត្រា៣ បានចែកចេញប្រភពបំពុលខ្យល់ជាពីរគឺ ប្រភពចល័ត និងប្រភពអចល័ត។ ប្រភពចល័ត គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទិ៍មានដូចជា យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្តជាដើម។ ប្រភពអចល័ត គឺជាប្រភពដែលស្ថិតនៅលើទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មានដូចជា រោងចក្រសហគ្រាស ឃ្លាំងស្តុកសម្ភារៈ ការដ្ឋានសំណង់ ឡដុតសម្រាម សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទក្នុងនោះផងដែរ គេបែងចែកប្រភេទនៃប្រភពបំពុលជាបីប្រភេទ៖

- ប្រភពចំណុច ( Point Source ) មានដូចជា បំពង់ផ្សែងរោងចក្រដែលគេអាចកំណត់រក និងធ្វើការត្រួតពិនិត្យបានយ៉ាងងាយស្រួល។ ចំពោះទិសដៅនៃការសាយភាយគេអាចទស្សន៍ទាយទុកមុនបានដោយមើលទៅលើទិសដៅខ្យល់បក់។

[៥៧] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣-២០២៤, ទំព័រទី៤៣

- ប្រភពខ្សែ ( Line Source ) មានដូចជា ផ្លូវថ្នល់សម្រាប់ធ្វើចរាចរណ៍ធំៗជាដើម ដែលពិបាកក្នុងការវាស់ស្ទង់ និងត្រួតពិនិត្យណាស់ហើយការសាយភាយនៃសារធាតុបំពុលក៏មានការពិបាកទស្សន៍ទាយជាងប្រភពចំណុច។
- ប្រភពផ្ទៃ ( Area Source ) គឺជាសំណុំនៃប្រភពសារធាតុបំពុលតូចៗច្រើនដូចជា ឧស្សាហកម្មតូចៗ ហើយមានការពិបាកយ៉ាងខ្លាំងក្នុងការត្រួតពិនិត្យ។

ទិដ្ឋភាពជាក់ស្តែងដែលបានកើតឡើងក្នុងតំបន់ខេត្តកណ្តាល បានបង្កអោយមានមូលហេតុការកើនឡើងនៃការបំពុលខ្យល់មានដូចខាងក្រោម៖

- កំណើនចរាចរណ៍តាមផ្លូវ
- ចលនាយានយន្តតាមផ្លូវមានលក្ខណៈ “ ឈប់ និងទៅ ”
- រថយន្ត និងទោចក្រយានយន្តចាស់ៗ ហើយពុំមានការថែទាំបានល្អ
- ការប្រើប្រាស់ឥន្ធនៈមិនស្អាត ( ដូចជាសាំងដែលមានបន្ថែមជាតិសំណ )
- ការប្រើប្រាស់គ្រឿងចក្រហួសសម័យក្នុងឧស្សាហកម្ម
- កំណើនការប្រើប្រាស់ថាមពល និងការប្រើប្រាស់ម៉ាស៊ីនភ្លើង ដែលគ្មានប្រសិទ្ធិភាពសម្រាប់ផលិតអគ្គិសនី
- គ្មានការបែងចែងតំបន់ឧស្សាហកម្មច្បាស់លាស់ ដែលជាហេតុធ្វើឱ្យមានផ្សែងពុលដែលចេញពីរោងចក្រឧស្សាហកម្មនានា
- ចំហេះឥន្ធនៈផូស៊ីលនៅក្នុងរថយន្ត ទោចក្រយានយន្ត រោងចក្រ យន្តហោះ
- ការដុតអុស លាមកសត្វ និងសំណល់ពីដំណាំ សម្រាប់ដាំស្ល បំភ្លឺ ឬយកកម្តៅ
- ការដុតព្រៃឈើ និងវាលស្មៅនៅតំបន់ត្រូពិច ដើម្បីរានដីយកដំណាំ
- ការចិញ្ចឹមសត្វ
- ការប្រើប្រាស់ជីគីមី ការបាញ់ថ្នាំគីមីទៅលើដំណាំក៏អាចធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងទៅលើខ្យល់ ព្រមទាំងបរិយាកាស ព្រោះការបំភាយសារធាតុគីមីអាចមានប្រតិកម្មជាមួយអុកស៊ីសែនដែលជាតម្រូវការចាំបាច់សម្រាប់ជីវិតមនុស្សនិងសត្វ។ ក្នុងករណីដែលមានប្រតិកម្មរវាងសារធាតុគីមីដែលមាននៅក្នុងជីគីមី និងអុកស៊ីសែននោះនឹងធ្វើឱ្យសារធាតុអុកស៊ីសែនក្នុងបរិយាកាសថយចុះ និងប្រែប្រួល។ រីឯខ្យល់ត្រូវបានទទួលរងការបំពុល ហើយថែមទាំងធ្វើឱ្យប៉ះពាល់ដល់ស្រទាប់អូហ្សូនថែមទៀតផង។[៥៩]

[៥៩] សៀវភៅ នីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា, បោះពុម្ពឆ្នាំ២០២៣-២០២៤, ទំព័រទី៤៧

## ២.២. ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល

### ២.២.១. ការរៀបចំសណ្តាប់ធ្នាប់

#### ២.២.១.១. ការរៀបចំសន្តិសុខ

ដើម្បីឱ្យខេត្តមួយមាននូវសណ្តាប់ល្អ លុះត្រាតែខេត្តឬតំបន់នោះមាននូវការរៀបចំសុវត្ថិភាពសន្តិសុខរបៀបរៀបរយ គ្មានភាពអនាធិបតេយ្យ។ល។ ហេតុនេះ ដើម្បីឱ្យខេត្តមានណ្តាប់ធ្នាប់ អាជ្ញាធរមានសមត្ថកិច្ចបានខិតខំរៀបចំ និងលាងសម្អាតនូវសកម្មភាពដែលបំផ្លាញសណ្តាប់ធ្នាប់ខេត្តកណ្តាល ស្របតាមគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពឱ្យដល់ប្រជាពលរដ្ឋក្នុងការរស់នៅប្រកបដោយសន្តិសុខទាំងផ្លូវកាយ និងចិត្ត។

យោងតាមសៀវភៅ នីតិនគរូបនីយវិទ្យារបស់បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣-២០២៤ សណ្តាប់ធ្នាប់មានធាតុផ្សំចំនួនបីគឺ សន្តិសុខ ភាពស្ងប់ស្ងៀម និងគ្មានការបំពុល។

**ក. សុវត្ថិភាពបុគ្គល**

យោងទៅតាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត សុវត្ថិភាព សំដៅដល់ការមានសួស្តី ការប្រកបដោយសេចក្តីសុខ។ ហេតុនេះ សុវត្ថិភាពបុគ្គល សំដៅដល់ កិច្ចការពារអាយុជីវិតពីរដ្ឋដោយរដ្ឋត្រូវមានច្បាប់ការពារ និងត្រូវមានអាជ្ញាធរសម្រាប់ជួយការពារប្រជាពលរដ្ឋប្រកបដោយសុវត្ថិភាព។ តម្រូវការរបស់ប្រជាពលរដ្ឋដែលចាំបាច់ទីមួយនោះគឺ សុវត្ថិភាពបុគ្គល ដែលជាការផ្តល់ឱ្យការរស់នៅរបស់ប្រជាជនរស់នៅដោយមានសេចក្តីសុខមិនទទួលរងការគំរាមគំហែងពីអ្នកដទៃ ឬជនមានអំណាចជីវិតដែលរស់នៅប្រកបដោយសន្តិភាពមិនមានការកាប់សម្លាប់ ប្រមាថជីវិត ឬការមើលងាយ ពិសេសនោះគឺការការប្រើអំពើហិង្សា និងការជួញដូរមនុស្សនិងផ្លូវភេទនោះឡើយ។ ដូចនេះ ដើម្បីធានាដល់សុវត្ថិភាពបុគ្គលរបស់ប្រជាពលរដ្ឋ អាជ្ញាធរខេត្តកណ្តាលបានយកចិត្តទុកដាក់ជាខ្លាំង និងបានអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាពគឺភូមិ-ឃុំ-សង្កាត់ត្រូវមានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍ គ្មានសំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។[៥៩]

បន្ថែមពីនេះ កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ថ្នាក់ដឹកនាំខេត្ត ឯកឧត្តម គង់ សោភ័ណ្ឌ បានចូលរួមកិច្ចប្រជុំស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅទីស្តីការក្រសួង

[៥៩] គោលនយោបាយ ស្តីពី ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព, លេខ០១ គនប, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២១

មហាផ្ទៃ។[៦០] លើសពីនេះទៅទៀត ក្នុងកិច្ចប្រជុំស្ដីពីការរៀបចំវិធានការបង្ក្រាបបទល្មើសគ្រឿងញៀន និងក្មេងទំនើងក្នុងភូមិសាស្ត្រខេត្តកណ្ដាល នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ ឯកឧត្ដម ណុប ដារ៉ា អភិបាលរងខេត្តកណ្ដាល បានណែនាំឱ្យអាជ្ញាធរ កម្លាំងសមត្ថកិច្ច គ្រប់មូលដ្ឋាន ត្រូវរៀបចំផែនការបង្ក្រាប និងទិសដៅផ្សព្វផ្សាយអប់រំ ទប់ស្កាត់ បង្រាបបទល្មើសគ្រឿងញៀន និងក្មេងទំនើងនៅតាមមូលដ្ឋានរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់។ ឯកឧត្ដមអភិបាលរងខេត្តបានលើកទឹកចិត្តដល់អាជ្ញាធរក្រុង-ស្រុក កងកម្លាំងមានសមត្ថកិច្ចត្រូវលើកឡើងពីបញ្ហាប្រឈម ក្នុងការងារបង្ក្រាបបទល្មើសគ្រឿងញៀន និងក្មេងទំនើងក្នុងភូមិសាស្ត្ររបស់ខ្លួនដើម្បីរួមគ្នាដោះស្រាយក្នុងកិច្ចប្រជុំនេះសំដៅធ្វើយ៉ាងណាជំរុញឱ្យការអនុវត្តការងារនេះកាន់តែមានប្រសិទ្ធភាពខ្ពស់ សំដៅការពារសន្តិសុខ និងសណ្ដាប់ធ្នាប់ជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន។ ក្នុងកិច្ចប្រជុំនេះដែរ ឯកឧត្ដមអភិបាលរងខេត្ត បានធ្វើការណែនាំដល់អាជ្ញាធរក្រុង-ស្រុក និងកងកម្លាំងមានសមត្ថកិច្ចត្រូវបន្តអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សនៅតាមសាលារៀនឱ្យយល់ដឹងអំពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន និងបញ្ហាក្មេងទំនើង។ ជាពិសេសត្រូវរៀបចំផែនការ កំណត់មុខសញ្ញារបស់ក្មេងទំនើង និងបទល្មើគ្រឿងញៀន នៅតាមទីតាំងនានាដូចជា ផ្ទះសំណាក់ កន្លែងកំសាន្ត ខារ៉ាអូខេ និងកន្លែងលក់ដូរជិតសាលារៀនជាដើម ដើម្បីត្រៀមក្នុងការអនុវត្តវិធានការ។ ឯកឧត្ដមបានបញ្ជាក់ថា គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង-ស្រុក យកចិត្តទុកដាក់ និងទទួលខុសត្រូវលើបញ្ហានេះ ហើយរាល់ការចុះបង្ក្រាបត្រូវធ្វើដោយគ្មានការលើកលែងត្រូវរាយការណ៍មកថ្នាក់លើមានកិច្ចសហការគ្នាឱ្យបានល្អជាមួយនឹងស្ថាប័នពាក់ព័ន្ធ ក្នុងករណីចាំបាច់ត្រូវស្នើឱ្យមានការសម្របសម្រួលពីព្រះរាជអាជ្ញា។ ចំពោះក្មេងទំនើងពេលចាប់បានត្រូវពិនិត្យរកសារធាតុញៀនបើក្នុងករណីមានសារធាតុញៀនត្រូវបញ្ជូនទៅមជ្ឈមណ្ឌលបន្សាបគ្រឿងញៀនសិនទើបបញ្ជូនមកសហគមន៍វិញ។[៦១]

ក្នុងឱកាសអបអរពីធីបុណ្យប្រពៃណីជាតិខ្មែរ រដ្ឋបាលក្រុងតាខ្មៅបានរៀបចំប្រារព្ធពិធីប្រពៃណីជាតិខ្មែរ និងបានរៀបចំកម្មវិធីកម្សាន្តសប្បាយៗជាច្រើន រួមផ្សំជាមួយការតាំងផលិតផលក្នុងស្រុក កម្មវិធីកីឡា និងល្បែងប្រជាប្រិយខ្មែរជាច្រើន។ ក្នុងការរៀបចំពិធីដ៏អធិកអធម សុវត្ថិភាពរបស់ប្រជាពលរដ្ឋជាកត្តាចម្បងដែលត្រូវយកចិត្តទុកដាក់ជាចាំបាច់ ហេតុនេះ រដ្ឋបាលក្រុងតាខ្មៅបានរៀបការពារសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ដោយបានសហការជាមួយស្នងការដ្ឋាននគរបាលខេត្តកណ្ដាល និងកងកម្លាំងយោធាការពារសុវត្ថិភាព និងផ្ដល់ភាពកក់ក្ដៅដល់អ្នកចូលរួម។ នៅថ្ងៃទី២ នៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ នាក្រុងតាខ្មៅបាននិងកំពុងប្រព្រឹត្តទៅយ៉ាងសប្បាយរីករាយជាមួយនឹងការចូលរួមរបស់ប្រជាពលរដ្ឋប្រមាណជាង ១ម៉ឺននាក់ខណៈការងារ

[៦០] សៀវភៅ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣របស់រដ្ឋបាលខេត្តកណ្ដាល, ទំព័រទី២១

[៦១] គេហទំព័រ រដ្ឋបាលខេត្តកណ្ដាល https://www.kandal.gov.kh/detail/15862, ដកស្រង់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២៤

សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈត្រូវធានាបានយ៉ាងល្អប្រសើរជូនប្រជាពលរដ្ឋ (បើយោងទៅតាមសំដីរបស់លោក **ហាក់ សុខមករា** អភិបាលរងខេត្តកណ្តាល)។

ក្រៅពីការរៀបចំសង្ក្រាន្តខេត្តកណ្តាល រដ្ឋបាលខេត្តកណ្តាលក៏បានរៀបចំពិធីបុណ្យអុំទូកដែលបានធ្វើនៅក្រុងតាខ្មៅនាថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២ ក្រោមអធិបតេយ្យភាព សម្តេច តេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាំចក្រកម្ពុជា។ សម្តេចតេជោ មានប្រសាសន៍លើកឡើងថា ជាមួយនឹងពិធីប្រណាំងទូកនេះខេត្តបានរៀបចំដាក់តាំងពិព័រណ៍ លក់ផលិតផលក្នុងស្រុកជាច្រើនប្រភេទ ដោយឡែកនៅពេលរាត្រី និងមានរៀបចំបណ្តែតគោមលើផ្ទៃទឹក បាញ់កាំជ្រួច និងមានកម្មវិធី ប្រគុំតន្ត្រីសម័យដែលមានតារាចំរៀងល្បីៗ ក្នុងព្រះរាជាណាចក្រកម្ពុជា។ សំរាប់ការប្រណាំងទូកនេះមានទូកទាំងអស់ចំនួន៩២ទូក ក្នុងនោះទូកអុំចំនួន ៤៦ទូក ទូកចែវចំនួន ០៦ទូក ទូកខ្នាតអន្តរជាតិបុរសចំនួន ៣៦ទូក និងទូកខ្នាតអន្តរជាតិនារីចំនួន ០៤ទូក សរុបចំណុះទូកចំនួន ៤.៥០៦នាក់ និងមានកម្លាំងត្រៀមការពារសន្តិសុខ សុវត្ថិភាពចំនួន ៧៨៤នាក់។ ជាមួយគ្នានេះផងដែរ លោកឧត្តមសេនីយ៍ទោ ឈឿន សុចិត្ត ស្នងការនគរបាលខេត្តកណ្តាលបានដឹកនាំកងកម្លាំងនគរបាលក្រោមឱវាទបានសហការជាមួយកងកម្លាំងយោធា សហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រណាំងទូកឆ្នាំ២០២២ ថ្ងៃទី២ នៅមាត់ទន្លេបាសាក់ ក្រុងតាខ្មៅ ខេត្តកណ្តាល។

### ខ. សុវត្ថិភាពសម្ភារៈ

សុវត្ថិភាពសម្ភារៈ ជាសេចក្តីសុខផ្នែកសម្ភារៈ និងទ្រព្យសម្បត្តិ ជាកិច្ចការពារទ្រព្យសម្បត្តិពីសំណាក់រដ្ឋ ដោយបង្កើតច្បាប់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ហើយក៏មានការចូលរួមពីសំណាក់ វិស័យឯកជនដូចជា ធនាគារ មីក្រូហិរញ្ញវត្ថុ កាមេរ៉ាសុវត្ថិភាព ទូដែកសុវត្ថិភាព។ បន្ទាប់ពីសុវត្ថិភាពបុគ្គល សុវត្ថិភាពសម្ភារៈជាតម្រូវការទី២ ដែលប្រជាពលរដ្ឋគ្រប់រូបចង់បានពីសំណាក់រាជរដ្ឋាភិបាល និងអាជ្ញាធរ។ បុគ្គលម្នាក់ៗតែងតែប្រាថ្នារស់នៅក្នុងតំបន់ដែលអាចផ្តល់នូវសុវត្ថិភាពសម្ភារៈរបស់ពួកគេតាមរយៈរូបភាពជាច្រើនដូចជា គ្មានការឆក់ គ្មានការប្លន់ទ្រព្យសម្បត្តិ គ្មានការចាប់ជំរិតទាមទារប្រាក់ គ្មានការក្លែងបន្លំផលទូផលប្រើប្រាស់។ល។ ដើម្បីធានាដល់ការរក្សាសុវត្ថិភាពសម្ភារៈ ស្ថាប័នឯកជនមួយចំនួនក៏បានលេចឡើងក្នុងរូបភាពជាធនាគារដែលអាចផ្តល់សេវាបញ្ញើទ្រព្យសម្បត្តិដើម្បីរក្សាសុវត្ថិភាព។ បន្ថែមពីនេះ ក៏មានការបង្កើតនូវឧបករណ៍ថ្មីៗទំនើបៗជាច្រើនដូចជា ការបង្កើតការមេរ៉ាសុវត្ថិភាពដែលអាចបំពាក់បានគ្រប់ទីកន្លែងដើម្បីការពារដល់សកម្មភាពលួច និងទូដែកសុវត្ថិភាព។ ក្រៅពីវិស័យឯកជន រាជរដ្ឋាភិបាលកម្ពុជាក៏បានស្វះស្វែងបង្កើតនូវច្បាប់មួយចំនួនផងដែរដូចជា គោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព (គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់

និងបទល្មើសគ្រប់ប្រភេទ )។[៦២] ពិសេសគឺការបង្កើតក្រមព្រហ្មទណ្ឌ ដែលបានកំណត់ពីទោសកំហុសនៃអំពើដែលបានប្រព្រឹត្តិ។

ជាក់ស្តែង កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ ក្នុងកិច្ចប្រជុំ ត្រួតពិនិត្យ និងការបង្ក្រាបទីតាំងល្បែងស៊ីសងគ្រប់ប្រភេទគ្មានច្បាប់អនុញ្ញាតនៅស្រុកកោះធំ និងក្រុងសំពៅពូន។ អភិបាលរងខេត្តកណ្តាលលោក ណុប ដារ៉ា អនុប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលស្រុកកោះធំ និងក្រុងសំពៅពូនត្រួតពិនិត្យ និងបញ្ជាឱ្យបង្ក្រាបដោយគ្មានត្រាប្រណីចំពោះទីតាំងល្បែងស៊ីសងគ្រប់ប្រភេទគ្មានច្បាប់អនុញ្ញាត ឬបំពាននឹងច្បាប់ស្តីពីល្បែងអេឡិចត្រូនិច។ លោកបានបញ្ជាក់ថា ទីតាំងល្បែងគ្មានការអនុញ្ញាតច្បាប់ ត្រូវចុះចាប់ និងបិទបន្ទាន់ ហើយមិនត្រូវអនុញ្ញាតឱ្យបើកទីតាំងថ្មីៗ បន្តទៀតនោះទេ បើទោះជាមានអាជ្ញាប័ណ្ណក៏ដោយ ហើយពង្រីកសាខាតាមតែចិត្ត គឺដាច់ខាតមិនឱ្យពង្រីកតាមចិត្តឡើយ។ ព្រោះការលេងល្បែងវាប៉ះពាល់ដល់ជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋខ្លាំងណាស់ បង្កការប្រើអំពើហិង្សា និងធ្លាក់ខ្លួនក្នុងស្ថានភាពបំណុល បញ្ហាចោរកម្ម ប្លន់ លួចជាដើមដែលនេះជាបញ្ហាប្រឈមរបស់អាជ្ញាធរមូលដ្ឋាន ដែលទាមទារឱ្យអាជ្ញាធរកងកម្លាំងគ្រប់លំដាប់ថ្នាក់ព្យាយាមអប់រំ និងពន្យល់បងប្អូនប្រជាលរដ្ឋកុំឱ្យលេងល្បែងតទៅទៀតបើទោះបីជាល្បែងទាំងនោះមានច្បាប់ក៏ដោយ។[៦៣]

បន្ថែមពីនោះ កាលពីថ្ងៃទី៦ ខែមីថុនា ឆ្នាំ២០២៤ កម្លាំងសមត្ថកិច្ចជំនាញ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច រួមនឹងអាជ្ញាធរមូលដ្ឋាន ក្រោមការដឹកនាំសម្របសម្រួលនីតិវិធីពី លោក លី ភារ៉ា ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកណ្តាលបានចុះបង្ក្រាបទីតាំងវេចខ្ចប់ កែច្នៃ ចែកចាយប្រេងម៉ាស៊ីនក្លែងក្លាយស្ថិតនៅចំណុចផ្ទះគ្មានលេខ ផ្លូវបេតុង ភូមិកំពង់សំណាញ់១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ។ នៅក្នុងប្រតិបត្តិការនោះ កម្លាំងសមត្ថកិច្ចជំនាញបានរកឃើញប្រេងម៉ាស៊ីន និងសម្ភារសម្រាប់វេចខ្ចប់ប្រេងម៉ាស៊ីនក្លែងក្លាយជាង ៥តោន។ ក្រោយឆែកឆេររួចរាល់កម្លាំងសមត្ថកិច្ចជំនាញបានដកហូតសម្ភារទាំងអស់នោះយកទៅរក្សាទុកជាបណ្តោះអាសន្ននៅនាយកដ្ឋាននគរបាលប្រឆាំងនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច និងបាននាំខ្លួនម្ចាស់ទីតាំងយកទៅសាកសួរដើម្បីអនុវត្តតាមច្បាប់។[៦៤]

---

[៦២] គោលនយោបាយលេខ០១ គនប, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២១, លក្ខណៈសម្បត្តិរបស់ភូមិ-ឃុំមានសុវត្ថិភាព, ចំណុច២

[៦៣] គេហទំព័រ FRESH NEWS https://m.freshnewsasia.com/index.php/en/localnews/328953-2024-02-17-03-22-46.html, ដកស្រង់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤

[៦៤] គេទំព័រ CNC https://www.cnc.com.kh/detail/news/54180, ដកស្រង់ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤

### គ. សុវត្ថិភាពចំណីអាហារ

មនុស្សគឺជាធនធានមួយដ៏សំខាន់ ហើយអាហារគឺជាប្រភពទ្រទ្រង់ជីវិតរបស់មនុស្សដ៏សំខាន់ដែលមិនអាចធ្វេសប្រហែសបានឡើយ។ យោងតាម ហ្វេសប៊ុកផេក JIC សុវត្ថិភាពចំណីអាហារ សំដៅដល់ការធានាថាអាហារនឹងមិនបង្កគ្រោះថ្នាក់ដល់អ្នកបរិភោគ និងរៀបចំតាមក្បួនប្រើប្រាស់។ សុវត្ថិភាពចំណីអាហារសំដៅដល់អាហារដែលមានសារធាតុពុល ឬសារធាតុគីមីដែលអាចបំផ្លាញសុខភាពរបស់មនុស្ស តាមរយៈបន្លែ ត្រី សាច់ ភេសជ្ជៈផ្សេងៗ។ សុខភាពគឺជាទ្រព្យដ៏មានតម្លៃដែលមិនអាចយកថវិកាមកទិញបានឡើយ ហេតុនេះ មនុស្សត្រូវមើលថែសុខភាពរបស់ខ្លួនតាមរយៈការបរិភោគចំណីអាហារ។ ដោយការយកចិត្តទុកដាក់ ខេត្តកណ្ដាលបានរៀបចំសិក្ខាសាលា ស្ដីពីការយល់ដឹងពីការធ្វើអាជីវកម្ម ដើម្បីកាត់បន្ថយបញ្ហាប្រឈមផ្នែកផ្លូវច្បាប់។ ឯកឧត្តម ម៉ៅ ថូរ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម បានមានប្រសាសន៍ថា គោលបំណងនៅក្នុងសិក្ខាសាលានេះគឺដើម្បីផ្ដល់ឱកាសដល់ អាជីវករ ពាណិជ្ជករ ក្រុមហ៊ុន សហគ្រាស នៅក្នុងខេត្តកណ្ដាល បានយល់ដឹងអំពីច្បាប់ពាក់ព័ន្ធ នៅក្នុងដំណើរការអាជីវកម្មរបស់ខ្លួន ដើម្បីកាត់បន្ថយបញ្ហាប្រឈមនានាដែលជាគន្លឹះជំរុញឱ្យការធ្វើអាជីវកម្មមានភាពរឹងមាំ បង្កើតបរិយាកាស អាជីវកម្មប្រកបដោយការប្រកួតប្រជែង និងមានភាពស្មោះត្រង់។ ឯកឧត្តមបានមានប្រសាសន៍ដូច្នេះ នៅក្នុងសិក្ខាសាលាស្ដីពីការយល់ដឹងពីការធ្វើអាជីវកម្មរបស់ពាណិជ្ជករកម្ពុជាដើម្បីកាត់បន្ថយបញ្ហាប្រឈមផ្នែកផ្លូវច្បាប់ដោយបានការអញ្ជើញជាអធិបតីពី ឯកឧត្តម នុត ពុធដារ៉ា អភិបាលរងខេត្តកណ្ដាល និងមានការអញ្ជើញចូលរួមពីមន្ទីរពាក់ព័ន្ធ ម្ចាស់អាជីវកម្ម និងអាជីវករ ក្រុមហ៊ុន សហគ្រាសក្នុងខេត្តជាង ២០០នាក់ នៅព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ នៅសាលាខេត្តកណ្ដាល។ ឯកឧត្តម ម៉ៅ ថូរ៉ា បានមានប្រសាសន៍បន្តថា សិក្ខាសាលានាថ្ងៃនេះ គឺផ្ដោតសំខាន់ទៅលើច្បាប់ចំនួន៤ រួមមាន៖

- ច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់
- ច្បាប់ស្ដីពីការប្រកួតប្រជែង
- ច្បាប់ស្ដីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវាដែលតំរូវឱ្យប្រជាពលរដ្ឋពិសេសគឺគ្រប់អាជីវករ ពាណិជ្ជករត្រូវតែមានការយល់ដឹងអំពីច្បាប់ទាំងអស់នេះ ដើម្បីធ្វើឱ្យអាជីវកម្មខ្លួនមានការរីកចម្រើន និងមិនជួបបញ្ហាប្រឈម។

ឯកឧត្តមក៏បានសំណូមពរដល់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ និងការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ សូមជួយបង្កើននូវការផ្សព្វផ្សាយច្បាប់ទាំងនេះឱ្យបានកាន់តែទូលំទូលាយដល់អាជីវករ ពាណិជ្ជករ ក្រុមហ៊ុនផលិត សហគ្រាសផលិត និងអ្នកពាក់ព័ន្ធនានាឱ្យបានជ្រាបបន្តទៀត ដើម្បីជំរុញឱ្យការអនុវត្តច្បាប់កាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ អ្នកប្រើប្រាស់ផលិតផល និងសេវាទទួលបានគុណភាពមានសមភាពក្នុង

ការប្រកួតប្រជែង ជាពិសេសសូមចុះពិនិត្យគុណភាពផលិតផលទំនិញនៅតាមទីផ្សារឱ្យបានច្រើន ដើម្បីឱ្យអ្នកប្រើប្រាស់ទទួលបានសុខសុវត្ថិភាពពេលទិញទំនិញទៅប្រើប្រាស់។[៦៥]

### ២.២.១.២. ភាពស្ងប់ស្ងៀម

ភាពស្ងប់ស្ងៀម គឺសម្តៅទៅលើទីតាំងមួយដែលមិនមានការបំពុលដោយសំឡេងដែលរំខានដល់ការរស់នៅរបស់ប្រជាជន។ ការរំខានដោយសារសម្លេងអាចកើតឡើងពីសម្លេងចេញពីរោងចក្រ គ្រឿងចក្រ ភោជនីយដ្ឋាន សាលារៀន ក្លឹបកំសាន្ត និងការសាងសង់ផ្សេង។ ខេត្តកណ្តាល ជាខេត្តមួយក្នុងចំណោមខេត្តទាំង២៥ ដែលមានទីតាំងជាប់នឹងរាជធានីភ្នំពេញ។ ហេតុនេះ ខេត្តកណ្តាលបានទទួលការអភិវឌ្ឍជាច្រើនទៅលើ ការសាងសង់លំនៅដ្ឋាន រោងចក្រ ភោជនីយដ្ឋាន ក្លឹបកំសាន្ត រមណីដ្ឋាន។ល។ ការអភិវឌ្ឍទាំងនេះ ក៏បានជះឥទ្ធិពលមិនល្អដល់ការរស់នៅរបស់ប្រជាជនផងដែរ។ ប៉ុន្តែ ដោយមានការសម្រួលពីអាជ្ញាធរមានសមត្ថកិច្ចគុណវិបត្តិទាំងនោះក៏លែងចោទជាបញ្ហាទៀតនោះឡើយ។

ជាក់ស្តែងកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ កម្លាំងនគរបាលចម្រុះ ខេត្តកណ្តាលបានចុះបង្ក្រាបភោជនីយដ្ឋានមួយដែលលបលួចផឹកស៊ីច្រៀងរាំមិនគោរពវិធានការរដ្ឋបាលនៅចំណុចភោជនីយដ្ឋានអាយផាប់ ស្ថិតនៅភូមិថ្មី២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល។

### ២.២.១.៣. គ្មានការបំពុល

ការប្រើប្រាស់ជីវិតរស់នៅ មនុស្សពឹងផ្អែកជាសំខាន់ទៅលើបរិស្ថាន បរិស្ថានល្អផ្តល់ឱ្យនូវបរិយាកាសល្អ ខ្យល់បរិសុទ្ធ ពិសេសនោះគឺផ្តល់នូវសុខភាពដ៏ល្អដល់ប្រជាពលរដ្ឋ។ ហេតុនេះហើយ ទើបកត្តាបរិស្ថានជាកត្តាដ៏សំខាន់ក្នុងការរៀបចំសណ្តាប់ធ្នាប់ទូទាំងខេត្ត។ គ្មានការំពុលសំដៅដល់ការគ្មា នការបំផ្លាញបរិស្ថានដោយគ្មានការបំពុលដី គ្មានការបំពុលទឹក គ្មានការបំពុលខ្យល់ គ្មានការបំពុលដោយសំណល់រឹងរាវ។ មន្ត្រីមានសមត្ថកិច្ចខេត្តកណ្តាល ជាពិសេស មន្ទីរបរិស្ថានខេត្តកណ្តាលបានកំពុងស្វះស្វែងធ្វើសកម្មភាពថែរក្សាបរិស្ថាន ក្រោមសកម្មភាពដូចខាងក្រោម

កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ នៅក្រុងតាខ្មៅ ខេត្តកណ្តាល លោក ពៅ សោម៉ាណាក់ ប្រធានមន្ទីរបរិស្ថានខេត្តកណ្តាលបានដឹកនាំក្រុមការងារចុះអប់រំផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹង ដល់អាជីវករជុំវិញការ ទុកដាក់សម្រាមឱ្យត្រឹមត្រូវ ពិសេសផ្តោតសំខាន់ទៅលើការគ្រប់គ្រងសម្រាម សំណល់រឹង សំណល់ ផ្លាស្ទិក ការញែកសម្រាម និងយុទ្ធាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក។

[៦៥] គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://www.kandal.gov.kh/, ដកស្រង់ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤

នាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤ មន្ទីរខេត្តកណ្តាល សហការផ្សព្វផ្សាយយុទ្ធនាការកម្ពុជាស្អាតខ្មែរធ្វើបាន និងថ្ងៃនេះខ្ញុំមិនប្រើថង់ប្លាស្ទិក ដោយមានអ្នកចូលរួមចំនួន ៨៤៩៩នាក់ ។

បន្ថែមពីនេះ យោងទៅតាមការចុះផ្សាយលើហ្វេសប៊ុកផេករបស់មន្ទីបរិស្ថានខេត្តកណ្ដាល បានឱ្យដឹងថា នៅព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៤ ក្រុមការងារមន្ទីរបរិស្ថានខេត្តកណ្ដាលដែលដឹកនាំដោយលោក ពៅ សោមាណាក់ ប្រធានមន្ទីរបានសហការជាមួយក្រុមការងារអង្គការសំអាតទន្លេ សមុទ្រ River Ocean Cleanup ដឹកនាំដោយលោក នូ សុវណ្ណ នាយកប្រតិបត្តិអង្គការរៀបចំកម្មវិធីផ្សព្វផ្សាយអំពីការថែទាំ បរិស្ថានសម្រាប់សាលា សហគមន៍ដែលមានភូមិសាស្ត្រជាប់នឹងមាត់ទន្ល ដោយប្រារព្ធនៅវិទ្យាល័យ ហ៊ុន សែន កោះចិន ស្ថិតក្នុងឃុំកោះចិន ស្រុកពញាឮ ដោយមានការអញ្ជើញចូលរួមពីលោក ថន សុវណ្ណា អភិបាលស្រុក តំណាងមន្ទីរអប់រំខេត្ត តំណាងក្រុមហ៊ុន Leader Energy Holding Bhd ព្រះសង្ឃ អាជ្ញាធរឃុំ ភូមិ លោកនាយក លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សវិទ្យាល័យ និងប្រជាពលរដ្ឋ សរុប ៦៥០នាក់ (ស្រី៣៥០នាក់) ក្នុងគោលបំណងផ្តល់ចំណេះដឹងដល់អ្នកចូលរួមអំពីសារៈសំខាន់នៃទន្លេ គោលការណ៍៤ក (កុំប្រើ កាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងកាកែច្នៃ) ដើម្បីកាត់បន្ថយសំណល់ ការគ្រប់គ្រងសំរាម សំណល់រឹងឱ្យបានត្រឹមត្រូវដើម្បីបញ្ចៀសការបោះចោលពាសវាលពាសកាលធ្វើឱ្យខូចបរិស្ថាន បំពុលទន្លេ និងចំណេះដឹងស្តីពីវិធានសុវត្ថិភាពសហគមន៍ដែលមានខ្សែបញ្ជូនអគ្គិសនីឆ្លងកាត់។ ក្រុមការងារមន្ទីរបរិស្ថានបានដឹកនាំធ្វើយុទ្ធនាការ«កម្ពុជាស្អាត ខ្មែរធ្វើបាន» «ថ្ងៃនេះ ខ្ញុំមិនប្រើថង់ប្លាស្ទិកទេ» ចូលរួមសហការដឹកនាំធ្វើអនាម័យបរិស្ថានប្រមូលដឹកជញ្ជូនសំរាមនៅតាមមាត់ទន្លេជិតកន្លែងប្រារព្ធពិធី។

ជាទីមោទកភាពចំពោះក្រុងតាខ្មៅ ដែលទទួលបានពានរង្វាន់ ជាទីក្រុងទេសចរណ៍ស្អាត អាស៊ាន លើកទី២ នៅឆ្នាំ២០២០។ ពិធីប្រគល់ពានរង្វាន់ជ័យលាភី បានប្រារព្ធពិធីនៅទីក្រុង បេដាសេរី បេកាវ៉ាន់ ប្រទេសប្រ៊ុយណេ ក្នុងវេទិកាទេសចរណ៍អាស៊ាន ឆ្នាំ២០២០ កាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០។ ការជ្រើសរើសទីក្រុងស្អាតវាយតម្លៃលើសូចនាករសំខាន់ៗចំនួន០៧ ដូចជា៖

- ការសហការគ្នាបានល្អរវាងប្រជាពលរដ្ឋនិងអាជ្ញាធរមូលដ្ឋាន
- ការថែរក្សាសំអាតអនាម័យបរិស្ថានបានស្អាត
- មិនមានផ្សែងបំពុលខ្យល់
- មានបង្គន់នៅតាមសាធារណៈ
- មានប្រព័ន្ធគ្រប់គ្រងទឹកស្អាត
- គ្រប់គ្រងសំរាម និងកាកសំណល់បានស្អាតត្រឹមត្រូវ

- ប្រជាជនសហការចូលរួមការពារសន្តិសុខ សុវត្ថិភាព ថែរក្សាសណ្ដាប់ធ្នាប់ របៀបរៀបរយបានល្អ និងមានសួនលំហែរកាយមានសោភ័ណភាពស្រស់ស្អាត។

នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០ រដ្ឋបាលខេត្តកណ្ដាលបាន ប្រារព្ធពិធីដង្ហែពានរង្វាន់ ក្រុងតាខ្មៅ ខេត្តកណ្ដាលទទួលបានពានជ័យលាភីទីក្រុងទេសចរណ៍ស្អាតអាស៊ានលើកទី២ ឆ្នាំ២០២០-២០២២។ ដោយចូលរួមជាអធិបតីដោយ ឯកឧត្ដមបណ្ឌិត ម៉ៅ ភារុណ អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល និងចូលរួមពីក្រុមប្រឹក្សាខេត្ត ថ្នាក់ដឹកនាំមន្ត្រីរាជការជុំវិញខេត្ត កងកម្លាំងប្រដាប់អាវុធ ព្រះសង្ឃ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រមាណជាង ៣០០០នាក់ និងបានរៀបចំរថយន្តធំ១៨៣គ្រឿង រថយន្តធនតូច ៥៣គ្រឿង និងម៉ូតូចំនួន ៥៣គ្រឿងសម្រាប់ប្រើប្រាស់ក្នុងពិធី និងរៀបចំក្បួនដង្ហែរចែកជា១១ផែនឆ្ពោះទៅសង្កាត់ទាំង១១នៃខេត្តកណ្ដាល។ ពិធីនេះប្រារព្ធនៅមាត់ទន្លេបាសាក់ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

ជារួម យើងឃើញថាការរៀបចំសណ្ដាប់ធ្នាប់ឱ្យបានល្អគឺត្រូវផ្ដោតទៅលើ កត្តាបីដែលជាធាតុផ្សំនៃការរៀបចំសណ្ដាប់ធ្នាប់ ដូចជា សន្តិសុខ ភាពស្ងប់ស្ងៀម និងគ្មានការបំពុល។ សណ្ដាប់ធ្នាប់ ជាគ្រាប់ពេជ្រនៃទឹកដី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ កាលណាដែលប្រជាពលរដ្ឋទទួលបាននូវការយកចិត្តទុកដាក់ពីសំណាក់អាជ្ញាធរ រាជរដ្ឋាភិបាល និងផ្ដល់ឱ្យពួកគេនូវសន្តិភាពឱ្យប្រជាពលរដ្ឋនឹងរស់នៅប្រកបដោយសន្តិភាព សុវត្ថិភាព ជាមួយសណ្ដាប់ធ្នាប់ល្អ ទីក្រុងស្អាត និងរីកចម្រើន។

### ២.២.២. ការរៀបចំសោភ័ណភាពខេត្តកណ្ដាល

បើផ្អែកលើវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ពាក្យ សោភ័ណ មានន័យថា ប្រសើរក្រៃលែង ល្អកន្លង។ ឧទាហរណ៍ ការតុបតែងពន្លឺភ្លើពណ៌នៅតាមដងវិថីនាពេលរាត្រី នាំឱ្យទីក្រុងមានសោភ័ណភាព និងមានការអភិវឌ្ឍ។[៦៦]

#### ២.២.២.១. សោភ័ណភាពពេលថ្ងៃ

**សោភ័ណភាពពេលថ្ងៃ** គឺសម្ដៅទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធរួមមាន ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធលូ ចិញ្ចើមផ្លូវ សំណង់អគារតូចធំទាំងអស់របស់រដ្ឋ និងឯកជន សួនច្បារសាធារណៈ ផ្លូវក្រោមដី ព្រមទាំងមានប្រព័ន្ធសុវត្ថិភាពចរាចរណ៍រួមមាន ភ្លើងសញ្ញា ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍ រួមទាំងការធ្វើដំណើរតាមដងផ្លូវនៃយានយន្តគ្រប់ប្រភេទ ទាំងថ្មើរជើងផង ប្រកបដោយសណ្ដាប់ធ្នាប់ និងមានរបៀបរៀបរយល្អថែមទៀត។

[៦៦] គេហទំព័រ https://thmeythmey.com/?page=detail&id=60547, ដកស្រង់ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤

**ក. ហេដ្ឋារចនាសម្ព័ន្ធសង្គម**

- ជំរុញ ស្ដារ និងរៀបចំលម្អសាធារណៈផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនា ដល់មនុស្សគ្រប់វ័យ រួមមាន កុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចាស់ និងជនពិការឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនពិការ បង្គន់អនាម័យសម្រាប់ជនពិការនៅតាមទីធ្លាសារណៈ អគារសាធារណៈនឹងកន្លែងផ្ដល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈគ្រប់កម្រិត ទៅតាមភូមិ សង្កាត់ ក្នុងក្រុងតាខ្មៅ ស្របតាមអនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្ដុះបណ្ដាល វិជ្ជាជីវៈ
- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ ប៉ុស្ដិ៍សុខភាព រៀបចំកន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យ ឱសថស្ថាននៅតាមសង្កាត់ និងក្នុងក្រុង ស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល ថែរក្សាទីតាំងវប្បធម៌ សាសនា និងសម្បត្តិបេតិកភណ្ឌ ដូចជាវិហារចិន វិហារឥស្លាម និងវត្តខ្មែរបុរាណ។

**ខ. ផ្លូវថ្នល់**

- រៀបចំ និងកែលម្អផ្លូវពាណិជ្ជកម្ម ដោយកំណត់ផ្លូវជាតិលេខ២១ ជាផ្លូវសម្រាប់ចរាចរណ៍ធនស្រាល
- រៀបចំឱ្យមានភ្លើងសញ្ញាចរាចរណ៍ ភ្លើងបំភ្លឺតាមដងផ្លូវ ផ្លាកនិងគំនូសសញ្ញាចរាចរណ៍ និងលេខផ្លូវឱ្យបានគ្រប់ផ្លូវទាំងអស់
- បង្កើតបណ្ដាញផ្លូវថ្នល់ភ្ជាប់ទំនាក់ទំនងរវាងទីប្រជុំជន ក្រុង ទៅតំបន់ជាយក្រុង ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការធ្វើដំណើរ ដឹកជញ្ជូន និងកាត់បន្ថយថ្លៃចំណាយក្នុងការធ្វើដំណើរ
- រៀបចំចិញ្ចើមផ្លូវសម្រាប់ទុកកន្លែងឱ្យអ្នកថ្មើរជើងធ្វើដំណើរមានភាពងាយស្រួល និងធានាបាននូវសុវត្ថិភាព
- រៀបចំឱ្យមានស្ពានអាកាសសម្រាប់ថ្មើរជើងឆ្លងកាត់ផ្លូវនៅតាមកន្លែងមួយចំនួន ដែលមាន មនុស្សឆ្លងកាត់ច្រើនដូចជាសាលារៀន ផ្សារ មន្ទីរពេទ្យ កន្លែងកម្សាន្ត និងរោងចក្រជាដើម ដើម្បីងាយស្រួល និងបញ្ចៀសគ្រោះថ្នាក់ចរាចរណ៍

- បង្កើតផ្លូវថ្មី និងតភ្ជាប់កំណាត់ផ្លូវដែលទាល់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការចរាចរណ៍បច្ចុប្បន្ន និងអនាគត
- ជំរុញកសាងផ្លូវវាងក្រុងតាមទៅតាមការប្លង់គោលប្រើប្រាស់ដី ដើម្បីបញ្ចៀសរថយន្តដឹកទំនិញ ធុនធ្ងន់ចូលក្នុងទីក្រុង និងការកាត់ទទួយបញ្ហាកកស្ទះ គ្រោះថ្នាក់បានការណ៍ ការហុយធូលី និងការពាក់នូវសណ្តាប់ធ្នាប់ សោភ័ណភាពក្រុង
- លើកទឹកចិត្តអ្នកចូលរួមគាំទ្រ ក្នុងការពង្រីកផ្លូវនៅតាមមូលដ្ឋាន ដើម្បីសម្រួលចរាចរណ៍ធ្វើដំណើរទៅវិញទៅមក
- កំណត់ទីតាំងសម្រាប់រៀបចំជាចំណតរថយន្តក្រុង និងចំណតទូទៅនៅក្នុងទីប្រជុំជនក្រុង និងតាមសង្កាត់នានា
- ពង្រីក និងកែលម្អនូវបណ្តាញផ្លូវថ្នល់ទាំងអស់ឱ្យមានលក្ខណៈធំទូលាយសមរម្យ និងមានលក្ខណៈជាប្រព័ន្ធប្រទាក់ក្រឡាគ្នាដើម្បីកាត់បន្ថយការកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍
- លើកកម្ពស់ និងផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍តាមផ្លូវគោក។

**គ. ផ្លូវទឹក**

- រៀបចំមធ្យោបាយធ្វើដំណើរតាមផ្លូវទឹកឱ្យបានច្រើនប្រភេទ ដើម្បីសម្រួលដល់ការធ្វើដំណើរទូទៅ និងប្រកបការងារ
- សាងសង់ឱ្យមានកំពង់ផែសម្រាប់ការលើកដាក់ ដឹកជញ្ជូនទំនិញចេញចូលនៅតាមដងទន្លេបាសាក់
- រៀបចំ និងបង្កើនមធ្យោបាយទេសចរណ៍ផ្លូវទឹកឱ្យបានច្រើន ដើម្បីអូសទាញភ្ញៀវទេសចរណ៍ និងកំណើនសេដ្ឋកិច្ច
- ជួសជុល កែលម្អស្ពានចាស់ទ្រុឌទ្រោម និងកសាងស្ពានថ្មីសម្រាប់ឆ្លងកាត់ទន្លេ ស្ទឹង ព្រែកឱ្យបានច្រើនសមស្រប ដើម្បីសម្រួលដល់ការធ្វើដំណើរ ការដឹកជញ្ជូនទាំងផ្លូវទឹក និងផ្លូវគោក
- កែលម្អ ស្តារឡើងវិញ និងកសាងបណ្តាញផ្លូវទឹកនៅតាមដងទន្លេបាសាក់ ស្ទឹងព្រែកត្នោត ស្ទឹងព្រែកហូរ និង ព្រែក អូរប្រឡាយ និងបឹងបួរបស់ក្រុងសម្រាប់បម្រើវិស័យទេសចរណ៍
- ការផ្គត់ផ្គង់ទឹក និងការរំដោះទឹក
- រៀបចំប្រព័ន្ធដឹកជញ្ជូន និងមធ្យោបាយដឹកជញ្ជូនស្រស្របតាមតម្រូវ។

**ឃ. ផ្លូវអាកាស**

- រៀបចំបង្កើតអាកាសយានដ្ឋានអន្តរជាតិក្រុងតាខ្មៅជាមួយនឹងស្រុកកណ្តាលស្ទឹង ដើម្បីឆ្លើយតបទៅនឹងតម្រូវការកំណើនសេដ្ឋកិច្ច និងភ្ញៀវទេសចរណ៍ដែលមានកំណើនខ្ពស់

➢ រៀបចំផែនការប្រើប្រាស់ដីលម្អិតក្នុងតំបន់ និងនៅជុំវិញផ្លូវអាកាស ដើម្បីរក្សាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍប្រកបដោយចីរភាព។

**ង. ការផ្គត់ផ្គង់ទឹកស្អាត**

➢ ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ក្រុង

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវបានបង្កើតឡើងក្នុងក្រុងតាខ្មៅ។ ប្រព័ន្ធដែលមានស្រាប់ត្រូវកែលម្អបន្ថែម និងពង្រីកដើម្បីរក្សាគុណភាពជាមួយកំណើនប្រជាជន។ តម្រូវការបន្ទាន់បំផុតសម្រាប់ការកែលម្អនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ទីក្រុង គឺមានតាមលំដាប់អាទិភាពដូចខាងក្រោម៖

- សិក្សាពីជលសាស្ត្រ និងត្រួតពិនិត្យតាមដានដើម្បីធានានូវបរិមាណទឹកស្អាតនៃធនធានទឹកដែលអាចមាន
- សិក្សាប្រភពទឹកដើម្បីធានានូវសក្តានុពលនៃទឹកក្រោមដីសម្រាប់ផ្គត់ផ្គង់ទឹកស្អាតតំបន់ក្រុង
- រៀបចំបទប្បញ្ញត្តិ និងការចាត់វិធានការផ្សេងៗ ក្នុងការការពារប្រភពផ្គត់ផ្គង់ទឹកសម្រាប់ បម្រើដល់ការអភិវឌ្ឍតំបន់ក្នុងទីក្រុង
- ស្តារឡើងវិញ និងការដោះដូរបំពង់ទឹកចាស់ៗ ដើម្បីកាត់បន្ថយការលេចធ្លាយ និងបង្កើនគុណភាពទឹកតាមតម្រូវការជាក់ស្តែង
- ការពារ ពង្រីកបន្ថែម សាងសង់អាងស្តុកទឹក និងបណ្តាញចែកចាយទឹក ដើម្បីធានាការផ្គត់ផ្គង់ស្របតាមការរីកចម្រើន និងការប្រើប្រាស់
- ពង្រីកបណ្តាញចែកចាយទឹក ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជនឱ្យបានច្រើនជាងមុន និងបង្កើនប្រាក់ចំណូលបន្ថែម
- បន្តពង្រឹងសមត្ថភាព និងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកស្របតាមបទដ្ឋានបច្ចេកទេស។

➢ **ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជាយក្រុង**

ប្រភពទឹកនៅតំបន់ជាយក្រុងតាខ្មៅ ស្ថិតនៅក្នុងឃុំស្វាយរលំ ឃុំកាខ្ពស់ ឃុំសិត្បូ និងឃុំកោះអន្លង់ចិន

- រក្សា និងកំពុងត្រូវបានការពារជាប្រភពទឹកធម្មជាតិសម្រាប់ប្រើប្រាស់ និងទេសចរណ៍កម្សាន្ត
- ស្តារ និងកែលម្អអាងស្តុកទឹក និងបណ្តាញចែកចាយទឹកដែលមានស្រាប់ ដើម្បីអភិវឌ្ឍន៍ និងផ្គត់ផ្គង់ទឹកស្អាត

- សិក្សា និងសាងសង់អាងស្តុកទឹក និងពង្រីកបណ្តាញចែកចាយទឹកបន្ថែម។[៦៧]

ជាក់ស្តែងយ៉ាងយូរ២ឆ្នាំទៀតគម្រោងពង្រីកអាងប្រព្រឹត្តិកម្មផ្គត់ផ្គង់ទឹកស្អាតក្រុងតាខ្មៅខេត្តកណ្តាល ដែលមានសមត្ថភាពអាចផលិតទឹកស្អាតបានចំនួន ៣ម៉ឺនម៉ែត្រគូបក្នុង១ថ្ងៃនឹងអាចឆ្លើយតបទៅនឹងតម្រូវការ ព្រមទាំងអាចជួយដោះស្រាយបញ្ហាខ្វះទឹករបស់ប្រជាពលរដ្ឋនៅក្រុងតាខ្មៅខេត្តកណ្តាលទាំងមូល ព្រមទាំង ជាយក្រុងភ្នំពេញបានថែមទៀត។

គម្រោងសាងសង់អាងប្រព្រឹត្តិកម្មទឹកស្អាតតាខ្មៅ ក្រោមជំនួយរបស់ជប៉ុន បច្ចុប្បន្នគម្រោងនេះសម្រេច បានប្រមាណជា ១១% នៃគម្រោងទាំងមូល ដែលមានទំហំការងារដូចជា សាងសង់ស្ថានីយបូមទឹកឆៅ និង បំពង់មេនាំទឹកឆៅ សាងសង់រោងចក្រប្រព្រឹត្តិកម្មទឹកស្អាត ៣០ ០០០ម៣/ថ្ងៃ អាងស្តុកទឹកស្អាត ៥ ០០០ម៉ែត្រ គូបក្នុង១ថ្ងៃ ការបំពាក់នាឡិកាទឹកមេ។

លោក ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានឱ្យដឹងថា រាជរដ្ឋាភិបាលជប៉ុន បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍនៅកម្ពុជា ជាពិសេសនៅក្នុងវិស័យទឹកស្អាត ដើម្បីធានានិរន្តរភាពក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ ប្រកបដោយគុណភាព សុវត្ថិភាព និរន្តរភាព និងតម្លៃសមរម្យ។ លោកបានឱ្យដឹងថា ការសាងសង់គម្រោងពង្រីកអាងប្រព្រឹត្តិកម្មទឹកស្អាតតាខ្មៅ ស្របពេលដែលចំនួនប្រជាជនកើនឡើងជាបន្តបន្ទាប់ ដែលធ្វើឱ្យតម្រូវការទឹកកើនឡើងទ្វេដង ទន្ទឹមនឹងតម្រូវ ការសម្រាប់ផ្គត់ផ្គង់ទឹក ដល់ព្រលានយន្តហោះថ្មី នៅតំបន់តាខ្មៅផងដែរ។

លោក ចម ប្រសិទ្ធ បានបន្តថាចាប់តាំងពីឆ្នាំ២០០៤មក ទឹកស្អាតសម្រាប់ប្រើប្រាស់ គឺផ្គត់ផ្គង់ដោយ រោងចក្រតូច១ដែលមានទំហំត្រឹមតែ ៥០ម៉ែត្រគូបប៉ុណ្ណោះក្នុង១ថ្ងៃ ដែលធ្វើឱ្យការផ្គត់ផ្គង់ទឹកស្អាតមានការខ្វះ ខាត បើទោះបីជា មានការបន្ថែមការតភ្ជាប់ពីរដ្ឋាករទឹកក្រុងភ្នំពេញក៏ដោយ។ លោកបញ្ជាក់ថា បន្ទាប់ពីសាង សង់រួចគម្រោងផ្គត់ផ្គង់ទឹកស្អាតនៅក្រុងតាខ្មៅនឹងចូលរួមចំណែកដល់បញ្ហាខ្វះទឹកស្អាតនៅរាជធានីភ្នំពេញ និង នៅក្រុងតាខ្មៅ ជាពិសេសគម្រោងនេះនឹងអាចឆ្លើយតប ទៅលើតម្រូវការផ្គត់ផ្គង់ទឹកស្អាត ទៅដល់ព្រលានយន្ត ហោះថ្មី ដែលកំពុងសាងសង់ និងការចែកចាយទៅដល់ប្រជាពលរដ្ឋនៅជុំវិញព្រលានយន្តនោះថែមទៀត។ ឆ្លៀតឱកាសនោះ លោកបានស្នើទៅអង្គភាពពាក់ព័ន្ធត្រូវយកចិត្តទុកដាក់ការពារប្រភពទឹកការពារសុវត្ថិភាពអាង ប្រព្រឹត្តិកម្មផងដែរ។

[៦៧] សេចក្តីសម្រេច ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ខេត្តកណ្តាល,លេខ ០០២ សសរ, ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨

លោក គង់ សោភ័ណ្ឌអភិបាលខេត្តកណ្ដាល បានថ្លែងបង្ហាញក្ដីរំភើបសម្រាប់ពលរដ្ឋក្រុងតាខ្មៅ ខេត្តកណ្ដាល ចំពោះសមិទ្ធផលថ្មីៗនេះ។ លោកថា អាងប្រព្រឹត្តិកម្មទឹកស្អាតនេះ នឹងធានាដល់ការប្រើប្រាស់ទឹកស្អាតបន្ថែមទៀតសម្រាប់ទ្រទ្រង់ជីវិតប្រចាំថ្ងៃរបស់ពលរដ្ឋ ព្រោះបើគ្មានទឹកប្រើប្រាស់ទេជីវិតមិនអាចធានាបាននូវសុខភាពគ្រួសារទេ។ លោកថ្លែងថា រាល់ការប្រើប្រាស់ទឹកស្អាត ដែលទទួលបានពីការត្រងទឹកភ្លៀងទុកប្រភពទឹកអណ្ដូង ជាពិសេសទឹកដាំឆ្អិនជាប្រចាំគឺអាចជួយទប់ស្កាត់រាល់មេរោគរាគត្បាត និងជំងឺផ្សេងៗបាន។ ដូច្នេះការប្រើប្រាស់ទឹកស្អាតពីអាងប្រព្រឹត្តកម្មទឹកស្អាតនេះ គឺជាកត្តាចាំបាច់ណាស់សម្រាប់ជីវិតរស់នៅរបស់សហគមន៍យើង។

ការអភិវឌ្ឍអាងប្រព្រឹត្តិកម្មទឹកស្អាតតាខ្មៅ ខេត្តកណ្ដាល គឺស្ថិតនៅក្រោមជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុនសរុបប្រមាណ ៣ ៩២១លានយ៉េន ឬប្រមាណ ៣០លានដុល្លារអាមេរិកតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន( JICA )ដោយដំណើរការសាងសង់រយៈ២ឆ្នាំទៀត ពោលគឺចាប់ផ្ដើមដំណើរការសាងសង់នៅចាប់ពីខែមិថុនា ឆ្នាំ២០២២ និងបញ្ចប់ការសាងសង់នៅខែធ្នូ ឆ្នាំ២០២៤។ គម្រោងនេះអាចមានសមត្ថភាពផលិតទឹកស្អាតបាន៣ ម៉ឺនម៉ែត្រគូប ក្នុង១ថ្ងៃ ខណៈគម្រោងនេះដែរក៏ជាប្រភេទគម្រោង Special Purpose Company ស្ថិតក្រោមការថែទាំលក្ខណៈបច្ចេកទេស និងគុណភាពទឹកក្នុងរយៈពេល ១០ឆ្នាំរបស់ជប៉ុននិងលក់ជាដុំជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញក្នុងតម្លៃតូចជាង ឬមិនឱ្យលើសពីតម្លៃ ៥០០រៀលក្នុង ១ម៉ែត្រគូប។ តាមរយៈគម្រោងខាងលើ លោក **MIKAMI MASAHIRO** ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជាក៏បានវាយតម្លៃខ្ពស់ថា សមិទ្ធផលនេះនឹងជាមោទនភាព និងមានសារៈសំខាន់ណាស់សម្រាប់ចូលរួមចំណែកនូវគោលនយោបាយអភិវឌ្ឍន៍វិស័យទឹកស្អាតរបស់កម្ពុជា។[៦៨]

### ២.២.២.២. សោភ័ណភាពពេលយប់

**សោភ័ណភាពពេលយប់** គឺសម្ដៅទៅលើការបំពាក់ភ្លើងបំភ្លឺតាមអគារនានាតាមដងមហាវិថីនានានៅក្នុងទីក្រុង ជាពិសេសការបំពាក់ភ្លើងបំភ្លឺចម្រុះពណ៌ពេលរាត្រីនៅតាមសួនច្បារសាធារណៈនៅក្នុងទីក្រុង។[៦៩]

ការលម្អភ្លើងនាពេលរាត្រីបានជួយបង្កើនសម្រស់ដល់ខេត្តកណ្ដាល ជាហេតុធ្វើឱ្យខេត្តកណ្ដាលមានភាពទាក់ទាញ ពិសេសចំពោះប្រជាពលរដ្ឋក្នុងខេត្តកណ្ដាល និងបានធ្វើឱ្យប្រជាពលរដ្ឋបានចូលរួមលំហែអារម្មណ៍នាពេលល្ងាច និងពេលរាត្រី ដូចជានៅតាមសួនច្បារ និងអាចទទួលទានអាហារសម្រន់បានតាមដងវិថីដែលលក់ដោយបងប្អូនអាជីវករជាមួយតម្លៃសមរម្យ។ ការលម្អភ្លើងចម្រុះនាពេលរាត្រីមានដូចជា៖

---

[៦៨] គេហទំព័រ https://m.postkhmer.com/national/2022-12-08-1703-244492.html, ដកស្រង់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤

[៦៩] គេហទំព័រ https://thmeythmey.com/?page=detail&id=60547, ដកស្រង់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤

- ការបំពាក់ភ្លើងពណ៌តាមរង្វង់មូល មានដូចជាៈ រង្វង់មូលព្រះនារាយណ៍ រង្វង់មូលក្រុងតាខ្មៅ រង្វង់មូលក្រុងសំពៅពូន និងរង្វង់មូលស្ពានព្រែកសំរោង
- ការបំពាក់ភ្លើងពណ៌តាមសួនសាធារណៈ មាននៅក្រុងតាខ្មៅ
- ការបំពាក់បង្គោលភ្លើងតាមដងផ្លូវ ដងស្ពាន សួនច្បារ
- ការដាំបង្គោលទូរទស្សន៍សាធារណៈនៅត្រង់ចំណុចច្រមុះជ្រូកក្រុងតាខ្មៅ។

### ២.២.៣. ផលវិបាក និងដំណោះស្រាយនៃការរៀបចំ

#### ២.២.៣.១. ផលវិបាក

##### ក. ធនធានមនុស្ស

ប្រទេសជាតិមួយអភិវឌ្ឍន៍ទៅបានយ៉ាងរលូន លុះត្រាតែប្រទេសនោះសម្បូរទៅដោយមនុស្សដែលមានទាំងចំណេះដឹង ចំណេះធ្វើ កម្លាំងពលកម្ម។ល។ ព្រោះធនធានមនុស្សជាកត្តាលីករមួយដែលជួយក្នុងការជំរុញឱ្យប្រទេសជាតិឆាប់ឈានទៅរកការអភិវឌ្ឍ។ មានធនធានមនុស្សកាន់តែច្រើន នោះបញ្ហានៃការរៀបចំ និងអនុវត្តផែនការមានកាន់តែតិច ឬឆាប់អាចដោះស្រាយបានយ៉ាងឆាប់រហ័ស។ ក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណ្ឌភាពខេត្តកណ្តាល ទាមទាឱ្យមានធនធានមនុស្ស ដើម្បីជម្រុញឱ្យផែនការ និងការអនុវត្តការងារឆាប់មានប្រសិទ្ធផល និងប្រសិទ្ធភាព។ ប៉ុន្តែ ដោយសារតែកត្តាជីវភាពបានធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនបានសម្រេចចិត្តធ្វើចំណាកស្រុកដើម្បីស្វែងរកការងារបន្ថែមប្រាក់ចំណូលក្នុងការផ្គត់ផ្គង់គ្រួសារ។ ចំពោះគ្រួសារក្រីក្រមួយចំនួនក៏បានឱ្យកូនឈប់រៀនដើម្បីជួយរកចំណូលក្នុងការផ្គត់ផ្គង់គ្រួសារ។ ម្យ៉ាងវិញទៀត យោងតាមសៀវភៅរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តតាកែវ និងខេត្តកណ្តាលបានឱ្យដឹងថាខេត្តកណ្តាលមានគ្រួសារចំនួន ២៨៦.១៧៥គ្រួសារ និងមានប្រជាជនសរុបចំនួន ១.២៤៣.៣៧២នាក់ ក្នុងចំណោមប្រជាជនសរុបក្នុងខេត្តកណ្តាល ចំនួនអ្នកធ្វើចំណាកស្រុកចំនួន ៤៦.៤៩០នាក់ ក្នុងនោះពលករក្នុងប្រទេសមានចំនួន ៣៧.៩៤៣នាក់ និងពលករក្រៅប្រទេសមានចំនួន ៨.៥៤៧នាក់។[៧០] ម្យ៉ាងវិញទៀត បើយោងទៅតាមសៀវភៅសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកណ្តាលបានឱ្យដឹងថា គិតត្រឹមត្រីមាសទី៤ ឆ្នាំ២០២២ ខេត្តកណ្តាលមានប្រជាជនចំណាកស្រុកប្រមាណ ២៥ ៦៦៧ នាក់។ ការធ្វើចំណាកស្រុកច្រើនបែបនេះជាហេតុមួយធ្វើឱ្យធនធានមនុស្សក្នុងខេត្តកណ្តាលបានធ្លាក់ចុះ។

[៧០] សៀវភៅរបាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តតាកែវ និងខេត្តកណ្តាល រៀបរៀងដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ខែធ្នូ ឆ្នាំ២០២០

ហេតុនេះ ទើបបញ្ហាធនធានមនុស្សជាកត្តាដ៏សំខាន់ក្នុងការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្តាល។

**ខ. កង្វះថវិកា**

បន្ទាប់ពីធនធានមនុស្ស ថវិកាក៏ជាកត្តាសំខាន់មួយក្នុងការអភិវឌ្ឍជាតិផងដែរ។ ដោយសារតែប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមជាច្រើនសតវត្ស បានធ្វើឱ្យកម្ពុជាបានខូចខាតហេដ្ឋារចនាសម្ព័ន្ធក្លាយជាប្រទេសក្រីក្រត្រូវក្រោកកសាងប្រទេសឡើងវិញ។ ក្នុងការកសាងប្រទេសចាំបាច់ត្រូវការថវិការជាច្រើន ដើម្បីការកសាងប្រទេសទាំងមូល។ ខេត្តកណ្តាល ចាំបាច់ត្រូវការថវិការជាច្រើនក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធទូទាំងខេត្ត។ បើផ្អែកទៅតាមសៀវភៅសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកណ្តាល រដ្ឋបាលបាលត្រូវចំណាយថវិកាសរុប ២៤៣ ៧២៧ ០០០ ០០០០ រៀល លើគម្រោងវិនិយោគបីឆ្នាំរំកិលខេត្ត។ បន្ថែមពីនោះ រដ្ឋបាលខេត្តកណ្តាល និងតាមបណ្តាមន្ទីរក្នុងខេត្តកណ្តាលក៏ត្រូវការកញ្ចប់ថវិការជាច្រើនបន្ថែមផងដែរ។ ខេត្តកណ្តាល ជាខេត្តមួយដែលកំពុងអភិវឌ្ឍន៍ ដែលទាមទារកញ្ចប់ថវិការជាច្រើនពិសេសគឺការវិនិយោគពីសំណាក់វិស័យឯកជនផងដែរដែលរួមចំណែកក្នុងការផ្តល់ហិរញ្ញប្បទានដើម្បីជួយអភិវឌ្ឍន៍ខេត្ត។

**គ. កង្វះបច្ចេកទេស**

ក្នុងការសាងសង់សំណង់នីមួយៗ ចាំបាច់ត្រូវមានបច្ចេកទេសត្រឹមត្រូវ បើពុំនោះទេនឹងមានបញ្ហាណាមួយកើតឡើងជាមិនខាន ពិសេសនោះគឺបង្កគ្រោះថ្នាក់ដល់ជីវិតរបស់ប្រជាពលរដ្ឋទៀតផង។ ខេត្តកណ្តាលសព្វថ្ងៃកំពុងស្ទុះស្ទាក្នុងការរៀបចំទាំងសោភ័ណភាព និងសណ្តាប់ធ្នាប់។ ចំពោះសោភ័ណភាព រដ្ឋបាលខេត្តកណ្តាលបានខិតខំកសាងនូវហេដ្ឋារចនាសម្ព័ន្ធជាច្រើន ដើម្បីសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ហេដ្ឋារចនាសម្ព័ន្ធនីមួយៗជៀសមិនផុតពីការប្រើប្រាស់បច្ចេកនោះទេដូចជា ស្ពាន ថ្នល់ សាលារៀន ការបំពាក់ភ្លើងស្តុប សាងសង់អគារ រោងចក្រ លំនៅស្ថាន។ល។ ទាំងនេះគឺសុទ្ធតែទាមទានូវការយកចិត្តទុកដាក់ និងអ្នកមានចេះដឹងយល់ដឹងពីយុទ្ធវិធីក្នុងការសាងសង់។ ដូចដែលយើងដឹងហើយថា កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ ហើយកាលពីសម័យកម្ពុជាប្រជាធិបតេយ្យ កម្ពុជាបានបាត់បង់ធនធានមនុស្សជាច្រើន ពិសេសគឺមនុស្សដែលមានជំនាញ ហើយបច្ចុប្បន្នកម្ពុជាក៏ពុំសូវមាននូវអ្នកជំនាញនោះទេ ប៉ុន្តែក៏មាននិស្សិតសិក្សាជំនាញការសាងសង់ផងដែរ តែក៏មិនទាន់គ្រប់គ្រាន់តាមតម្រូវនោះទេ។ ជាហេតុធ្វើឱ្យកម្ពុជាចាំបាច់ត្រូវជួលអ្នកជំនាញពីបរទេសដើម្បីសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេស ពិសេសក្នុងខេត្តកណ្តាល។ ក្នុងការជួលនេះធ្វើឱ្យមានការចំណាយថវិកាជាច្រើនផងដែរ។

ដូចនេះ ក្នុងការរៀបចំទាំងសណ្តាប់ធ្នាប់ និងសោភ័ណភាពមិនមែនជារឿងងាយស្រួលនោះទេទាមទារទាំងធនធានមនុស្ស ថវិកា បច្ចេកទេស។ តែមានបញ្ហាតែងមានដំណោះស្រាយ បើទោះបីជាការរៀបចំជួបនូវបញ្ហា តែរដ្ឋបាលខេត្តកណ្តាលក៏បានខិតខំក្នុងការកែប្រែខេត្តកណ្តាល ដើម្បីខេត្តកណ្តាលផងដែរ។

### ២.២.៣.២. ដំណោះស្រាយ

#### ក. ការបណ្តុះបណ្តាលធនធានមនុស្ស

ជាការពិតណាស់ ធនធានមនុស្សជាក្រុមមនុស្សដែលឈរជាសសរទ្រូងនៃប្រទេសជាតិ និងជាអ្នកចូលរួមស្វះស្វែងអភិវឌ្ឍន៍ប្រទេសជាតិឱ្យរីកចម្រើន។ ធនធាននៅទីនេះ មិនមែនសំដៅតែទៅលើមនុស្សដែលបញ្ចប់ការសិក្សានោះទេ ប៉ុន្តែនៅទីនេះ ធនធានមនុស្សសំដៅដល់មនុស្សដែលមាន ចំណេះដឹង ចំណេះធ្វើ កម្លាំងពលកម្ម។ល។ ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណ្ឌភាពខេត្តកណ្តាលអាចសម្រេចទៅបានដោយរលូន ដរាបណាខេត្តកណ្តាលមានបណ្តុំធនធានមនុស្សដែលមានទាំងសមត្ថភាព កម្លាំងលកម្ម ចំណេះដឹង ចំណេះធ្វើ ព្រមទាំងការសហការ និងការអធ្យាស្រ័យល្អអោយគ្នាទៅវិញទៅមក ដោយមិនរើសអើងអ្នកអវិជ្ជា ឬអ្នកដែលមិនបានបញ្ចប់ការសិក្សានោះទេ។ ការអភិវឌ្ឍខេត្ត មិនមែនជារឿងងាយស្រួលនោះទេ ប៉ុន្តែក៏មិនមែនជាបញ្ហាចោទនោះទេ បើខេត្តកណ្តាលមានប្រជាពលរដ្ឋដែលមានឧត្តមគតិ និងគោលដៅតែមួយ នោះគឺជួយគ្នាដើម្បីអភិវឌ្ឍន៍ខេត្តកណ្តាលឱ្យរីកចម្រើន។ ការបណ្តុះបណ្តាលធនធានមនុស្ស គឺមានសារៈសំខាន់ណាស់ចំពោះការភាពជោគជ័យសម្រាប់ផែនការបីឆ្នាំរំកិលរបស់ខេត្ត និងផែនការអភិវឌ្ឍខេត្តជាច្រើន។ គោលបំណងនៃការបណ្តុះបណ្តាលគឺដើម្បីបង្កើនសមត្ថភាពប្រជាពលរដ្ឋ និងមន្ត្រីរាជការថ្នាក់ក្រោមជាតិ។ លើសពីនេះ គឺផ្តល់ឱកាសដល់ប្រជាពលរដ្ឋដែលមិនមានជំនាញអាចសិក្សា និងទទួលយកចំណេះពីការបណ្តុះបណ្តាល។ ជាមួយគ្នានេះដែរ ការផ្លាស់ប្តូរនូវបច្ចេកវិទ្យា ត្រូវតែទាមទាឱ្យប្រជាពលរដ្ឋត្រូវតែមានការយល់ដឹង និងអាចដើរទាន់ភាពរីកចម្រើនរបស់ពិភពលោក។ ហេតុនេះ ការបណ្តុះបណ្តាលបណ្តាលធនធានមនុស្សត្រូវផ្តោតលើការបណ្តុះបណ្តាលចំណេះជំនាញ ព្រមទាំងអប់រំពីបច្ចេកវិទ្យាទំនើបៗដែលទើបតែរកឃើញផលិតចេញជារូបរាង។

#### ខ. ការចូលរួមពីប្រជាពលរដ្ឋ

ប្រជាជនជាផ្នែកមួយដ៏សំខាន់បំផុតក្នុងការរួមចំណែកចូលរួមសហការជាមួយសមត្ថកិច្ចក៏ដូចជាភាគីពាក់ព័ន្ធក្នុងការសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីជាផ្នែកមួយក្នុងការជួយដល់ការរៀបចំសណ្តាប់ធ្នាប់ និងសោភ័ណ្ឌភាពខេត្តកណ្តាល ដែលការចូលរួមក្រោមរូបភាពដូចជា៖

- ចូលរួមបណ្តុះបណ្តាលពីសំណាកមន្ត្រីរាជការ វិស័យឯកជន ឬអ្នកជំនាញ
- ចូលរួមក្នុងការអនុវត្តផែនការរបស់រាជរដ្ឋាភិបាល និងគោរពច្បាប់នានា ពិសេសច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីកាត់បន្ថយគ្រោះថ្នាក់ជាយថាហេតុ

- ចូលរួមរាយការណ៍ដល់អាជ្ញាធរ សមត្ថកិច្ច លើករណីខុសច្បាប់ផ្សេងៗ
- ចូលរួមអភិវឌ្ឍន៍ខ្លួនអោយក្លាយជាបុគ្គលដ៏មានសារៈសំខាន់
- ចូលរួមថែរក្សាទ្រព្យសម្បត្តិសាធារណៈ
- ចូលរួមបណ្តុះបណ្តាលយុវជនជំនាន់ក្រោយអោយក្លាយជាទំពាំងស្នងឫស្សី
- ចូលរួមថែរក្សាសណ្តាប់ធ្នាប់ ការលក់ដូរលើដងចំណីផ្លូវ និងថែរក្សាបរិស្ថាន
- យល់ដឹងនូវទិន្នន័យទំហំផ្លូវដែលបានដោះស្រាយផលប៉ះពាល់រួចហើយ
- រថយន្តដែលដឹកទំនិញមិនត្រូវដឹកលើសទម្ងន់កម្រិតកំណត់ចរាចរនៅលើដងផ្លូវកៅស៊ូមានរថយន្តល្មើសមួយចំនួនបើកបរគេចស្ថានីយថ្លឹងរថយន្ត។

**គ. ការចូលរួមពីសំណាក់រដ្ឋបាលខេត្ត សមត្ថកិច្ច និងអាជ្ញាធរខេត្តកណ្តាល**

- ស្នើសុំកិច្ចអន្តរាគមន៍ពីថ្នាក់ដឹកនាំខេត្ត និងស្នើសុំកិច្ចសហការពីរដ្ឋបាលក្រុង ស្រុក អាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់ការរំលោភដីចំណីផ្លូវ។
- ស្នើសុំបង្កើតគណៈកម្មការចម្រុះដឹកនាំដោយអភិបាលរងខេត្តចុះអនុវត្តជាក់ស្តែង ( រដ្ឋបាលខេត្តមិនទាន់បានសម្រេច )។
- បន្តប្រាស្រ័យទាក់ទងជិតស្និតជាមួយប្រជាពលរដ្ឋ និងស្វែងរកបញ្ហារបស់ប្រជាពលរដ្ឋ ព្រមទាំងដោះស្រាយវិវាទជូនប្រជាពលរដ្ឋទាន់ពេលវេលា
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈក្រុងតាខ្មៅលើវិស័យទេសចរណ៍។
- បង្កើតក្រុមការងារចម្រុះ ដឹកនាំដោយអភិបាលរងខេត្ត ចុះអនុវត្តជាក់ស្តែង ដោយរុះរើ និងអប់រំដល់ប្រជាពលរដ្ឋ ដែលសាងសង់សំណង់នៅលើដីចំណីផ្លូវ។
- ចុះអនុវត្តជាប្រចាំ ចាប់ផាកពិន័យ ឬឃាត់ទុករថយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់តាមច្បាប់ដែលមានជាធរមាន ដោយមិនលើកលែង។
- បន្តចុះអនុវត្តជាប្រចាំ ឆ្មក់ចាប់រថយន្តដែលល្មើសច្បាប់ដឹកទំនិញលើសទម្ងន់កម្រិតកំណត់ ដោយផាកពិន័យ ឬឃាត់ទុកតាមច្បាប់កំណត់។
- ចូលរួមធ្វើអន្តរាគមន៍ ជួយសង្គ្រោះប្រជាជន ពេលមានគ្រោះធម្មជាតិ ជំងឺរាតត្បាត និងគ្រោះថ្នាក់ផ្សេងៗ
- មន្ត្រីរាជការ ព្រមទាំងអាជ្ញាធរ ត្រូវបំពេញមុខងាររបស់ខ្លួនប្រកបដោយគណនេយ្យភាព ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋ។

# ជំពូកទី៣

# កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់

# ខេត្តកណ្តាល

# ជំពូកទី៣

# កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្តកណ្ដាល

ក្រុមប្រឹក្សាខេត្តកណ្ដាល បានដាក់ចេញនូវសេចក្ដីណែនាំស្ដីពីដំណើរការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៤-២០២៦) របស់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងខេត្ត។

## ៣.១. ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខេត្ត

### ៣.១.១. ស្ថានភាពសេដ្ឋកិច្ច

- កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការកើនឡើងគួរឱ្យកត់សំគាល់។ សូចនាករនៃអត្រាភាពក្រីក្រតាមទិន្នន័យមូលដ្ឋានបានបង្ហាញថា អត្រាភាពក្រីក្របានថយចុះមកនៅត្រឹម៣.៦៨% នាឆ្នាំ២០២២។ ផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រជាជនម្នាក់របស់ខេត្តកណ្ដាលបានកើនពីចំនួន ១.៨៦០ដុល្លារ នៅឆ្នាំ២០១៨ ដល់១.៩៩៧ ដុល្លារ នៅឆ្នាំ២០១៩ និងកើនដល់២,០៣៨ដុល្លា ក្នុងឆ្នាំ២០២០។
- ផលិតកម្មកសិកម្ម ការដាំដុះដំណាំស្រូវទទួលបានទិន្នផលកើនឡើងបរិមាណផលស្រូវសម្រាប់ផ្គត់ផ្គង់ស្បៀង និងមានលទ្ធភាពលក់លើទីផ្សារ។ ការដាំដុះដំណាំរួមផ្សំ បន្លែបង្ការ ដំណាំរយៈពេលវែង ដំណាំរយៈពេលខ្លី និងការចិញ្ចឹមសត្វលក្ខណៈគ្រួសារទទួលបានលទ្ធផលល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។
- ហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទទាំងផ្លូវទីប្រជុំជន និងផ្លូវជនបទ ធារាសាស្ត្រ អប់រំ សុខាភិបាលមានការអភិវឌ្ឍគួរឱ្យកត់សំគាល់។
- សកម្មភាពសេដ្ឋកិច្ចគ្រប់ប្រភេទមានការរីកចម្រើន ពិសេសការវិនិយោគទៅលើរោងចក្រ សហគ្រាសសិប្បកម្ម អាជីវកម្ម គ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានលទ្ធភាពផ្ដល់ការងារ ដល់កម្មករនិយោគជិតជាច្រើនទាំងក្នុងខេត្ត និងក្រៅខេត្ត។

### ៣.១.២. ស្ថានភាពសង្គមកិច្ច

- សេវាសុខាភិបាលសាធារណៈត្រូវបានកែលម្អការប្រើសេវាសុខាភិបាលប្រកបដោយប្រសិទ្ធភាព និងសមធម៌ដល់ប្រជាពលរដ្ឋទូទៅ ពិសេសគ្រួសារក្រីក្រនិងគ្រួសារងាយរងគ្រោះតាមរយៈមូលនិធិសមធម៌ និងបណ្ណសមធម៌។
- គោលការណ៍អប់រំសម្រាប់យើងផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនទាំងអស់បានទទួលការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងគ្រប់កម្រិតសិក្សា។

- សេវាសង្គមកិច្ចសម្រាប់ជួយជនរងគ្រោះ និងជនងាយរងគ្រោះគ្រប់ប្រភេទមានភាពប្រសើរឡើង។ ដោះស្រាយបញ្ហាជនអនាថា ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជួយជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស។ អនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ ជំរុញកម្មវិធីអប់រំ សីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរសម្រាប់ពង្រីកវប្បធម៌ អហឹង្សាក្នុងគ្រួសារ។
- បានអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ ការថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ ទាំងរូបិយ អរូបិយ អប់រំដល់ស្រទាប់យុវជន និងកុមារឱ្យយល់ដឹងច្បាស់អំពីតម្លៃនៃវប្បធម៌ទំនៀមទំលាប់ប្រពៃណីខ្មែរ ព្រមទាំងលើកកម្ពស់សេរីភាពខាងជំនឿ និងសាសនា ពង្រឹងសុខដុមនីយកម្មរវាងសាសនាទូទាំងខេត្ត។

### ៣.១.៣. ការប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ បរិស្ថាន និងការប្រែលប្រួលអាកាសធាតុ

- អនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលក្នុងវិស័យព្រៃឈើ ជលផល និងវិស័យគ្រប់គ្រងដីធ្លីតាមរយៈការផ្តល់កម្មសិទ្ធិស្របច្បាប់ជូនប្រជាពលរដ្ឋ ដោយអនុវត្តគោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីសម្រេចប្រកាសតំបន់វិនិច្ឆ័យតាមបណ្តាឃុំមួយចំនួន បំពេញសលាកបត្រ័ព៌តមានក្បាលដីបញ្ចូលក្នុងសម្រង់បញ្ជីឈ្មោះម្ចាស់ដីបានវាស់វែងក្បាលដីគូសក្បាលដីបានបំពេញទម្រង់បែបបទក្បាលដីចេញប័ណ្ណកម្មសិទ្ធិ ព្រមទាំងការចុះបញ្ជីដីលក្ខណៈជាប្រព័ន្ធចែកជូនប្រជាពលរដ្ឋជាម្ចាស់ដី។
- ពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីបរិស្ថាន ការគ្រប់គ្រងកាកសំណល់រឹង រាវ ការថែរក្សាតំបន់ការពារធម្មជាតិ ទប់ស្កាត់រាល់សកម្មភាពបំផ្លាញគុណភាពបរិស្ថាន អនុវត្តការគ្រប់គ្រងអភិរក្ស និងការអភិវឌ្ឍន៍ធនធានជលផល។
- ជំរុញសកម្មភាពអនាម័យដើម្បីលើកកម្ពស់សុខុមាលភាពប្រជាជន ជាពិសេសកាត់បន្ថយកង្វះទឹកស្អាតប្រើប្រាស់ បង្កើនការប្រើប្រាស់បង្គន់អនាម័យ និងបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល។

### ៣.១.៤. រដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានបានចូលរួមថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅមូលដ្ឋានបានល្អតាមរយៈការអនុវត្តន៍គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ការអនុវត្តន៍ច្បាប់ គោលនយោបាយរបស់រាជរដ្ឋាភិបាល។
- បានអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅមូលដ្ឋានទៅតាមគោលការណ៍ដែលបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

- សមត្ថភាពស្ថាប័ន និងមន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធរដ្ឋបាល ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ក៏ត្រូវបាន លើកកម្ពស់ ពង្រឹងពង្រីកថែមមួយកម្រិតទៀតតាមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា។
- ដំណើរការនៅការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត ក្រុង ស្រុក បានរួមចំណែកលើកកម្ពស់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋដោយផ្តោតលើគុណភាពសេវា អាចកាត់បន្ថយបានពេល វេលា និងការបង់កម្រៃមិនផ្លូវការដែលនាំឱ្យមានការថ្ងាំងថ្នាក់ពីប្រជាពលរដ្ឋ។

## ៣.២. គោលចំណង និងទិសដៅសំខាន់ៗនៅឆ្នាំខាងមុខ

ក្រុមប្រឹក្សាខេត្តកណ្តាលអាណត្តិទី៣ បានសម្រេចដាក់ចេញនូវ គោលនយោបាយណែនាំ ផ្នែកគោល នយោបាយ ដែលជាឧបករណ៍សម្រាប់តម្រង់ទិសរៀបចំផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ (២០២០-២០២៤) និង សេចក្តីណែនាំសម្រាប់រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ឈានទៅ សម្រេចនូវចក្ខុវិស័យក្នុងផែនការអភិវឌ្ឍខេត្ត។

### ៣.២.១. ផ្នែកសេដ្ឋកិច្ច

- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឱ្យសម្រេចបានកំណើនខ្ពស់ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ របស់ប្រជាពលរដ្ឋយ៉ាងតិច១% ក្នុងមួយឆ្នាំតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។
- លើកកម្ពស់ការអភិវឌ្ឍទាំងគុណភាព បរិមាណផលិតកម្មកសិកម្មរបស់ខេត្ត ដូចជាស្រូវ បន្លែ ផ្លែឈើ ផលិតផលពីសត្វដើម្បីបំពេញតម្រូវការក្នុងខេត្ត និងការនាំចេញ។
- ពង្រឹងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ពិសេសនៅថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់។
- លើកកម្ពស់ផលិតភាព និងសហគ្រិនភាពរបស់សហគ្រាសធុនធំ មធ្យម និងតូចព្រមទាំងពង្រីក លទ្ធភាព ទទួលបានបច្ចេកវិទ្យាជឿនលឿន ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់កម្មករ។
- ជំរុញការពង្រីកខ្សែបណ្តាញផ្គត់ផ្គង់អគ្គិសនីឱ្យបានគ្រប់ភូមិ ដោយផ្តល់សេវាអគ្គិសនីថ្លៃលក់ថាមពល អគ្គិសនីស្របតាមច្បាប់អគ្គិសនី។
- អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់គ្រប់ប្រភេទទាំងផ្លូវទីប្រជុំជន ផ្លូវជនបទ និងពង្រីកការគ្រប់គ្រង ការងារថែទាំផ្លូវថ្នល់។ បន្តខិតខំធ្វើឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកសាងផ្លូវជនបទ ជាជំហានៗ ពីផ្លូវក្រាលគ្រួសក្រហមមកជាផ្លូវបេតុង និងក្រាលកៅស៊ូ។

- លើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទឱ្យមានលក្ខណៈសម្បត្តិខាងបច្ចេកទេសគ្រប់គ្រាន់ដើម្បីចរាចរណ៍នៅលើផ្លូវសាធារណៈ។ ផ្សព្វផ្សាយអប់រំដល់ប្រជាជនទូទៅឱ្យបានយល់ដឹងច្បាស់អំពីច្បាប់ចរាចរណ៍ផ្លូវគោក។
- លើកកម្ពស់ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព តាមរយៈការពង្រឹងសមត្ថភាពសហគមន៍កសិករប្រើប្រាស់ទឹក ការស្តារ កសាង ថែទាំដើម្បីបង្កើនលទ្ធភាពស្រោចស្រព ជំរុញការងារបង្កបង្កើនផល ពង្រីកវារីវប្បកម្ម ការកាត់បន្ថយមហន្តរាយដែលបង្កឡើងដោយគ្រោះធម្មជាតិ និងមនុស្ស។
- អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ កាត់បន្ថយការធ្វើចំណាកស្រុកស្វែងរកការងារធ្វើ និងការបង្កើនកម្មវិធីបណ្តុះបណ្តាលអាជីវកម្មខ្នាតតូច មុខជំនាញគ្រួសារ ផ្តល់បច្ចេកទេសជំនាញ និងការយល់ដឹងអំពីការបង្កើនមុខរបរ។
- ផលិតផល ទំនិញធ្វើចរាចរនៅគ្រប់ទីកន្លែងតាមគោលការណ៍ប្រកួតប្រជែងតាមតម្លៃទីផ្សារ ពិសេសយកចិត្តទុកដាក់លើថ្លៃទំនិញកសិផលរបស់កសិករ។ ពិសេសពង្រឹងការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវាទប់ស្កាត់សកម្មភាពផលិត ការចែកចាយផលិតផលក្លែងក្លាយ និងផលិតផលគ្មានគុណភាព ខូចគុណភាព និងបន្តជំរុញចលនាភូមិមួយផលិតផលមួយ។
- គ្រប់គ្រងអភិវឌ្ឍន៍គោលដៅទេសចរណ៍សំខាន់ៗ ការកែលម្អសេវាទេសចរណ៍ និងបង្កើនផលិតផលទេសចរណ៍។ ចូលរួមការអនុវត្តទិសដៅនៃការអភិវឌ្ឍបៃតងតាមរយៈការបន្តជំរុញចលនាប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត ទីក្រុងបៃតង បង្កើនអនាម័យ ការដាំដើមឈើជាដើម។ បំផុសចលនាសកម្មភាពប្រើប្រាស់បច្ចេកវិទ្យាបៃតង
- កែលម្អហេដ្ឋារចនាសម្ព័ន្ធព្រំដែនសំដៅបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច សន្តិសុខសណ្តាប់ធ្នាប់។

### ៣.២.២. ផ្នែកសង្គមកិច្ច

- ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។
- លើកកម្ពស់ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។
- ជំរុញការសាងសង់ជួសជុលសាលារៀន ហេដ្ឋារចនាសម្ព័ន្ធអប់រំនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ពិសេសសាងសង់អនុវិទ្យាល័យក្នុងឃុំដែលនៅមិនទាន់មានអនុវិទ្យាល័យ។
- លើកកម្ពស់គុណភាពអប់រំនៅគ្រប់កម្រិតសិក្សា រួមទាំងសនិទានកម្មបុគ្គលិកអប់រំ គ្រូបង្រៀន សិស្សពូកែទាំងនៅបឋមសិក្សា និងមធ្យមសិក្សា។ ការផ្តល់សៀវភៅសិក្សាគោល សម្ភារៈបង្រៀន និងរៀន។

- អភិវឌ្ឍន៍ការងារអប់រំកាយ និងកីឡាសំដៅរួមចំណែកដល់ការលើកកម្ពស់សុខភាពប្រជាជនពង្រឹងសាមគ្គីភាព និងត្រៀមលក្ខណៈសម្បត្តិដើម្បីចូលរួមប្រកួតក្នុងព្រឹត្តិការណ៍កីឡាជាតិធំៗ។
- យកចិត្តទុកដាក់ផ្តល់សេវាសុខាភិបាលប្រកបដោយប្រសិទ្ធភាព សមធម៌ គុណភាពដល់ប្រជាជនទូទៅពិសេសគ្រួសារក្រីក្រ និងជនងាយរងគ្រោះ។
- ពង្រីកវិសាលភាពនៃសេវាសុខាភិបាលសាធារណៈឱ្យកាន់តែខិតចូលជិតប្រជាជន ពង្រឹងសកម្មភាពចុះផ្តល់សេវាសុខភាពតាមភូមិ អប់រំផ្សព្វផ្សាយពីជំងឺឆ្លងផ្សេងៗពិសេសជំងឺកូវីដ១៩ ពង្រីកយន្តការលើកលែងការបង់ថ្លៃសម្រាប់គ្រួសារក្រីក្រតាមរយៈការពិនិត្យព្យាបាលជំងឺគ្រួសារក្រីក្រ និងការពង្រីកមូលនិធិសមធម៌បង់ថ្លៃជំនួស។
- អភិវឌ្ឍន៍ការងារ និងបណ្តុះបណ្តាលតម្រង់ទិសវិជ្ជាជីវៈធ្វើឱ្យប្រជាជនមានការងារធ្វើ និងសិទ្ធិទទួលបានផលប្រយោជន៍ស្របច្បាប់របស់និយោជក និងកម្មករនិយោជិតត្រូវបានការពារដោយស្របច្បាប់ការងារ។
- ពង្រីកនិងពង្រឹងទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករនិយោជិត និងនិយោជក ព្រមទាំងពង្រឹងប្រព័ន្ធសុខភាពនិងសុវត្ថិភាពការងារនៅតាមរោងចក្រសហគ្រាសនានានៅក្នុងខេត្តឱ្យបានល្អប្រសើរ។
- លើកកម្ពស់អភិរក្ស អភិវឌ្ឍន៍វប្បធម៌ជាតិ និងថែរក្សាការពារបេតិកភ័ណ្ឌវប្បធម៌ជាតិទាំងរូបី និងអរូបីឱ្យស្ថិតស្ថេរគង់វង្ស។ បង្កើនផលិតផលវប្បធម៌ ផ្សព្វផ្សាយផលិតផល សិល្បៈសូនរូប និងសិល្បៈសិប្បកម្មពង្រីកសកម្មភាពវប្បធម៌លើគ្រប់ជំនាញ។ បង្កើនការអប់រំដល់ស្រទាប់យុវជន និងកុមារឱ្យបានយល់ដឹងច្បាស់អំពីតម្លៃនៃវប្បធម៌ ទំនៀមទម្លាប់ប្រពៃណីខ្មែរ ដែលជាអត្តសញ្ញាណរបស់ជាតិ។
- លើកកម្ពស់សេរីភាពខាងជំនឿ និងសាសនា ពង្រឹងសុខដុមនីយកម្មរវាងសាសនិកនៃគ្រប់សាសនានិងបន្តពង្រីកពុទ្ធិកសិក្សានៅគ្រប់កម្រិត។
- លើកកម្ពស់ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សំដៅរួមចំណែកធ្វើឱ្យសុខុមាលភាពរបស់ប្រជាជនមានស្ថានភាពកាន់តែប្រសើរ ដោយមានសេវាសង្គមកិច្ចសម្រាប់ជួយដល់ជនរងគ្រោះជនងាយរងគ្រោះគ្រប់ប្រភេទ ពិសេសសេវាថែទាំកុមារ អ្នករងផលប៉ះពាល់ពីជំងឺកូវីដ១៩ គ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងការពង្រីកសមាគមន៍មនុស្សចាស់។
- ពង្រឹងកម្មវិធីដោះស្រាយបញ្ហាជនអនាថា ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការជួយជនរងគ្រោះ និងជនងាយរងគ្រោះគ្រប់ប្រភេទការទប់ស្កាត់បទល្មើសគ្រឿងញៀន និងបង្កើតមណ្ឌលបន្សាបគ្រឿងញៀន។
- ពង្រឹងស្ថានភាពតួនាទីស្ត្រីឱ្យកាន់តែទទួលបាននូវកាលានុវត្តន៍ភាពការងារទូលំទូលាយ និងខ្លាំងក្លាថែមទៀតតាមរយៈការជំរុញ និងការបណ្តុះបណ្តាលការប៉ប៉ូនជំនាញ ការជំរុញភាពអង់អាចក្លាហាន

បង្កើនឱកាសរៀនសូត្រសម្រាប់ស្ត្រី ការបង្កើនសមាមាត្រការចូលរួមរបស់ស្ត្រីឱ្យបានកាន់តែច្រើនឡើង ក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្តនានា និងអភិបាលកិច្ចនៅក្នុងខេត្ត។

### ៣.២.៣. ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

- ជំរុញការចុះបញ្ជីដីធ្លី
- ផ្សព្វផ្សាយច្បាប់លិខិតបទដ្ឋានពាក់ព័ន្ធដីធ្លី
- រៀបចំកសាងប្លង់គោល
- គ្រប់គ្រងទប់ស្កាត់ការរំលោភបំពានកាន់កាន់កាប់ដីរដ្ឋ
- ពង្រឹងការអនុវត្តច្បាប់ឱ្យបានល្អប្រសើរជៀសវាងបាននូវទំនាស់ដីធ្លី
- ពង្រឹងយន្តការគ្រប់គ្រងថែរក្សាការពារធនធានជលផលដើម្បីធានាដល់និរន្តរភាពដោយៈ
  - ធ្វើការផ្សព្វផ្សាយបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ អំពីសារៈសំខាន់នៃធនធានធម្មជាតិចូលរួម ដាំ និងថែរក្សាកូនឈើព្រៃលិចទឹក
  - ពង្រឹងកិច្ចសហការ ជាមួយអាជ្ញាធរមូលដ្ឋានទប់ស្កាត់ការចាប់ទន្ទ្រានយកផ្ទៃបឹង អូរ ព្រែក និងការ នេសាទខុសច្បាប់ ព្រមទាំងបង្កើតសហគមន៍ថែរក្សាអន្លង់ជ្រៅៗបង្កើតស្រះដែលជាជម្រកត្រី ការពារតំបន់អភិរក្សដើម្បីអភិរក្សជលផល
  - ជំរុញការចិញ្ចឹមត្រីលក្ខណៈគ្រួសារ និងពង្រឹងសហគមន៍នេសាទ។
- ពង្រឹងយន្តការ ថែទាំបរិស្ថាន និងធនធានធម្មជាតិដោយៈ
  - អប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងដល់ ប្រជាពលរដ្ឋអំពីការបំពុលទឹក ការគ្រប់គ្រងកាកសំណល់ រឹង រាវ ការថែរក្សាការពារធនធានព្រៃឈើ ព្រៃលិចទឹក
  - សហការជាមួយអាជ្ញាធរដែនដីរកទីលានរៀបចំរណ្តៅចាក់សំរាម និងពង្រឹងយន្តការគ្រប់គ្រង ប្រមូលសំរាមនៅតាមទីផ្សារ និងទីប្រជុំជន
  - អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីរបៀបប្រើ ប្រាស់សារធាតុគីមីនានានៅក្នុងវិស័យកសិកម្មឱ្យ បានត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស និងអំពីផលប៉ះពាល់របស់វា។
- ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយ និងបម្រែបម្រួលអាកាសធាតុដោយៈ
  - បណ្តុះបណ្តាលគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ បន្តការយកចិត្ត ទុកដាក់យន្តការប្រកាសអាសន្នពីស្ថានភាពទឹកជំនន់ ផ្តល់ព័ត៌មានភាពរាំងស្ងួតឱ្យមានភាព ប្រសើរឡើង និងទាន់ពេលវេលា
  - ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីគ្រោះថ្នាក់ និងការត្រៀមបង្ការពេលមានគ្រោះភ័យ

- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ថ្នាក់ត្រូវត្រៀមមធ្យោបាយសម្ភារៈទីទួលសុវត្ថិភាព សម្រាប់ជួយពេលមានគ្រោះអាសន្ន និងក្រោយពេលគ្រោះអាសន្ន
- អប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋពីប្រែប្រួលអាកាសធាតុ។

### ៣.២.៤. រដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

➢ ពង្រឹងការផ្តល់សេវាសាធារណៈប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរដោយៈ

- ពង្រឹងការផ្តល់សេវាចុះអត្រានុកូលដ្ឋាន ធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋខ្មែរ និងគ្រប់គ្រងសៀវភៅចុះអត្រានុកូលដ្ឋាន
- បង្កើនសមត្ថភាពជំនាញរដ្ឋបាលដល់មន្ត្រី
- សាងសង់ពង្រីកអគាររដ្ឋបាល និងបំពាក់ឧបករណ៍ បរិក្ខា មធ្យោបាយ គ្រឿងសង្ហារឹម
- បង្កើនការយល់ដឹងពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទិន្នន័យ ព្រមទាំងបង្កើន សមត្ថភាពមន្ត្រីពាក់ព័ន្ធអំពីការវិភាគទិន្នន័យស្ថានភាពខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ចូលរួមប្រមូលទិន្នន័យឱ្យមានភាពសុក្រិត្យ
- បង្កើនកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធផ្តល់ការបណ្តុះបណ្តាល និងគាំទ្រដំណើរ ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់។

➢ ពង្រឹងយន្តការអនុវត្តច្បាប់ដើម្បីរក្សាសុវត្ថិភាពជូនប្រជាពលរដ្ឋដោយៈ

- ទប់ស្កាត់នូវការប្រព្រឹត្តិបទល្មើសនានា
- ធ្វើការត្រួតពិនិត្យជាប្រចាំ
- អប់រំផ្សព្វផ្សាយការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ការជួញដូរ ការប្រើប្រាស់ និងផលិតគ្រឿងញៀន ក្មេងទំនើង
- ផ្សព្វផ្សាយ ពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក និងទឹកព្រមទាំង ដំឡើងប៉ាណូ ស្លាកសញ្ញាចរាចរណ៍ ទាំងផ្លូវគោក និងផ្លូវទឹក
- រៀបចំ និងពង្រឹងក្រុមប្រជាការពារនៅតាមភូមិ ឃុំ សង្កាត់។
- កសាងសមត្ថភាពបន្ថែមដល់មន្ត្រីអនុវត្តច្បាប់។[៧១]

[៧១] សេចក្តីណែនាំ ស្តីពីដំណើរការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ (២០២៤-២០២៦) របស់ខេត្តកណ្តាល, លេខ ០១៧ ស.ណ.ន, ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើរួចមក យើងឃើញថាការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពខេត្តកណ្ដាល គឺមានភាពល្អប្រសើរពិសេសនោះគឺបានជួយដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងខេត្តកណ្ដាលឱ្យរស់នៅក្នុងលក្ខខណ្ឌជីវិតដ៏ល្អប្រសើរជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដ៏សម្បូរបែប និងទំនើបៗ ដូចទីក្រុងភ្នំពេញផងដែរ។ បន្ថែមពីនោះទៀតសោត ខេត្តកណ្ដាលបានកំពុងនឹងសម្រេចនូវសមិទ្ធិផលថ្មីជាច្រើនទៀតទៅតាមផែនការអភិវឌ្ឍន៍ខេត្ត ដែលជាហេដ្ឋារចនាសម្ព័ន្ធទាក់ទាញនូវវិនិយោគិនមកវិនិយោគក្នុងទឹកដីខេត្តកណ្ដាលឱ្យកាន់តែទទួលបាននូវការអភិវឌ្ឍ។ យ៉ាងណាមិញ បើទោះបីជាយើងឃើញមានភាពល្អលូតលាស់ក្នុងខេត្តកណ្ដាល ប៉ុន្តែនៅក្នុងខេត្តនៅពុំទាន់បានអភិវឌ្ឍន៍គ្រប់តំបន់នោះទេ ពិសេសនោះគឺនៅមានបញ្ហាផ្លូវថ្នល់ បណ្ដាញទឹកស្អាត បញ្ហាការគ្រប់គ្រងសម្រាម និងបញ្ហាប្រព័ន្ធលូ ដែលនៅតែបង្កការលំបាកដល់ប្រជាពលរដ្ឋនៅឡើយ។ ក្រៅពីសោភ័ណភាព អាជ្ញាធរខេត្តកណ្ដាលក៏បានយកទុកដាក់ខ្ពស់លើបញ្ហាសុវត្ថិភាពរបស់ប្រជាពលរដ្ឋ បានបង្រ្កាបបានបទល្មើសជាច្រើនករណី ព្យាមយាមការពារកាត់បន្ថយហានិភ័យ និងទទួលបានលទ្ធផលល្អគឺបញ្ហាអសន្តិសុខបានកាត់បន្ថយ ក្មេងទំនើង និងការប្រើប្រាស់គ្រឿងញៀននៅក្នុងតំបន់ក៏មានលក្ខណៈល្អប្រសើជាងមុន។

យ៉ាងណាមិញ ការសិក្សាស្រាវជ្រាវលើប្រធានខាងលើ បានធ្វើឱ្យនាងខ្ញុំទាំងពីរនាក់មានការយល់កាន់តែច្បាស់ពីបុព្វហេតុនៃការរៀបចំខេត្ត ពិសេសនោះគឺការរៀបចំសណ្ដាប់ធ្នាប់ ដែលជាកត្តាសំខាន់ទីមួយសម្រាប់ជីវិតរបស់ពលរដ្ឋ។ ក្រៅពីការរៀបចំសណ្ដាប់ធ្នាប់ ការរស់នៅក៏ជាកត្តាចាំបាច់ដែលយើងគ្រប់គ្នាត្រូវរស់នៅក្នុងសង្គមដែលលក្ខណៈសព្វបែបយ៉ាង គឺសំដៅដល់ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធបណ្ដាញទឹក ប្រព័ន្ធអគ្គីសនី សាលារៀន មន្ទីរពេទ្យ វត្តអារាម លំនៅដ្ឋាន ពិសេសនោះគឺកន្លែងលក់ដូរ គឺផ្សារ និងតាមដងផ្លូវ។ ការរៀបចំទាំងនេះមិនត្រឹមតែធ្វើឱ្យខេត្តកណ្ដាលទទួលបាននូវបរិយាកាសរស់នៅល្អនោះទេថែមទាំងទទួលបានជ័យលាភីជាទីក្រុងស្អាត ព្រមទាំងនឹងក្លាយជាតំបន់អភិវឌ្ឍន៍ទៀតផង ដែលធ្វើឱ្យខេត្តកណ្ដាលអាចទាក់ទាញនូវភ្ញៀវទេសចរ ពិសេសនោះគឺក្រុមវិនិយោគិនជាច្រើនដែលបានមកបង្កើនការងារដល់ប្រជាពលរដ្ឋខេត្តកណ្ដាល និងធ្វើឱ្យអត្រាការរកការងារក្រៅប្រទេសកាត់បន្ថយ។

សរុបជារួមមកយើងអាចសន្និដ្ឋានបានថា ការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាព ពិតជាមានសារៈសំខាន់ណាស់សម្រាប់ខេត្តកណ្ដាលទាំងមូល ពីព្រោះការរៀបចំសណ្ដាប់ធ្នាប់ និងសោភ័ណភាពទាំងនេះប្រៀបបាននឹងកូនសោរដែលចាក់ទៅរកភាពរីកចម្រើន និងការអភិវឌ្ឍក្នុងដែនដីនៃខេត្តកណ្ដាលព្រមទាំងធ្វើឱ្យទទួលបាននូវដែនដីមួយដែលពោរពេញទៅដោយភាពមានសណ្ដាប់ធ្នាប់ល្អ កាត់បន្ថយបទល្មើស ព្រមទាំងគ្រោះថ្នាក់ផ្សេងៗ។ លើសពីនេះ បានធ្វើគ្មានឬកាត់បន្ថយការបំពុលទាំងប្រាំមានដូចជា ការបំពុលដី ការបំពុលទឹក

ការបំពុលដោយសំណល់រឹង-រាង ការបំពុលសំឡេង និងការបំពុលខ្យល់។ បន្ថែមពីនេះទៅទៀត កូនសោរទាំងពីរនេះ ក៏បានផ្តល់ឱ្យនូវសុវត្ថិភាពទាំងបីរួមមាន សុវត្ថិភាពបុគ្គល សុវត្ថិភាពសម្ភារៈ និងសុវត្ថិភាពចំណីអាហារ។

ជាមួយគ្នានេះផងដែរ ការរៀបចំសណ្តាប់ធ្នាប់ក្នុងខេត្តកណ្តាល បានជំរុញឱ្យមានការរៀបចំសោភ័ណភាពល្អនាពេលថ្ងៃ ដែលយើងឃើញមានដូចជា ការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គម ផ្លូវទឹក ផ្លូវថ្នល់ ផ្លូវអាកាស ការផ្គត់ផ្គង់ទឹកស្អាតទឹកក្នុងក្រុង និងជាយក្រុង។ល។ ក្រៅពីសោភ័ណភាពនាពេលថ្ងៃ ក៏មានការរៀបចំសោភ័ណភាពពេលយប់ មានដូចជាការបំពាក់ភ្លើងពណ៌តាមសួនសាធារណៈ តាមដងផ្លូវ លើដងស្ពាន តាមផ្ទះប្រជាជនឬអគារក៏មានបំភ្លឺភ្លើងអគ្គីសនីគ្រប់ទីកន្លែង។ ការរៀបចំទាំងនេះ មិនត្រឹមតែធ្វើឱ្យខេត្តកណ្តាលមានការអភិវឌ្ឍនោះទេ ថែមទាំងធ្វើឲ្យប្រជាពលរដ្ឋខេត្តកណ្តាលទទួលបាននូវជីវិតល្អប្រសើរ រស់នៅក្នុងសន្តិភាពទាំងផ្លូវកាយ និងផ្លូវចិត្តថែមទៀតផង។

# អនុសាសន៍

# អនុសាសន៍

ដោយមើលឃើញពីស្ថានភាពជាក់ស្តែក្នុងខេត្តកណ្តាល យើងឃើញថា ការរៀបចំសណ្តាប់ធ្នាប់ និង សោភ័ណភាពខេត្តកណ្តាល គឺមានលក្ខណៈល្អប្រសើរក្រោមការដឹកនាំរបស់ថ្នាក់ដឹកនាំ អាជ្ញាធរមានសមត្ថកិច្ច និងការសហការចូលរួមពីសំណាក់ប្រជាពលរដ្ឋខេត្តកណ្តាលផ្ទាល់។ ជាមួយគ្នានេះផងដែរ យើងក៏ឃើញមាន បញ្ហាមួយចំនួនតូចដែលនៅតែកើតមានឡើងមានដូចជា ការលេងល្បែងស៊ីសង ការប្រើប្រាស់គ្រឿងញៀន ការ ចោលសំរាមតាមដងផ្លូវ គ្រោះថ្នាក់ចរាចរណ៍ ការបើកបរហួសល្បឿនកំណត់ ការលក់ដូរលើចិញ្ចើមផ្លូវ ផ្លូវខូច ជាដើម។ល។

ដោយមើលឃើញពីបញ្ហាខាងលើ នាងខ្ញុំទាំងពីរនាក់សូមសេចក្តីអនុញ្ញាតបញ្ចេញមតិសំណូមពរលើ បញ្ហាទាំងអស់នោះដែលមានដូចជា៖

- ស្នើសុំឱ្យអាជ្ញាធរជួយអនុវត្តច្បាប់និងរឹតបន្តឹងបន្ថែមលើការលេងល្បែងស៊ីសង
- ស្នើសុំឱ្យអាជ្ញាធររឹតបណ្តឹង និងបង្ក្រាបការប្រើប្រាស់គ្រឿងញៀនក្នុងមូលដ្ឋាន
- ស្នើសុំឱ្យមានការជួសជុលលើផ្លូវដែលមានបញ្ហា ដើម្បីបញ្ចៀសគ្រោះថ្នាក់ជាយថាហេតុ
- ស្នើសុំឱ្យដោះស្រាយប្រព័ន្ធលូ ដើម្បីបញ្ចៀសការលេចទឹកនារដូវវស្សា
- ស្នើសុំឱ្យមានការយាមល្បាតតាមមូលដ្ឋានឱ្យបានគ្រប់ភូមិ
- ស្នើសុំឱ្យអាជ្ញាធរបំពាក់កាម៉េរាសុវត្ថិភាពតាមដងផ្លូវ
- ស្នើសុំឱ្យមានការកសាងបណ្ណាល័យនៅតាមក្រុងទាំង៣នៃខេត្តកណ្តាល ដើម្បីលើកស្ទួយការអាន របស់សិស្ស និងប្រជាពលរដ្ឋ
- ស្នើសុំឱ្យប្រជាពលរដ្ឋចូលរួមថែរក្សាបរិស្ថាន អនាម័យ គោរពតាមច្បាប់ និងស្តាប់តាមការណែនាំរបស់ អាជ្ញាធរ
- ស្នើសុំឱ្យអាជ្ញាធរនៅតែពង្រឹងការអប់រំ ការលក់ដូររំលោភផ្លូវ ពិសេសនៅតាមផ្សារ
- ស្នើសុំឱ្យមានកម្មវិធីផ្សព្វផ្សាយពីចំណេះដឹងបរិស្ថានដល់ប្រជាពលរដ្ឋ ពិសេសអាជីវករឱ្យបានច្រើន
- ស្នើសុំឱ្យមានការបណ្តុះបណ្តាលជំនាញសំខាន់ៗដែលមានប្រយោជន៍ដល់ខេត្ត និងប្រជាពលរដ្ឋ
- ស្នើសុំឱ្យមានការរៀបចំសណ្តាប់ធ្នាប់សម្រាប់ការលក់ដូររបស់អាជីវករនៅតាមបណ្តោយផ្លូវមាត់ទន្លេ ក្រុងតាខ្មៅ
- ស្នើសុំឱ្យមានការផ្សព្វផ្សាយតំបន់ទេសចរណ៍ខេត្តកណ្តាលអោយកាន់តែទូលំទូលាយ
- ស្នើសុំឱ្យមានការបន្ថែមធុងសម្រាមតាមទីសាធារណៈពេលមានកម្មវិធីបុណ្យជាតិដូចជា ពិធីបុណ្យ ចូលឆ្នាំខ្មែរ ពិធីបុណ្យអុំទូក ការតាំងពិព័រជាដើម។

# ឯកសារយោង

# ឯកសារយោង

## ១. លិខិតបទដ្ឋានគតិយុត្ត

- អនុក្រឹត្យ ស្ដីពីការបង្កើតក្រុងអរិយក្សត្រខេត្តកណ្ដាល, លេខ ២៧២ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២
- អនុក្រឹត្យ ស្ដីពីការបង្កើតក្រុងសំពៅពូន នៃខេត្តកណ្ដាល, លេខ ២៧៩ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២
- អនុក្រឹត្យ ស្ដីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងតាខ្មៅជាមួយស្រុកស្អាង និងស្រុកកណ្ដាលស្ទឹងនៃខេត្តកណ្ដាល, លេខ ០៩អនក្រ.បក មាត្រា២, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩
- អនុក្រឹត្យ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩
- អនុក្រឹត្យ ស្ដីពីការប្ដូរស្រុកតាខ្មៅទៅជាក្រុងតាខ្មៅ, លេខ ២២៨ អនក្រ.បក, ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨
- សេចក្ដីព្រាង អនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និង ទីប្រជុំជន, មាត្រា១២
- ប្រកាស ស្ដីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តកណ្ដាល, លេខ ៨៨៦៣ ប្រក, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩
- សេចក្ដីសម្រេច ស្ដីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ខេត្តកណ្ដាល,លេខ ០០២ សសរ, ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨
- សេចក្ដីសម្រេច ស្ដីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ខេត្តកណ្ដាល, លេខ ០០២ សសរ, ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨, ទំព័រទី១៧
- សេចក្ដីណែនាំ ស្ដីពីដំណើរការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ (២០២៤-២០២៦) របស់ខេត្តកណ្ដាល, លេខ ០១៧ ស.ណ.ន, ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣
- គោលនយោបាយ ស្ដីពីភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព, លេខ ០១ គនប, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២១
- របាយការណ៍ ស្ដីពីផលប៉ះពាល់ដោយសារគ្រោះមហន្តរាយក្នុងខេត្តកណ្ដាលប្រចាំឆ្នាំ២០២៣

- របាយការណ៍ លទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២០ និងទិសដៅការងារបន្តរបស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកណ្តាល
- ស្ថិតិ និងសូចនាករអប់រំសាធារណៈ ២០២១-២០២២, ក្រសួងអប់រំ យុវជន និងកីឡា, នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

## ២. សៀវភៅ

- បទបង្ហាញ ស្តីពីលទ្ធផលការងារសន្តិសុខ សណ្តាប់ធ្នាប់ ឆ្នាំ២០២១ និងការងារអនុវត្តគោលនយោបាយភូមិ/ឃុំ សង្កាត់មានសុវត្ថិភាព និងទិសដៅការងារឆ្នាំ២០២២, រៀបរៀងដោយ សេនាធិការដ្ឋាន
- សៀវភៅ សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់រដ្ឋបាលខេត្តកណ្តាល
- សៀវភៅ នីតិនគរូបនីយវិទ្យា បណ្ឌិត អ៊ុន សកក្កដា បោះពុម្ពឆ្នាំ២០២៣-២០២៤
- សៀវភៅ របាយការណ៍លទ្ធផលទិន្នន័យស្ថិតិថ្នាក់ក្រោមជាតិខេត្តតាកែវ និងខេត្តកណ្តាល រៀបរៀងដោយនាយកដ្ឋានស្ថិតិថ្នាក់ក្រោមជាតិ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ខែធ្នូ ឆ្នាំ២០២០

## ៣. គេហទំព័រ

- គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://www.kandal.gov.kh/
- គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://www.kandal.gov.kh/detail/23391
- គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://demo.cambodia.gov.kh/tourism/
- គេហទំព័រ រដ្ឋបាលខេត្តកណ្តាល https://www.kandal.gov.kh/detail/15862
- គេហទំព័រ បេឡាជាតិសន្តិសុខសង្គម https://www.nssf.gov.kh/
- គេហទំព័រ https://thmeythmey.com/?page=detail&id=60547
- គេហទំព័រ https://m.postkhmer.com/national/2022-12-08-1703-244492.html
- គេហទំព័រ https://thmeythmey.com/?page=detail&id=60547
- គេហទំព័រ Fresh news https://freshnewsasia.com/index.php/en/localnews/229655-2022-01-30-05-38-05.html

- គេហទំព័រ FRESH NEWS https://m.freshnewsasia.com/index.php/en/localnews/328953-2024-02-17-03-22-46.html
- គេហទំព័រ Kampuchea Thmey Daily https://images.app.goo.gl/yJ2sggPRet2Eo5REA
- គេហទំព័រ CNC https://www.cnc.com.kh/detail/news/54180
- គេហទំព័រ វិទ្យុវាយោ VAYO FM RADIO https://www.vayofm.com/news/detail/114617-954.html
- គេហទំព័រ Open development Mekong https://data.opendevelopmentmekong.net/dataset/9c0daca4-3148-46b0-b81f-67fb78bccd41/resource/ea2db792-ad1f-4794-a021-2451faf06418

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

**ឧបសម្ព័ន្ធទី១៖** ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ចក្ខុវិស័យឆ្នាំ២០៣០

**ឧបសម្ព័ន្ធទី២៖** ឯកឧត្តម គង់ សោភ័ណ្ឌ បានចូលរួមកិច្ចប្រជុំស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅទីស្តីការក្រសួងមហាផ្ទៃ

**ឧបសម្ព័ន្ធទី៣៖** សិក្ខាសាលា ស្តីពីការយល់ដឹងពីការធ្វើអាជីវកម្ម ដើម្បីកាត់បន្ថយបញ្ហាប្រឈមផ្នែកផ្លូវច្បាប់

**ឧបសម្ព័ន្ធទី៤៖** ការរៀបចំទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា ក្រោមប្រធានបទ«ការកែប្រែគុណភាពដីរហោឋានកម្ម និងភាពធន់នឹងគ្រោះរាំងស្ងួត» នៅក្នុងបរិវេណវត្តកែវកុមារនេត្រ ហៅវត្តព្រែកក្មេង ភូមិព្រែកក្មេង សង្កាត់ព្រែកក្មេង ក្រុងអរិយក្សត្រ ក្រោមអធិបតីភាព ឯកឧត្តម ជ្រិន សុខា អនុរដ្ឋលេខាធិការ

**ឧបសម្ព័ន្ធទី៥៖** ប្រធានមន្ទីរបរិស្ថានខេត្តកណ្តាលអប់រំ ផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹងដល់អាជីវករ និងពលរដ្ឋជុំវិញការទុកដាក់សម្រាមឱ្យត្រឹមត្រូវ

**ឧបសម្ព័ន្ធទី៦៖** ក្រុងតាខ្មៅទទួលបានពានរង្វាន់ ជាទីក្រុងទេសចរណ៍ស្អាត អាស៊ាន លើកទី២ នៅឆ្នាំ២០២២

**ឧបសម្ព័ន្ធទី៧៖** ក្បួនដង្ហែពានរង្វាន់ជាទីក្រុងទេសចរណ៍ស្អាត អាស៊ាន លើកទី២ នៅក្រុងតាខ្មៅ

**ឧបសម្ព័ន្ធទី៨៖** ចុះបង្ក្រាបទីតាំងវេចខ្ចប់កែច្នៃ ចែកចាយប្រេងម៉ាស៊ីនក្លែងក្លាយ

**ឧបសម្ព័ន្ធទី៩៖** ការសម្ពោធអាគារវះកាត់ និងសម្ភពថ្មីនៃមន្ទីរពេទ្យបង្អែកជ័យជំនះ

**ឧបសម្ព័ន្ធទី១០៖** តំបន់ទេសចរណ៍ខេត្តកណ្តាល

**ឧបសម្ព័ន្ធទី១១៖** សោភ័ណភាពខេត្តកណ្តាលនាពេលថ្ងៃ

**ឧបសម្ព័ន្ធទី១២៖** សោភ័ណភាពខេត្តកណ្តាលនាពេលយប់

**ឧបសម្ព័ន្ធទី១៣៖** កំពង់ចម្លងភ្នំពេញ-អរិយក្សត្រ

**ឧបសម្ព័ន្ធទី១៤៖** ការសម្របសម្រួលចរាចរណ៍ដល់សិស្សានុសិស្សដើម្បីរក្សាសណ្តាប់ធ្នាប់ និងសុវត្ថិភាព

**ឧបសម្ព័ន្ធទី១៥៖** សកម្មភាព និងការការពារសុវត្ថិភាពនាសង្ក្រាន្តខេត្តកណ្តាល

**ឧបសម្ព័ន្ធទី១៦៖** ការការពារសុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងពេលបុណ្យអុំទូក

**ឧបសម្ព័ន្ធទី១៧៖** ទិដ្ឋភាពក្រុងអរិយក្សត្រ

## ២. ឧបសម្ព័ន្ធគតិយុត្ត

**ឧបសម្ព័ន្ធទី១៖** អនុក្រឹត្យ ស្តីពីការប្តូរស្រុកតាខ្មៅទៅជាក្រុងតាខ្មៅ, លេខ ២២៨ អនក្រ.បក, ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងតាខ្មៅជាមួយស្រុកស្អាង និងស្រុកកណ្តាលស្ទឹងនៃខេត្តកណ្តាល, លេខ ០៩អនក្រ.បក, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យ ស្តីពីការបង្កើតក្រុងសំពៅពូន នៃខេត្តកណ្តាល, លេខ ២៧៩ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២

**ឧបសម្ព័ន្ធទី៤៖** អនុក្រឹត្យ ស្តីពីការបង្កើតក្រុងអរិយក្សត្រខេត្តកណ្តាល, លេខ ២៧២ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២

**ឧបសម្ព័ន្ធទី៥៖** អនុក្រឹត្យ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ,លេខ ២១៦ អនក្រ.បក, ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៨

**ឧបសម្ព័ន្ធទី៦៖** ប្រកាស ស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តកណ្តាល, លេខ ៨៨៦៣ ប្រក, ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩

**ឧបសម្ព័ន្ធទី៧៖** គោលនយោបាយ ស្តីពី ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព, លេខ ០១ គនប, ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២១

**ឧបសម្ព័ន្ធទី៨៖** សេចក្តីណែនាំ ស្តីពីដំណើរការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ (២០២៤-២០២៦) របស់ខេត្តកណ្តាល, លេខ០១៧ ស.ណ.ន, ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣

**ឧបសម្ព័ន្ធទី៩៖** សេចក្តីជូនដំណឹង ស្តីពីការរៀបចំសង្ក្រាន្តខេត្តកណ្តាលដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ គ.ស. ២០២៤

**ឧបសម្ព័ន្ធទី១០៖** សេចក្តីសម្រេច ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ខេត្តកណ្តាល, ០០២ សសរ, ចុះថ្ងៃ៥ ខែកក្កដា ឆ្នាំ២០១៨

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធរូបភាព

## ឧបសម្ព័ន្ធទី១៖ ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ចក្ខុវិស័យឆ្នាំ២០៣០



**ឧបសម្ព័ន្ធទី២៖ ឯកឧត្តម គង់ សោភ័ណ្ឌ បានចូលរួមកិច្ចប្រជុំស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ នៅទីស្តីការក្រសួងមហាផ្ទៃ**





# ឧបសម្ព័ន្ធទី៣៖ សិក្ខាសាលា ស្តីពី ការយល់ដឹងពីការធ្វើអាជីវកម្ម ដើម្បីកាត់បន្ថយបញ្ហាប្រឈមផ្នែកផ្លូវច្បាប់






**ឧបសម្ព័ន្ធទី៤៖ ការរៀបចំទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា ក្រោមប្រធានបទ «ការកែប្រែគុណភាពដីរហោឋានកម្ម និងភាពធន់នឹងគ្រោះរាំងស្ងួត» នៅក្នុងបរិវេណវត្តកែវកុមារនេត្រ ហៅវត្តព្រែកក្មេង ភូមិព្រែកក្មេង សង្កាត់ព្រែកក្មេង ក្រុងអរិយក្សត្រ ក្រោមអធិបតីភាព ឯកឧត្តម ឡើន សុខា អនុរដ្ឋលេខាធិការ**





## ឧបសម្ព័ន្ធទី៥៖ ប្រធានមន្ទីរបរិស្ថានខេត្តកណ្តាលអប់រំ ផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹង ដល់អាជីវករ និងពលរដ្ឋជុំវិញការទុកដាក់សម្រាមឱ្យត្រឹមត្រូវ






## ឧបសម្ព័ន្ធទី៦៖ ក្រុងតាខ្មៅទទួលបានពានរង្វាន់ ជាទីក្រុងទេសចរណ៍ស្អាត អាស៊ាន លើកទី២ នៅឆ្នាំ២០២២



## ឧបសម្ព័ន្ធទី៧៖ ក្បួនដង្ហែពានរង្វាន់ជាទីក្រុងទេសចរណ៍ស្អាត អាស៊ាន លើកទី២ នៅក្រុងតាខ្មៅ







## ឧបសម្ព័ន្ធទី៨ ៖ ចុះបង្ក្រាបទីតាំងវេចខ្ចប់កែច្នៃ ចែកចាយ ប្រេងម៉ាស៊ីនក្លែងក្លាយ



## ឧបសម្ព័ន្ធទី៩៖ ការសម្ពោធអាគារវះកាត់ និងសម្ភពថ្មីនៃមន្ទីពេទ្យបង្អែកជ័យជំនះ





# ឧបសម្ព័ន្ធទី១០ ៖ តំបន់ទេសចរណ៍ខេត្តកណ្ដាល

វត្តវិហារសួគ៌





រមណីយដ្ឋានគៀនស្វាយក្រៅ









## រមណីយដ្ឋានព្រែកលាប និងបាក់ខែង






## រមណីយដ្ឋានភ្នំព្រះរាជទ្រព្យ(ភ្នំឧដុង្គ)






## រមណីយដ្ឋានស្គាងភ្នំ









## សួនសត្វភ្នំពេញសាហ្វារី










រមណីយដ្ឋានភ្នំប្រសិទ្ធិ









រមណីយដ្ឋានខ្សាច់កោះដាច់







# ឧបសម្ព័ន្ធទី១១៖ សោភ័ណភាពខេត្តកណ្ដាលនាពេលថ្ងៃ




















# ឧបសម្ព័ន្ធទី១២៖ សោភ័ណភាពខេត្តកណ្តាលនាពេលយប់













មាត់ទន្លេក្រុងតាខ្មៅ







ស្ពានថ្មក្រុងតាខ្មៅ





ស្ពានព្រែកសំរោងក្រុងតាខ្មៅ



រង្វង់មូលសំពៅក្រុងសំពៅពូន



# ឧបសម្ព័ន្ធទី១៣៖ កំពង់ចម្លងភ្នំពេញ-អរិយក្សត្រ










## ឧបសម្ព័ន្ធទី១៤៖ ការសម្របសម្រួលចរាចរណ៍ដល់សិស្សានុសិស្ស ដើម្បីរក្សាសណ្ដាប់ធ្នាប់ និងសុវត្ថិភាព









## ឧបសម្ព័ន្ធទី១៥៖ សកម្មភាព និងការការពារសុវត្ថិភាពនាសង្ក្រាន្តខេត្តកណ្ដាល









# ឧបសម្ព័ន្ធទី១៦៖ ការការពារសុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងពេលបុណ្យអុំទូក











# ឧបសម្ព័ន្ធទី១៧៖ ទិដ្ឋភាពក្រុងអរិយក្សត្រ





# ឧបសម្ព័ន្ធគតិយុត្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ០៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងតាខ្មៅ ជាមួយស្រុកស្អាង និងស្រុកកណ្តាលស្ទឹង នៃខេត្តកណ្តាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងតាខ្មៅ ជាមួយស្រុកស្អាង និងស្រុកកណ្ដាលស្ទឹង នៃខេត្តកណ្ដាល ដោយកាត់យកឃុំចំនួន០៤ ពីស្រុកស្អាងគឺ ឃុំស្វាយរលំ ឃុំកោះអន្លង់ចិន ឃុំសិត្បូ ឃុំកោខ្ពស់ និងដីមួយផ្នែកនៃស្រុកកណ្ដាលស្ទឹង មកឲ្យក្រុងតាខ្មៅ។

ផ្អែកតាមការកែសម្រួលនេះ ព្រំប្រទល់រដ្ឋបាលរវាងក្រុងតាខ្មៅ ជាមួយស្រុកស្អាង និងស្រុកកណ្ដាល-ស្ទឹង នៃខេត្តកណ្ដាល ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានប្តូរឃុំចំណុះក្រុងតាខ្មៅ នៃខេត្តកណ្ដាល ទៅជាសង្កាត់ មានដូចខាងក្រោម៖

- ឃុំស្វាយរលំ ទៅជា សង្កាត់ស្វាយរលំ
- ឃុំកោះអន្លង់ចិន ទៅជា សង្កាត់កោះអន្លង់ចិន
- ឃុំសិត្បូ ទៅជា សង្កាត់សិត្បូ
- ឃុំកោខ្ពស់ ទៅជា សង្កាត់កោខ្ពស់។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តកណ្ដាល គណៈអភិបាលខេត្តកណ្ដាល ក្រុមប្រឹក្សាក្រុងតាខ្មៅ គណៈអភិបាលក្រុងតាខ្មៅ ក្រុមប្រឹក្សាស្រុកស្អាង គណៈអភិបាលស្រុកស្អាង ក្រុមប្រឹក្សាស្រុកកណ្ដាលស្ទឹង គណៈអភិបាលស្រុកកណ្ដាលស្ទឹង និងក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៣ កើត ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៩

**សាយអារដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការប្តូរស្រុកតាខ្មៅ ទៅជាក្រុងតាខ្មៅ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង សុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**សម្រេច**

**មាត្រា ១.-**

ត្រូវបានប្តូរ ស្រុកតាខ្មៅ ទៅជា ក្រុងតាខ្មៅ នៃខេត្តកណ្តាល ។

**មាត្រា ២.-**

ត្រូវបានប្តូរ ឃុំ ដូចមានឈ្មោះខាងក្រោម ទៅជា សង្កាត់ នៃក្រុងតាខ្មៅ :

១- ឃុំ តាក្តុល ទៅជា សង្កាត់ តាក្តុល

២- ឃុំ ព្រែកឫស្សី ទៅជា សង្កាត់ ព្រែកឫស្សី

៣- ឃុំ ដើមមៀន ទៅជា សង្កាត់ ដើមមៀន

៤- ឃុំ តាខ្មៅ ទៅជា សង្កាត់ តាខ្មៅ

៥- ឃុំ ព្រែកហូរ ទៅជា សង្កាត់ ព្រែកហូរ

៦- ឃុំ កំពង់សំណាញ់ ទៅជា សង្កាត់ កំពង់សំណាញ់ ។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុងតាខ្មៅ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តកណ្តាល អភិបាលក្រុងតាខ្មៅ និងក្រុមប្រឹក្សាសង្កាត់ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៨*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៦៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុងសំពៅពូន នៃខេត្តកណ្ដាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣
- **យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

## សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត **ក្រុងសំពៅពូន** នៃខេត្តកណ្តាល ដោយកាត់យកឃុំចំនួន ០៥ ពីស្រុកកោះធំ គឺឃុំឈើខ្មៅ ឃុំព្រែកជ្រៃ ឃុំព្រែកស្តី ឃុំជ្រោយតាកែវ និងឃុំសំពៅពូន។

ព្រំប្រទល់រដ្ឋបាល **ក្រុងសំពៅពូន** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

**ក្រុងសំពៅពូន** មានសង្កាត់ចំនួន០៥គឺសង្កាត់ឈើខ្មៅ សង្កាត់ព្រែកជ្រៃ សង្កាត់ព្រែកស្តី សង្កាត់ជ្រោយតាកែវ និងសង្កាត់សំពៅពូន។

ទីតាំងរដ្ឋបាល **ក្រុងសំពៅពូន** ត្រូវស្ថិតនៅក្នុងសង្កាត់សំពៅពូន។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល **ក្រុងសំពៅពូន** ត្រូវអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាក្រុងសំពៅពូន និងក្រុមប្រឹក្សាស្រុកកោះធំ ត្រូវអនុលោមតាមមាត្រា១៨ថ្មី នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា៣ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តកណ្តាល គណៈអភិបាលខេត្តកណ្តាល ក្រុមប្រឹក្សាស្រុកកោះធំ គណៈអភិបាលស្រុកកោះធំ និងក្រុមប្រឹក្សាឃុំពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ២៧៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតក្រុងអរិយក្សត្រ នៃខេត្តកណ្ដាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ស្ដីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី៣
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត ក្រុងអរិយក្សត្រ នៃខេត្តកណ្ដាល ដោយកាត់យកឃុំចំនួន ០៦ ពីស្រុកខ្សាច់កណ្ដាល គឺឃុំបាក់ដាវ ឃុំកោះឧកញ៉ាតី ឃុំព្រែកអំពិល ឃុំព្រែកលួង ឃុំព្រែកតាកូវ និងឃុំស្វាយជ្រំ និងឃុំចំនួន ០៥ ពីស្រុកល្វាឯម គឺឃុំអរិយក្សត្រ ឃុំសារិកាកែវ ឃុំពាមឧកញ៉ាអុង ឃុំព្រែកក្មេង និងឃុំបារុង។

ព្រំប្រទល់រដ្ឋបាល ក្រុងអរិយក្សត្រ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ក្រុងអរិយក្សត្រ មានសង្កាត់ចំនួន១១ គឺសង្កាត់បាក់ដាវ សង្កាត់កោះឧកញ៉ាតី សង្កាត់ព្រែកអំពិល សង្កាត់ព្រែកលួង សង្កាត់ព្រែកតាកូវ សង្កាត់ស្វាយជ្រំ សង្កាត់អរិយក្សត្រ សង្កាត់សារិកាកែវ សង្កាត់ពាមឧកញ៉ាអុង សង្កាត់ព្រែកក្មេង និងសង្កាត់បារុង។

ទីតាំងរដ្ឋបាល ក្រុងអរិយក្សត្រ ត្រូវស្ថិតនៅក្នុងសង្កាត់អរិយក្សត្រ។

**មាត្រា ៣.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុងអរិយក្សត្រ ត្រូវអនុលោមតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៤.-**

ការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាក្រុងអរិយក្សត្រ ក្រុមប្រឹក្សាស្រុកខ្សាច់កណ្ដាល និងក្រុមប្រឹក្សាស្រុកល្វាឯម ត្រូវអនុលោមតាមមាត្រា១៨ថ្មី នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា៣ថ្មី នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធក្រុមប្រឹក្សាខេត្តកណ្ដាល គណៈអភិបាលខេត្តកណ្ដាល ក្រុមប្រឹក្សាស្រុកខ្សាច់កណ្ដាល គណៈអភិបាលស្រុកខ្សាច់កណ្ដាល ក្រុមប្រឹក្សាស្រុកល្វាឯម គណៈអភិបាលស្រុកល្វាឯម និងក្រុមប្រឹក្សាឃុំពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ [illegible]កើត ខែ[illegible] ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ៨ ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៣១៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត របស់ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង របស់ក្រុមប្រឹក្សានិងគណៈអភិបាលស្រុក ព្រមទាំងទំនាក់ទំនងការងាររវាងរដ្ឋបាលខេត្ត ជាមួយរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ក្នុងខេត្ត និងរដ្ឋបាលទាំងនេះជាមួយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

**មាត្រា ២.-**

រដ្ឋបាលខេត្តដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត។

រដ្ឋបាលក្រុងដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលក្រុង។

រដ្ឋបាលស្រុកដែលប្រើក្នុងអនុក្រឹត្យនេះ គឺសំដៅទៅលើក្រុមប្រឹក្សានិងគណៈអភិបាលស្រុក។

**មាត្រា ៣.-**

ខេត្ត ក្រុង ស្រុក ត្រូវគ្រប់គ្រងតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចិរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ។

**មាត្រា ៤.-**

ខេត្ត ក្រុង ស្រុក ឃុំ និងសង្កាត់ក្នុងខេត្ត ត្រូវមានក្រុមប្រឹក្សារៀង១ខ្លួនជាតំណាង ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

**មាត្រា ៥.-**

រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ និងរដ្ឋបាលសង្កាត់ ទទួលសិទ្ធិអំណាចរបស់ខ្លួនដោយរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តដទៃទៀតដែលស្របនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

## ជំពូកទី២

## រដ្ឋបាលខេត្ត

### ផ្នែកទី១

### ក្រុមប្រឹក្សាខេត្ត

**មាត្រា ៦.-**

ក្រុមប្រឹក្សាខេត្តដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈ

ជាអ្នកការពារនិងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ៧.-**

ក្រុមប្រឹក្សាខេត្ត ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាដែលនៅជាធរមាន។

**មាត្រា ៨.-**

ក្រុមប្រឹក្សាខេត្ត មានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិភូកម្ម ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ៩.-**

ក្នុងអំឡុងត្រីមាសទី៤នៃឆ្នាំនីមួយៗ ក្រុមប្រឹក្សាខេត្តត្រូវរៀបចំឱ្យមានវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នៅតាមក្រុងនិងស្រុកនានាក្នុងខេត្ត។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ ត្រូវចូលរួមដោយសមាជិកក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត សមាជិកក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង សមាជិកក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក សមាជិកក្រុមប្រឹក្សាឃុំ សមាជិកក្រុមប្រឹក្សាសង្កាត់ក្នុងខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធដទៃទៀតតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត។

វេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះ មានគោលបំណងដើម្បីឱ្យក្រុមប្រឹក្សាខេត្តជម្រាបជូនក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ ឬ/និងអ្នកពាក់ព័ន្ធនានា អំពីសកម្មភាពរបស់ក្រុមប្រឹក្សាខេត្តក្នុងរយៈពេលមួយ(០១)ឆ្នាំ ការឆ្លើយតបចំពោះសំណើ សំណូមពរនានារបស់ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ សហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ការពិភាក្សាស្រាយបំភ្លឺអំពីបញ្ហានានាដល់អ្នកចូលរួម និងការប្រមូលមតិយោបល់នានាពីអ្នកចូលរួម ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន។

ប្រធានក្រុមប្រឹក្សាខេត្ត ជាអ្នកសម្របសម្រួលក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះ។

គណៈអភិបាលខេត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន ត្រូវធ្វើការបូកសរុប វាយតម្លៃអំពីលទ្ធផលនៃវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់នេះយ៉ាងយូរដប់ប្រាំ(១៥)ថ្ងៃបន្ទាប់។ ក្នុងការបូកសរុបវាយតម្លៃនេះ ត្រូវលើកឡើងនូវគោលការណ៍ វិធានការ ដើម្បីលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការរបស់មូលដ្ឋាន ក្នុងក្របខ័ណ្ឌតួនាទីសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត។ ចំពោះកិច្ចការទាំងឡាយណា ដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀត រដ្ឋបាលខេត្តត្រូវពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាដែលពាក់ព័ន្ធទាំងនោះ ដើម្បីលើកឡើងអំពីគោលការណ៍ វិធានការ ដោះស្រាយ

តាមសមត្ថកិច្ចរៀងៗខ្លួន។ ចំពោះកិច្ចការដែលពាក់ព័ន្ធតួនាទី សមត្ថកិច្ចរបស់ថ្នាក់ជាតិ រដ្ឋបាលខេត្តត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រសួងមហាផ្ទៃ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំបន្ថែមទៀតអំពីការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់តាមការចាំបាច់។

**មាត្រា ១០.-**

ក្រុមប្រឹក្សាខេត្ត ត្រូវបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិនិងសេចក្តីសម្រេចខាងប្រតិបត្តិ តាមរយៈដីកា និងសេចក្តីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្តីសម្រេចទាំងនោះ ត្រូវបានអនុវត្តដោយមានការតាមដាននិងវាយតម្លៃជាប្រចាំ។

**មាត្រា ១១.-**

កិច្ចប្រជុំក្រុមប្រឹក្សាខេត្ត អាចយកជាការបានលុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន។

សេចក្តីសម្រេចទាំងឡាយណា ដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សារបស់ខ្លួន មិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវណែនាំ ឬអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ ដើម្បីឱ្យក្រុមប្រឹក្សាកែតម្រូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះឡើងវិញ។

**មាត្រា ១២.-**

ក្រុមប្រឹក្សាខេត្ត អាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការឬអនុគណៈកម្មាធិការឬក្រុមការងារនានាដើម្បីស្រាវជ្រាវរៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេចតាមការចាំបាច់។ ក្នុងករណីនេះ គណៈអភិបាលខេត្តត្រូវដឹកនាំនាយករដ្ឋបាលសាលាខេត្ត និងទីចាត់ការពាក់ព័ន្ធនៃសាលាខេត្ត ដើម្បីផ្តល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។

គណៈអភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវធ្វើការសម្របសម្រួល ណែនាំដល់ទីចាត់ការនានានៃសាលាខេត្ត រៀបចំសេចក្តីព្រាងដីកា ឬសេចក្តីព្រាងសេចក្តីសម្រេច ដើម្បីដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យពិភាក្សា និងអនុម័ត។

អភិបាលខេត្ត ត្រូវណែនាំនាយករដ្ឋបាលសាលាខេត្ត ឱ្យរៀបចំដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច ឱ្យស្របតាមទម្រង់ដែលកំណត់ ដើម្បីដាក់ជូនប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន និងត្រូវប្រថាប់ត្រារដ្ឋបាលខេត្ត។

ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យអភិបាលខេត្តចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្តីសម្រេចទាំងឡាយណាដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

**មាត្រា ១៣.-**

ប្រធានក្រុមប្រឹក្សាខេត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានសិទ្ធិចុះហត្ថលេខានិងប្រថាប់ត្រារដ្ឋបាលខេត្តលើ :

- ដីកាឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាខេត្តបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ តាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាខេត្ត
- កំណត់ហេតុប្រជុំដែលត្រូវបានអនុម័តដោយអង្គប្រជុំក្រុមប្រឹក្សាខេត្ត
- សំណើដកហូតអភិបាលខេត្តឬអភិបាលរងខេត្តចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត តាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា១៥២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាខេត្ត
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តរយៈពេលដប់ពីរ(១២)ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាខេត្ត
- កិច្ចការដទៃទៀតដែលតម្រូវដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា។

គណៈអភិបាលខេត្ត ត្រូវជួយក្រុមប្រឹក្សារបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារក្នុងចំណុចគំនូសទី៤។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចចេញសេចក្តីណែនាំអំពីទម្រង់នៃឯកសារខាងលើតាមការចាំបាច់។

**មាត្រា ១៤.-**

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ ដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលខេត្ត និងវិធានការ បែបបទ នីតិវិធីចាត់ចែងការងារ តាមការចាំបាច់ដែលទាក់ទងទៅនឹង :

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីដែលស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាខេត្ត
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលខេត្ត
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត

- ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាខេត្ត ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនិងទទួលតាមដានការងារនានាតាមតម្រូវការរបស់ក្រុមប្រឹក្សាខេត្ត
- ការគ្រប់គ្រងនិងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលខេត្ត
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- សមិទ្ធផល បញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ១៥.-**

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាខេត្តត្រូវធ្វើការសម្រេចរៀងរាល់កិច្ចប្រជុំដូចមានចែងក្នុងមាត្រា១៤នៃអនុក្រឹត្យនេះ ក្រុមប្រឹក្សាខេត្តអាចធ្វើការសម្រេចក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន :

- ការកោះអញ្ជើញអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬគណៈអភិបាលខេត្ត ឬបុគ្គលដែលពាក់ព័ន្ធ មកសាកសួរអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ឬហេតុការណ៍ណាមួយដែលកើតមានក្នុងខេត្ត ឬការដោះស្រាយបញ្ហាបន្ទាន់និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀតដែលពាក់ព័ន្ធដល់រដ្ឋបាលខេត្ត
- ការសម្រេចឱ្យមានការសិក្សាស្រាវជ្រាវឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាខេត្តយល់ថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំដល់គណៈអភិបាលខេត្តអំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ការពិនិត្យ ស្រាវជ្រាវ និងការធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃ ក្នុងករណីមានការរំលោភអំណាចដូចមានចែងក្នុងមាត្រា៤៧ មាត្រា៤៨ និងមាត្រា៤៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដោយក្រុមប្រឹក្សាខេត្ត ឬសមាជិកក្រុមប្រឹក្សាខេត្ត ឬគណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត តាមគោលការណ៍ដូចមានចែងក្នុងផ្នែកទី៥ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការពិនិត្យនិងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋានស្របទៅតាមច្បាប់និងនីតិវិធីជាធរមាន
- ការពិនិត្យនិងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរឬការតវ៉ានានាពីសំណាក់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ពិនិត្យនិងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលខេត្ត
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្តយល់ឃើញថាចាំបាច់។

**មាត្រា ១៦.-**

ក្រុមប្រឹក្សាខេត្ត ត្រូវប្រើប្រាស់អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិ ដោយផ្អែកតាមគោលការណ៍ បែបបទ និង នីតិវិធីដែលកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

ក្នុងករណីកិច្ចការណាមួយដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះ ច្បាប់ ឬ លិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទនិងនីតិវិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្តធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទនិងនីតិវិធីសមស្រប ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យនិងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនេះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់នូវបែបបទ នីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនេះ។

ក្នុងករណីកិច្ចការណាមួយដែលច្បាប់និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទ និងនីតិវិធីនោះចែងមិនច្បាស់លាស់ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាខេត្ត មិនអាចអនុវត្តបាន ក្រុមប្រឹក្សាខេត្តត្រូវចាត់ឱ្យគណៈអភិបាលខេត្តធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្អែកតាមយន្តការនៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យនិងដោះស្រាយករណីនេះ។

**មាត្រា ១៧.-**

អំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាខេត្តបានសម្រេចរួចហើយ គណៈអភិបាលខេត្តត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

គណៈអភិបាលខេត្ត ត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញឬវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត ដូចមានចែងក្នុងមាត្រា១៤ និងមាត្រា១៥នៃអនុក្រឹត្យនេះ។

ក្រុមប្រឹក្សាខេត្ត ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលខេត្ត ដើម្បីធានាថាគណៈអភិបាលខេត្តអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត។

គ.ជ.អ.ប. ត្រូវដាក់ចេញនូវគោលការណ៍ណែនាំ គាំទ្រដល់ក្រុមប្រឹក្សាខេត្តក្នុងការរៀបចំនូវប្រព័ន្ធតាមដាន ត្រួតពិនិត្យនិងវាយតម្លៃលើការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត។

## ផ្នែកទី២
## អំពីគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត

**មាត្រា ១៨.-**

ក្រុមប្រឹក្សាខេត្ត ត្រូវមានគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលរួមមាន :

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ
- គណៈកម្មាធិការលទ្ធកម្ម ។

កិច្ចដំណើរការនៃគណៈកម្មាធិការទាំងបីខាងលើ ត្រូវផ្អែកតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទាំងនេះ ។

**មាត្រា ១៩.-**

ក្រៅពីគណៈកម្មាធិការទាំងបីខាងលើនេះ ក្រុមប្រឹក្សាខេត្តអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់ ។

គណៈកម្មាធិការខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបីដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឡើយ ។

ក្រុមប្រឹក្សាខេត្តអាចបង្កើតអនុគណៈកម្មាធិការឬក្រុមការងារផ្សេងៗទៀត តាមការស្នើសុំរបស់គណៈកម្មាធិការនានាឬគណៈអភិបាលខេត្ត ។

អនុគណៈកម្មាធិការឬក្រុមការងារខាងលើនេះ ត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការឬគណៈអភិបាលខេត្ត ។

**មាត្រា ២០.-**

ក្រុមប្រឹក្សាខេត្ត អាចតែងតាំងសមាជិកក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត អភិបាលរងខេត្ត បុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត តំណាងក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង ។

ក្រុមប្រឹក្សាខេត្ត ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ការតែងតាំងប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង ។

គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងតំណែងប្រធាន ឬ អនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារផង ។

ក្រុមប្រឹក្សាខេត្ត អាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង តាមការចាំបាច់ ឬតាមសំណើរបស់គណៈកម្មាធិការ ឬគណៈអភិបាលខេត្ត ។

**មាត្រា ២១.-**

គណៈអភិបាលខេត្ត អាចស្នើសុំក្រុមប្រឹក្សាខេត្តដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង រួមទាំងគណៈកម្មាធិការទាំងបី(០៣)ដែលតម្រូវឱ្យបង្កើតឡើងដោយ

ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជួយសិក្សាផ្ដល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត។

**មាត្រា ២២.-**

ក្រុមប្រឹក្សាខេត្ត ត្រូវទទួលខុសត្រូវរាល់ការសម្រេចនិងសកម្មភាពរបស់គណៈកម្មាធិការនានា និងទទួលខុសត្រូវចំពោះផលវិបាកនានាដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ។

**មាត្រា ២៣.-**

ក្រុមប្រឹក្សាខេត្ត ត្រូវណែនាំឱ្យគណៈអភិបាលខេត្តផ្ដល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់ និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការទាំងបី(០៣) ដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង។

**មាត្រា ២៤.-**

គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្ដីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។

សេចក្ដីរាយការណ៍ខាងលើនេះ ត្រូវចម្លងជូនគណៈអភិបាលខេត្ត ដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រុមប្រឹក្សាខេត្ត។

ក្រុមប្រឹក្សាខេត្ត អាចតម្រូវឱ្យគណៈកម្មាធិការណាមួយរាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេសនិងបន្ទាន់ណាមួយក្នុងកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់។

## ផ្នែកទី៣

## គណៈអភិបាលខេត្ត

**មាត្រា ២៥.-**

ខេត្តនីមួយៗ ត្រូវមានគណៈអភិបាលខេត្តមួយដែលរួមមាន អភិបាលខេត្ត អភិបាលរងខេត្ត ដែលត្រូវបានតែងតាំងឡើងស្របតាមល័ក្ខខ័ណ្ឌនៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា ២៦.-**

អភិបាលខេត្ត អភិបាលរងខេត្ត មិនមែនជាសមាជិកក្រុមប្រឹក្សាខេត្តឡើយ។

**មាត្រា ២៧.-**

គណៈអភិបាលខេត្ត ត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន អំពីការអនុវត្តសេចក្ដីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

**មាត្រា ២៨.-**

គណៈអភិបាលខេត្ត មានភារកិច្ចផ្តល់យោបល់ រាយការណ៍ជូនក្រុមប្រឹក្សាខេត្ត និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាខេត្ត ទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។

**មាត្រា ២៩.-**

គណៈអភិបាលខេត្ត ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្តអំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិនិងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាខេត្ត ដើម្បីក្រុមប្រឹក្សាខេត្តធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញឬវិសាមញ្ញ ទាក់ទងនឹង :

- ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាខេត្ត និងរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
- ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ
- ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- គម្រោងថវិកាប្រចាំឆ្នាំ
- ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យនានា
- ការរៀបចំតួនាទី ភារកិច្ច និងល័ក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរសក្តិ និងការបញ្ឈប់បុគ្គលិក
- ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងកម្រៃផ្សេងៗនៃបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
- ការរៀបចំរបាយការណ៍ប្រចាំឆ្នាំដាក់ជូនក្រុមប្រឹក្សាខេត្ត ពិនិត្យ និងអនុម័តមិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ដែលពាក់ព័ន្ធនឹង :
  + ដីកានិងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាខេត្ត និងសកម្មភាព លទ្ធផលនៃការអនុវត្ត
  + របាយការណ៍ហិរញ្ញវត្ថុ
  + ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលខេត្តនិងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត
  + វិធានការចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាខេត្ត

**មាត្រា ៣២.-**

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ដែលបានសម្រេច និង/ឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាខេត្ត ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។

គណៈអភិបាលខេត្ត ឬអភិបាលខេត្ត ឬអភិបាលរងខេត្ត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពខាងលើនេះ។

**មាត្រា ៣៣.-**

គណៈអភិបាលខេត្ត ត្រូវប្រជុំពិភាក្សាដើម្បីបែងចែកភារកិច្ចដល់អភិបាលខេត្ត និងអភិបាលរងខេត្ត ហើយសុំការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវចេញសេចក្តីណែនាំអំពីការបែងចែកភារកិច្ចដល់អភិបាលខេត្ត អភិបាលរងខេត្ត និងរបៀបរបបអនុវត្តភារកិច្ចដែលបានបែងចែកនោះ។

**មាត្រា ៣៤.-**

អភិបាលខេត្ត ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សារបស់ខ្លួន លើកលែងតែលិខិតបទដ្ឋានដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាខេត្តចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សារបស់ខ្លួនដូចមានចែងក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ។

អភិបាលខេត្ត អាចប្រគល់សិទ្ធិដល់អភិបាលរងខេត្តក្នុងការចុះហត្ថលេខាលើឯកសារ លិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងខេត្តនីមួយៗ។

អភិបាលខេត្ត ត្រូវទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងខេត្ត។

អភិបាលខេត្ត មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងខេត្តណាមួយដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់ និងមិនស្របតាមបែបបទ នីតិវិធី។ ការប្រគល់និងការដកហូតសិទ្ធិក្នុងការចុះហត្ថលេខានេះ អភិបាលខេត្តត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីបែបបទ នីតិវិធីនៃការប្រគល់សិទ្ធិចុះហត្ថលេខានេះ។

**មាត្រា ៣៥.-**

ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងខេត្ត អភិបាលខេត្តមានភារកិច្ច :

- ណែនាំដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ឱ្យអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ស្របតាមច្បាប់ គោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងមន្ទីរ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ

- សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅខេត្ត ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលជាមួយមន្ទីរ អង្គភាព និងទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីរួមគ្នាអនុវត្តកិច្ចការនោះដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត អភិបាលខេត្តត្រូវធ្វើការសម្របសម្រួលតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការធ្វើសមាហរណកម្មផែនការនិងថវិការបស់ខ្លួនទៅក្នុងផែនការនិងថវិការបស់ក្រុមប្រឹក្សាខេត្ត។
- ពិនិត្យ វាយតម្លៃ ផ្តល់មូលវិចារណ៍ និងដាក់ពិន្ទុដល់ប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានា តាមគោលការណ៍កំណត់
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាខេត្តជាមុន ក្នុងការផ្តល់យោបល់ដល់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នលើបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានាដែលប្រចាំនៅខេត្ត។ ក្នុងករណីមិនគាំទ្រចំពោះបេក្ខភាពដែលស្នើតែងតាំងជាប្រធានមន្ទីរ អង្គភាពណាមួយ អភិបាលខេត្តត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់អំពីហេតុផលដែលមិនគាំទ្រនោះជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដើម្បីពិនិត្យពិចារណា។ ក្នុងករណីរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីឯកភាពតាមរបាយការណ៍របស់អភិបាលខេត្ត រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវផ្លាស់ប្តូរបេក្ខភាពដែលបានស្នើឡើងឱ្យបានសមស្រប។ ក្នុងករណីរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីស្រាវជ្រាវឃើញថា ហេតុផលដែលបានបញ្ជាក់ក្នុងរបាយការណ៍របស់អភិបាលខេត្តពុំមានមូលដ្ឋានច្បាស់លាស់ រដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមីត្រូវបញ្ជាក់ជូនអភិបាលខេត្ត ដើម្បីទទួលយកបេក្ខភាពដែលបានស្នើតែងតាំងនោះ។ ក្នុងករណីមិនមានការឯកភាពរវាងអភិបាលខេត្ត ជាមួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីទៅលើបេក្ខភាពដែលស្នើតែងតាំងនោះ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវធ្វើសេចក្តីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ សម្រេច។ អភិបាលខេត្តត្រូវរាយការណ៍ករណីនេះជូនក្រុមប្រឹក្សារបស់ខ្លួននិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- ក្នុងករណីពិនិត្យឃើញភាពមិនប្រក្រតីក្នុងមន្ទីរ អង្គភាព និងទីភ្នាក់ងារណាមួយ ឬការប្រព្រឹត្តខុសឆ្គងរបស់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវទីភ្នាក់ងារណាមួយ អភិបាលខេត្តត្រូវធ្វើការណែនាំជាបន្ទាន់ដល់ប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះ ឱ្យធ្វើការកែលម្អឡើងវិញជាបន្ទាន់។ ក្នុងករណីប្រធានមន្ទីរ អង្គភាព និងអ្នកទទួលខុសត្រូវនោះមិនបានកែប្រែ ឬក្នុងករណីភាពមិនប្រក្រតីឬការប្រព្រឹត្តខុសឆ្គងខាងលើមានលក្ខណៈធ្ងន់ធ្ងរ អភិបាលខេត្តត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីនៃមន្ទីរ អង្គភាព និងទីភ្នាក់ងារទាំងនោះ។ រដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីត្រូវធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ដើម្បីដោះស្រាយទៅតាមច្បាប់។

**មាត្រា ៣៩.-**

អភិបាលខេត្ត ដោយមាននាយករដ្ឋបាលសាលាខេត្តជាជំនួយការ ត្រូវធ្វើសេចក្តីរាយការណ៍អំពីសកម្មភាព និងលទ្ធផលនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួង ស្ថាប័ននានា ព្រមទាំងស្ថានភាពនៃការងារទាំងនោះ ក្នុងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។

ក្នុងករណីមានបញ្ហាណាមួយដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលខេត្តក្នុងនាមជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារ តវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាខេត្តអាចតម្រូវឱ្យអភិបាលខេត្តធ្វើសេចក្តីរាយការណ៍ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន។

ក្រុមប្រឹក្សាខេត្ត អាចផ្តល់អនុសាសន៍ និងការណែនាំដល់អភិបាលខេត្តអំពីការអនុវត្តតួនាទីខាងលើនេះ ដើម្បីឆ្លើយតបតម្រូវការជាអាទិភាពនិងបញ្ហាប្រឈមនានារបស់មូលដ្ឋាន។

អភិបាលខេត្ត ត្រូវទទួលយកអនុសាសន៍និងការណែនាំពីក្រុមប្រឹក្សារបស់ខ្លួន ដើម្បីធ្វើការណែនាំ សម្របសម្រួល និងតម្រង់ទិសដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅខេត្ត ក្នុងការឆ្លើយតបតម្រូវការទាំងនោះ ហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនវិញ។

**មាត្រា ៤០.-**

ក្នុងករណីអភិបាលខេត្តអវត្តមាន អភិបាលខេត្តត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងខេត្តមួយរូបឱ្យទទួលជាអភិបាលខេត្តស្តីទី។

ប្រសិនបើអភិបាលខេត្តអវត្តមានដោយពុំបានផ្ទេរសិទ្ធិ អភិបាលរងខេត្តដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃអនុក្រឹត្យតែងតាំងអភិបាលរងនៃគណៈអភិបាលខេត្ត ត្រូវធ្វើជាអភិបាលខេត្តស្តីទី។

ក្នុងករណីអភិបាលខេត្តស្តីទីអវត្តមាន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចេញប្រកាស ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងខេត្តមួយរូបឱ្យទទួលជាអភិបាលខេត្តស្តីទី។

អភិបាលខេត្តស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលខេត្ត នៅពេលដែលអភិបាលខេត្តមានវត្តមានវិញ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្ទេរសិទ្ធិនេះ។

**មាត្រា ៤១.-**

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវធ្វើសេចក្តីណែនាំស្តីពីការសុំច្បាប់ឈប់សម្រាករបស់អភិបាលខេត្ត អភិបាលរងខេត្ត និងបុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត។

## ផ្នែកទី៤

## នាយករដ្ឋបាលសាលាខេត្ត

**មាត្រា ៤២.-**

ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្ត ត្រូវមាននាយករដ្ឋបាលមួយ(០១)រូប ហៅថានាយករដ្ឋបាលសាលាខេត្ត

ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើពីអភិបាលខេត្ត យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាខេត្ត។

នាយករដ្ឋបាលសាលាខេត្ត ត្រូវមាននាយករងរដ្ឋបាលពីរ(០២)រូបជាជំនួយការ ដែលតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្អែកតាមសំណើពីអភិបាលខេត្ត យោងតាមការសម្រេចពីក្រុមប្រឹក្សាខេត្ត។

នាយករដ្ឋបាលសាលាខេត្ត ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរស័ក្តិចាប់ពីអនុមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ។

នាយករងរដ្ឋបាលសាលាខេត្ត ត្រូវបានតែងតាំងឡើងពីក្នុងចំណោមមន្ត្រីដែលស្ថិតក្នុងឋានន្តរស័ក្តិចាប់ពីនាយក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ។

**មាត្រា ៤៣.-**

លក្ខណសម្បត្តិនិងនីតិវិធីសម្រាប់ការតែងតាំងនាយករដ្ឋបាលសាលាខេត្ត និងនាយករងរដ្ឋបាលសាលាខេត្ត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញប្រកាសឬសេចក្តីណែនាំអំពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់នាយករដ្ឋបាលសាលាខេត្ត និងនាយករងរដ្ឋបាលសាលាខេត្ត។

**មាត្រា ៤៤.-**

នាយករដ្ឋបាលសាលាខេត្ត មានតួនាទីជាជំនួយការដល់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងអភិបាលខេត្តក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខេត្ត។

ក្នុងតួនាទីនេះ នាយករដ្ឋបាលសាលាខេត្តត្រូវធ្វើរបាយការណ៍ និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាលខេត្ត អភិបាលខេត្ត និងក្រុមប្រឹក្សារបស់ខ្លួន។

**មាត្រា ៤៥.-**

ក្នុងការអនុវត្តតួនាទីដូចមានចែងក្នុងមាត្រា៤៤នៃអនុក្រឹត្យនេះ នាយករដ្ឋបាលសាលាខេត្តមានភារកិច្ច ៖

- រៀបចំនិងដាក់ជូនគណៈអភិបាលខេត្ត ពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាខេត្ត ផ្អែកតាមក្របខ័ណ្ឌសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត ហើយត្រូវធានាថាកិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល
- រៀបចំនិងដាក់ជូនគណៈអភិបាលខេត្ត នូវវិធាននិងគោលការណ៍ក្នុងការអនុវត្តដីកានិងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាខេត្ត
- ធ្វើជាសេនាធិការជូនអភិបាលខេត្តនិងប្រធានក្រុមប្រឹក្សាខេត្ត ក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារនិងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាខេត្ត ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈ ឯកសារ និងខ្លឹមសារទាំងអស់ដែលនាយករដ្ឋបាលសាលាខេត្ត បានរៀបចំសម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត ត្រូវតែដាក់ជូនគណៈអភិបាលខេត្ត ដើម្បីពិនិត្យ

**មាត្រា ៥៤.-**

រដ្ឋបាលខេត្ត ត្រូវរៀបចំឱ្យមានក្ដារព័ត៌មានសាធារណៈនៅមុខសាលាខេត្ត ដែលសាធារណជនអាចពិនិត្យមើលបានដោយងាយស្រួល ។

ក្ដារព័ត៌មានសាធារណៈនេះ ត្រូវបានសរសេរឬបានបិទផ្សាយសេចក្ដីជូនដំណឹងជាផ្លូវការដល់សាធារណជន ។

ការសរសេរនិងការបិទផ្សាយខាងលើនេះ ត្រូវរក្សាទុកឱ្យបានយ៉ាងតិចដប់(១០)ថ្ងៃ ។

ក្រៅពីក្ដារព័ត៌មានសាធារណៈនៅមុខសាលាខេត្ត ក្រុមប្រឹក្សាខេត្តត្រូវរៀបចំឱ្យមានក្ដារព័ត៌មានសាធារណៈនៅទីសាធារណៈសមស្រប ដើម្បីបិទផ្សាយព័ត៌មានជូនសាធារណជន ។

ក្រៅពីការរៀបចំឱ្យមានក្ដារព័ត៌មានសាធារណៈ ក្រុមប្រឹក្សាខេត្តត្រូវស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀត ដើម្បីជូនដំណឹងអំពីកិច្ចការនានានៃរដ្ឋបាលរបស់ខ្លួនដល់ប្រជាពលរដ្ឋ ។

**មាត្រា ៥៥.-**

សាលាខេត្ត ត្រូវមានទីចាត់ការចំណុះចាំបាច់ដូចខាងក្រោម :

- ទីចាត់ការរដ្ឋបាល
- ទីចាត់ការផែនការនិងវិនិយោគ
- ទីចាត់ការហិរញ្ញវត្ថុ
- ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
- ទីចាត់ការអន្តរវិស័យ ។

**មាត្រា ៥៦.-**

ទីចាត់ការនីមួយៗ ត្រូវស្ថិតក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់នាយកទីចាត់ការ ។

នាយកទីចាត់ការនីមួយៗ ត្រូវទទួលខុសត្រូវនិងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាខេត្ត ។

**មាត្រា ៥៧.-**

ទីចាត់ការនីមួយៗនៃសាលាខេត្តដូចមានចែងក្នុងមាត្រា៥៥នៃអនុក្រឹត្យនេះ ត្រូវមាននាយកទីចាត់ការមួយ(០១)រូប និងនាយករងទីចាត់ការយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ ។

ទីចាត់ការនីមួយៗនៃសាលាខេត្ត ត្រូវមានការិយាល័យចំណុះមួយចំនួន ។

ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធានការិយាល័យមួយ(០១)រូប និងមានអនុប្រធានការិយាល័យយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ ។

ល័ក្ខខ័ណ្ឌនៃការតែងតាំងនាយកទីចាត់ការ នាយករងទីចាត់ការ ប្រធានការិយាល័យ អនុប្រធានការិយាល័យ និងមន្ត្រី បុគ្គលិកនៃទីចាត់ការនីមួយៗ ត្រូវផ្អែកតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ។

– ការអនុវត្តមុខងារ ភារកិច្ចថ្មីដែលបានផ្ទេរមកឱ្យរដ្ឋបាលខេត្ត លើកលែងតែមុខងារ ភារកិច្ចដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ទីចាត់ការនានានៃសាលាខេត្ត ដែលបានកំណត់ក្នុងអនុក្រឹត្យនេះ។

ក្រៅពីភារកិច្ចដូចមានចែងខាងលើនេះ ទីចាត់ការនីមួយៗអាចបំពេញកិច្ចការផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពីគណៈអភិបាលខេត្ត។

ទីចាត់ការនីមួយៗ ត្រូវបំពេញកិច្ចការដោយផ្អែកតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីនានាជាធរមាន។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចចេញសេចក្តីណែនាំអំពីភារកិច្ច និងរបៀបរបបការងាររបស់ទីចាត់ការនានានៃសាលាខេត្ត។

**មាត្រា ៥៩.-**

ផ្អែកតាមតួនាទី ភារកិច្ចរបស់ទីចាត់ការនានានៃសាលាខេត្ត ដូចមានចែងក្នុងមាត្រា៥៨នៃអនុក្រឹត្យនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រោយពីមានការឯកភាពពី គ.ជ.អ.ប. ត្រូវចេញប្រកាសបង្កើតការិយាល័យចំណុះទីចាត់ការនីមួយៗនៃសាលាខេត្ត និងកំណត់អំពីតួនាទី ភារកិច្ច របៀបរបបការងាររបស់ការិយាល័យនីមួយៗនោះ។

**មាត្រា ៦០.-**

ក្រៅពីទីចាត់ការនិងការិយាល័យដូចមានចែងក្នុងមាត្រា៥៥និងមាត្រា៥៩នៃអនុក្រឹត្យនេះ គណៈអភិបាលខេត្តអាចស្នើទៅក្រុមប្រឹក្សាខេត្ត ដើម្បីបង្កើតទីចាត់ការឬការិយាល័យបន្ថែមទៀតតាមការចាំបាច់។

ទីចាត់ការឬការិយាល័យដែលបង្កើតបន្ថែមខាងលើនេះ មិនត្រូវមានតួនាទី ភារកិច្ចត្រួតគ្នាជាមួយទីចាត់ការឬការិយាល័យដែលតម្រូវឱ្យបង្កើតឡើងដោយអនុក្រឹត្យនេះឡើយ។

ផ្អែកតាមការសម្រេចពីក្រុមប្រឹក្សារបស់ខ្លួន អភិបាលខេត្តត្រូវលើកសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ សម្រេច និង/ឬរៀបចំបែបបទក្នុងការបង្កើត ឬរំសាយ ឬកែសម្រួលទីចាត់ការ ឬការិយាល័យខាងលើនេះ។

## ជំពូកទី៣

## រដ្ឋបាលក្រុង

### ផ្នែកទី១

### ក្រុមប្រឹក្សាក្រុង

**មាត្រា ៦១.-**

ក្រុមប្រឹក្សាក្រុងនីមួយៗដែលបានបង្កើតឡើងដោយការបោះឆ្នោត ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈជាអ្នកការពារនិងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា ៦២.-**

ក្រុមប្រឹក្សាក្រុងនីមួយៗ ត្រូវប្រតិបត្តិតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ: ៥៥៦៣ ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តកណ្ដាល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងតាមសំណើរបស់រដ្ឋបាលខេត្តកណ្ដាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តកណ្តាល ជាផ្លូវការ ដូចមាននៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសនេះ។

**ប្រការ ២.-**

និមិត្តសញ្ញាខេត្តកណ្តាល មានរាង និងរូបភាពដែលត្រូវបានកំណត់ដូចខាងក្រោម៖

- មានរាងមូល
- រង្វង់មូលពណ៌មាសព័ទ្ធជុំវិញ៖ តំណាងឱ្យទឹកដីនៃខេត្តកណ្តាល ដែលហ៊ុំព័ទ្ធជុំវិញរាជធានីភ្នំពេញ
- មហាចេតិយចំនួនបី៖ តំណាងឱ្យជាតិ សាសនា ព្រះមហាក្សត្រ និងតំណាងឱ្យអំណាចទាំងបីរបស់រដ្ឋគឺ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ
- ព្រះសក្យមុនីចេតិយ៖ តំណាងឱ្យទីតម្កល់នូវព្រះសារីរិកធាតុជាទីគោរពសក្ការៈបូជារបស់ប្រជាជនកម្ពុជាចំពោះព្រះពុទ្ធសាសនា

ឧបសម្ព័ន្ធ នៃប្រកាសលេខ ៥៥២៣ ប្រ.ក
ចុះថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៩
ស្ដីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់នូវនិមិត្តសញ្ញាខេត្តកណ្ដាល



- កំពូលចេតិយ៖ តំណាងឱ្យអរិយធម៌ និងការខ្ពង់ខ្ពស់នៃប្រជាជាតិកម្ពុជាតាំងពីបុរាណសម័យ
- ក្បាច់ក្បូរចង្វា៖ តំណាងឱ្យភាពស៊ីវិល័យ ភាពរីកចម្រើន ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការប្រែក្លាយទឹកដីជនបទទៅជាទីក្រុង
- ពណ៌ត្រួតជាន់៖ តំណាងឱ្យថ្ងៃទាំង៧ នៃសប្តាហ៍ និងថ្ងៃជ័យជំនះ៧មករា
- ភ្នំព្រះរាជទ្រព្យ៖ តំណាងឱ្យមណ្ឌលដែនដី និងការគ្រប់គ្រងទឹកដីនៃខេត្តកណ្ដាល
- ដើមឈើពណ៌បៃតង៖ តំណាងឱ្យបរិស្ថានល្អសម្បូរទៅដោយធនធានធម្មជាតិ ព្រៃឈើគ្រប់ប្រភេទ និងភាពរីកចម្រើននៃវិស័យកសិកម្ម
- ពពក៖ តំណាងឱ្យភាពត្រជាក់ត្រជុំ សុខដុមរមនារបស់ប្រជាជនដែលរស់នៅក្រោមម្លប់នៃសុខសន្តិភាព នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ៣.-

និមិត្តសញ្ញាខេត្តកណ្ដាល ត្រូវបានប្រើប្រាស់ជាផ្លូវការ ដូចខាងក្រោម៖
- ដាក់នៅកន្លែងធ្វើការងារ
- ដាក់នៅលើក្បាលលិខិត ឯកសារ និងស្រោមសំបុត្រផ្លូវការ
- ប្រើប្រាស់ក្នុងពិធីនានារបស់រដ្ឋបាលខេត្តកណ្ដាល
- ប្រើប្រាស់ជាផ្លូវការក្នុងករណីផ្សេងៗទៀតដែលចាំបាច់។

ប្រការ ៤.-

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារនិងហិរញ្ញវត្ថុ អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាខេត្តកណ្ដាល និងគណៈអភិបាលខេត្តកណ្ដាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្ដេចក្រឡាហោម ស ខេង

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- [illegible]
- [illegible]
- [illegible]
- [illegible]
- [illegible]
- [illegible]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ០១ គនប

# គោលនយោបាយ
## «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀត មានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីយើងមានសន្តិភាព ស្ថិរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បញ្ហាសុខមាលភាពរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាចាំបាច់នានា នៅតែជាបញ្ហាអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឱ្យជនគ្រប់រូប និងសង្គមទាំងមូល មានសុវត្ថិភាពយ៉ាងល្អប្រសើរ ជីវភាពរុងរឿង និងសុខដុមរមនា។

ឆ្លងកាត់បទពិសោធន៍អស់រយៈពេល១០ឆ្នាំ ក្រសួងមហាផ្ទៃដោយមានការគាំទ្រ និងចូលរួមពីក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមការងាររបស់រាជរដ្ឋាភិបាលចុះមូលដ្ឋាន និងអ្នកពាក់ព័ន្ធ បានចាត់តាំងអនុវត្តប្រកបដោយជោគជ័យ និងបានធ្វើការកែលម្អផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំមានសុវត្ថិភាព» ជាបន្តបន្ទាប់ ឱ្យស្របតាមបរិបទនៃការអភិវឌ្ឍរីកចម្រើនរបស់សង្គមជាតិ។

ដើម្បីឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្ន និងកៀរគរឱ្យមានការចូលរួមគាំទ្រកាន់តែច្រើនថែមទៀត រាជរដ្ឋាភិបាលសម្រេចកែលម្អលក្ខណសម្បត្តិនៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ព្រមទាំងលើកកម្រិតគោលនយោបាយនេះជារបស់រាជរដ្ឋាភិបាល ដែលមានគោលបំណង និងសំណូមពរ ដូចខាងក្រោម៖

១. បន្តកសាង និងពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម លើកកម្ពស់អនាម័យ បរិស្ថាន សុខមាលភាពប្រជាពលរដ្ឋ និងកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីគ្រោះមហន្តរាយ និងជំងឺឆ្លងពគស្បាតនៅគ្រប់កាលៈទេសៈ ព្រមទាំងលើកទឹកចិត្តឱ្យមានការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ។

២. កសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដោយបំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ច ពីវិស័យសាធារណៈ វិស័យឯកជន អ្នកពាក់ព័ន្ធនានា និងប្រជាពលរដ្ឋនៅទូទាំងប្រទេស។

## I. លក្ខណសម្បត្តិរបស់ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព»

**១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត។**

**២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ។**

**៣. មានសណ្តាប់ធ្នាប់សាធារណៈល្អ ជាពិសេសគ្មានគ្រោះថ្នាក់ចរាចរណ៍។**

**៤. គ្មានអំពើអនាចារ គ្មានការជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ គ្មានអំពើហិង្សាក្នុងគ្រួសារ និងគ្មានក្មេងទំនើង។**

**៥. ដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព។**

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ។**

**៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយនិងរាល់ជំងឺឆ្លងពពួកសត្វការពារសហភាពប្រកបដោយប្រសិទ្ធភាព ។**

## II. វិធានការជាមូលដ្ឋាន

លក្ខណសម្បត្តិទាំង០៧យ៉ាង នៃគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ត្រូវបានចាត់តាំងអនុវត្តតាមវិធានការជាមូលដ្ឋានដូចខាងក្រោម៖

**១. ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត៖**

ចាត់វិធានការឱ្យបានហ្មត់ចត់ និងទាន់ពេលវេលាក្នុងការលើកកម្ពស់ការផ្តល់សេវារដ្ឋបាល សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននានានៅគ្រប់វិស័យ នៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋកាន់តែប្រសើរឡើង ទាំងផ្នែកបរិមាណ គុណភាព ប្រសិទ្ធភាព តម្លាភាព ពោលគឺជំរុញឱ្យការផ្តល់សេវា និងកិច្ចអន្តរាគមន៍នានាកាន់តែកៀកកិតនឹងប្រជាពលរដ្ឋ សំដៅបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋកាន់តែច្រើនឡើង។

**២. គ្មានបទល្មើស លួច ឆក់ ប្លន់ គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ៖**

- ត្រូវចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការបង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ និងយកចិត្តទុកដាក់លើការងារផ្សព្វផ្សាយអប់រំអំពីច្បាប់ពាក់ព័ន្ធ និងផលប៉ះពាល់នានាដែលបណ្តាលមកពីបទល្មើសគ្រប់ប្រភេទ ជាពិសេសអំពើ លួច ឆក់ ប្លន់ ចាប់ជំរិតយកប្រាក់ ការប្រើប្រាស់អាវុធខុសច្បាប់ និងល្បែង

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

លេខ: ០០២ សសរ.

ថ្ងៃព្រហស្បតិ៍ ៣កើត ខែអាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៨

# សេចក្ដីសម្រេច

## ស្ដីពី

## ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ខេត្តកណ្ដាល

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

-យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្តាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ។

**ប្រការ ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្តាល និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងតាខ្មៅ ត្រូវរៀបចំផែនការ សម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងតាខ្មៅ ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងតាខ្មៅ ត្រូវអនុវត្តតាមនីតិវិធី ដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកណ្តាល និងអភិបាលនៃគណៈអភិបាលក្រុងតាខ្មៅ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងតាខ្មៅ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

ជា សុផារ៉ា

**កន្លែងទទួល:-**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកណ្ដាល
លេខ:០១៧ ស.ណ.ន

# សេចក្ដីណែនាំ
## ស្ដីពីដំណើរការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល
## ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ (២០២៤-២០២៦)
## របស់ខេត្តកណ្ដាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យ ប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃព្រហស្បតិ៍ ៤រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សា ក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃព្រហស្បតិ៍ ៤រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-រាជក្រឹត្យលេខ នស/រកត/០៦១៩/៧៥១ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ ស្ដីពីការទទួលស្គាល់សមាសភាព ក្រុមប្រឹក្សាខេត្តកណ្ដាលអាណត្តិទី៣

-យោងប្រកាសអន្តរក្រសួងលេខ ០៧៨៨.ក ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការស្ដីពីការដាក់ឲ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

-យោងប្រកាសអន្តរក្រសួងលេខ០៧៧៨.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការស្ដីពីការដាក់ឲ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង

-យោងប្រកាសអន្តរក្រសួងលេខ០៧៦៨.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការស្ដីពីការដាក់ឲ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក

-យោងប្រកាសអន្តរក្រសួងលេខ០៧៣ ៨.កចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការស្ដីពីការដាក់ឲ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេស ស្ដីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលសង្កាត់

-យោងប្រកាសអន្តរក្រសួងលេខ០៧៤៨.ក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្ដីពីការដាក់ឲ្យប្រើប្រាស់សេចក្ដីណែនាំបច្ចេកទេសស្ដីពីការរៀបចំនិងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

-យោងប្រកាសអន្តរក្រសួងលេខ ០១៤៩៨ផ.ក ប្រ.ក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០២០ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការដាក់ឲ្យប្រើប្រាស់សេចក្តីណែនាំបំពេញបន្ថែមលើសេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

-សេចក្តីសម្រេចលេខ ០៤៩ ស.ស.រ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្តកណ្តាល

-យោងប្រកាសលេខ១៧៤១ប្រ.កចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាខេត្តកណ្តាល

-យោងតាមស្មារតីអង្គប្រជុំសាមញ្ញលើកទី៤៥.អាណត្តិទី៣ របស់ក្រុមប្រឹក្សាខេត្ត នាថ្ងៃ១០រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣

-យោងតាមការចាំបាច់របស់រដ្ឋបាលខេត្តកណ្តាល

**ក្រុមប្រឹក្សាខេត្តកណ្តាល**

ដាក់ចេញនូវសេចក្តីណែនាំស្តីពីដំណើរការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦) របស់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងខេត្តដូចតទៅ៖

**១.ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរបស់ខេត្ត**

ខេត្តកណ្តាលស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា ព័ទ្ធជុំវិញរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ខាងជើងជាប់នឹងខេត្តកំពង់ចាម-កំពង់ឆ្នាំង ខាងកើតជាប់នឹងខេត្តព្រៃវែង ខាងលិចជាប់នឹងខេត្តកំពង់ស្ពឺ-តាកែវ និងខាងត្បូងជាប់នឹងខេត្តតាកែវ និងប្រទេសវៀតណាម។ ខេត្តកណ្តាលចែកចេញជា១ក្រុង និង១០ស្រុកគ្របដណ្តប់ លើឃុំ សង្កាត់១២៧ មានផ្ទៃដីសរុប ៣,២១១.៤៦គ.ម² ប្រជាជនសរុប ១,៣៤៨,៨៥១ នាក់ ដង់ស៊ីតេ៤២០នាក់/គម² ហើយមានអំណោយផលធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តយ៉ាងល្អប្រសើរសម្រាប់ការវិនិយោគវិស័យ កសិកម្ម ឧស្សាហកម្ម នគរូបនីយកម្មសំណង់ ទេសចរណ៍ និងសេវាកម្ម។ ស្ថានភាព នៃកិច្ចអភិវឌ្ឍន៍ខេត្តបានឆ្លុះបញ្ចាំងតាមរយៈលទ្ធផលចម្បងៗខាងក្រោម៖

**១.១.សេដ្ឋកិច្ច**

-កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការកើនឡើងគួរឲ្យកត់សំគាល់។ សូចនាករនៃអត្រាភាពក្រីក្រតាមទិន្នន័យមូលដ្ឋានបានបង្ហាញថា៖ អត្រាភាពក្រីក្របានថយចុះមកនៅត្រឹម៣.៦៨% នាឆ្នាំ ២០២២ ។ ផលិត ផលក្នុងស្រុកសរុប (GDP) របស់ប្រជាជនម្នាក់ របស់ខេត្តបានកើនពីចំនួន ១.៨៦០ ដុល្លារនៅឆ្នាំ ២០១៨ ដល់ ១.៩៩៧ ដុល្លារ នៅឆ្នាំ២០១៩ និងកើនដល់២,០៣៨ដុល្លាក្នុងឆ្នាំ២០២០។

-ផលិតកម្មកសិកម្ម ការដាំដុះដំណាំស្រូវទទួលបានទិន្នផលកើនឡើង បរិមាណផលស្រូវសម្រាប់ផ្គត់ផ្គង់ស្បៀង និងមានលទ្ធភាពលក់លើទីផ្សារ។ ការដាំដុះដំណាំរួមផ្សំ បន្លែបង្ការ ដំណាំរយៈពេលវែង ដំណាំរយៈពេលខ្លី និងការចិញ្ចឹមសត្វលក្ខណៈគ្រួសារទទួលបានលទ្ធផលល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។

- ហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទទាំងផ្លូវទីប្រជុំជន និងផ្លូវជនបទ ធារាសាស្ត្រ អប់រំ សុខាភិបាល មានការអភិវឌ្ឍន៍គួរឲ្យកត់សំគាល់។

- សកម្មភាពសេដ្ឋកិច្ចគ្រប់ប្រភេទមានការរីកចម្រើន ពិសេសការវិនិយោគលើរោងចក្រ សហគ្រាស

សិប្បកម្ម អាជីវកម្ម គ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានលទ្ធភាពផ្តល់ការងារដល់កម្មករនិយោជិតជាច្រើន ទាំងក្នុងខេត្ត និងក្រៅខេត្ត។

**ទន្ទឹមនឹងការរីកចម្រើន វិស័យសេដ្ឋកិច្ចខេត្តក៏បានជួបប្រទះ បញ្ហាប្រឈមមួយចំនួនរួមមាន៖**

-អត្រាភាពក្រីក្ររបស់ប្រជាជននៅក្នុងខេត្តស្ថិតនៅក្នុងកម្រិត៣.៦៨%។

-ផលិតកម្មកសិកម្មថ្វីត្បិតតែមានការរីកចម្រើន ប៉ុន្តែកត្តាគុណភាពសម្រាប់ប្រកួតប្រជែងទីផ្សារនៅតែជាបញ្ហា។ ផលិតកម្មកសិកម្មមិនទាន់ទំនើបកម្មលើការប្រើប្រាស់ឧបករណ៍គ្រឿងយន្តកសិកម្ម បច្ចេកវិទ្យាផលិតកម្មដាំដុះ ការកែប្រែគុណភាពដី ជាពិសេសទីផ្សារផលិតផលមិនទាន់ទូលាយ ។

-ហេដ្ឋារចនាសម្ព័ន្ធសម្រាប់សកម្មភាពសេដ្ឋកិច្ច នៅមានបញ្ហាប្រឈមដោយសារហេដ្ឋារចនាសម្ព័ន្ធមួយចំនួនត្រូវបានខូចខាតដោយគ្រោះធម្មជាតិ និងការដឹកជញ្ជូនលើសទម្ងន់ ដែលត្រូវការជួសជុល និងថែទាំឲ្យបានទាន់ពេលវេលា។ គ្រោះថ្នាក់ចរាចរណ៍នៅតែមានអត្រាខ្ពស់ ទាមទារឲ្យមានការផ្សព្វផ្សាយច្បាប់ចរាចរណ៍ និងបង្កើនការគ្រប់គ្រងឲ្យមានប្រសិទ្ធភាព។

-ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រោចស្រពផ្ទៃដីដាំដុះមិនទាន់ឆ្លើយតបនឹងសេចក្តីត្រូវការពិសេសបង្កើនរដូវដាំដុះ ដែលចាំបាច់ទាមទារឲ្យមានការជួសជុល កសាងប្រព័ន្ធស្រោចស្រពបន្ថែមទៀត។

### ១.២ សង្គមកិច្ច

-សេវាសុខាភិបាលសាធារណៈត្រូវបានកែលម្អការប្រើសេវាសុខាភិបាលប្រកបដោយប្រសិទ្ធភាព សមធម៌ដល់ប្រជាពលរដ្ឋទូទៅ ពិសេសគ្រួសារក្រីក្រនិងគ្រួសារងាយរងគ្រោះតាមរយៈមូលនិធិសមធម៌និងបណ្ណសមធម៌។

គោលការណ៍អប់រំសម្រាប់យើងផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនទាំងអស់បានទទួលការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងគ្រប់កម្រិតសិក្សា។

សេវាសង្គមកិច្ចសម្រាប់ជួយជនរងគ្រោះនិងជនងាយរងគ្រោះគ្រប់ប្រភេទមានភាពប្រសើរឡើង។ អន្តរាគមន៍សង្គមកិច្ចជួយប្រជាជនក្រីក្រងាយរងគ្រោះ និងជនងាយរងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ ពិសេស អ្នករងផលប៉ះពាល់ពីជំងឺកូវីដ១៩ គ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា។ ដោះស្រាយបញ្ហាជនអនាថា ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជួយជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស។ អនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។ជំរុញកម្មវិធីអប់រំសីលធម៌សង្គមតម្លៃស្ត្រី និងគ្រួសារខ្មែរសម្រាប់ពង្រីកវប្បធម៌អហឹង្សាក្នុងគ្រួសារ។

-បានអភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ ការថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ ទាំងរូបិយ និងអរូបិយ អប់ រំដល់ស្រទាប់យុវជន និងកុមារឲ្យយល់ដឹងច្បាស់អំពីតម្លៃនៃវប្បធម៌ទំនៀមទំលាប់ប្រពៃណីខ្មែរ ព្រមទាំងលើកកម្ពស់សេរីភាពខាងជំនឿ និងសាសនា ពង្រឹងសុខដុមនីយកម្មរវាងសាសនាទូទាំងខេត្ត។

**ទន្ទឹមនឹងការរីកចម្រើន វិស័យសង្គមកិច្ចខេត្តក៏បានជួបប្រទះ បញ្ហាប្រឈមមួយចំនួនរួមមាន៖**

-ការអប់រំផ្សព្វផ្សាយអំពីសុខភាពតាមមូលដ្ឋាន និងសហគមន៍ពុំទាន់បានទូលំទូលាយ

-បុគ្គលិកសុខាភិបាលនៅមានកម្រិតខ្វះខាតផ្នែកសមត្ថភាព និងមានចំនួនមិនទាន់គ្រប់តាមស្តង់ដារ

-នៅមានអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សា

-ខ្វះសម្ភារសិក្សា អគារសិក្សា បណ្ណាល័យ ទឹកស្អាត និងបង្គន់អនាម័យនៅតាមសាលារៀន

-ការយល់ដឹងរបស់ឃុំ/សង្កាត់ពីគោលការណ៍បង្កើត និងគ្រប់គ្រងសមាគមមនុស្សចាស់នៅមានកម្រិត
-ការយល់ដឹងពីការងារយេនឌ័រនៅមានកម្រិត
-ការថែរក្សាការពារ និងអភិវឌ្ឍបេតិកភណ្ឌ វប្បធម៌រូបិយ និអរូបិយកំពុងប្រឈមមហានីភ័យ

**១-៣ ការប្រើប្រាស់ដីធ្លី ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ**

អនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលក្នុងវិស័យព្រៃឈើ ជលផល និងវិស័យគ្រប់គ្រងដីធ្លី តាម រយៈការផ្តល់កម្មសិទ្ធិស្របច្បាប់ជូនប្រជាពលរដ្ឋ ដោយអនុវត្តគោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី សម្រេចប្រកាសតំបន់វិនិច្ឆ័យតាមបណ្តាឃុំមួយចំនួន បំពេញសលាកបត្រព័ត៌មានក្បាលដី បញ្ចូលក្នុងសម្រង់បញ្ជីឈ្មោះម្ចាស់ដីបានវាស់វែងក្បាលដី គូសក្បាលដីបានបំពេញទម្រង់បែបបទក្បាលដី ចេញប័ណ្ណកម្មសិទ្ធិ និងការចុះ បញ្ជីដីលក្ខណៈជាប្រព័ន្ធចែកជូនប្រជាពលរដ្ឋជាម្ចាស់ដី។

ពង្រឹងការអនុវត្តន៍ច្បាប់ស្តីពីបរិស្ថាន ការគ្រប់គ្រងកាកសំណល់រឹង រាវ ការថែរក្សាតំបន់ការពារធម្មជាតិ ទប់ស្កាត់រាល់សកម្មភាពបំផ្លាញគុណភាពបរិស្ថាន អនុវត្តការគ្រប់គ្រងអភិរក្ស និងការអភិវឌ្ឍន៍ធនធានជលផល។

ជំរុញសកម្មភាពអនាម័យដើម្បីលើកកម្ពស់សុខុមាលភាពប្រជាជន ជាពិសេសកាត់បន្ថយកង្វះទឹកស្អាតប្រើប្រាស់ បង្កើនការប្រើប្រាស់បង្គន់អនាម័យ និងបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល។

**ទន្ទឹមនឹងការរីកចម្រើន វិស័យធនធានធម្មជាតិ បរិស្ថាន នៅជួបប្រទះបញ្ហាមួយចំនួនមានជាអាទិ៍ ៖**

-បញ្ហាទំនាស់ដីធ្លីតែងតែកើតមានឡើង ដោយសារការយល់ដឹងពីច្បាប់ភូមិបាលរបស់ប្រជាពលរដ្ឋនៅមានកម្រិត និងដោយសារភាពមិនច្បាស់លាស់នៃព្រំប្រទល់រដ្ឋបាល និងព្រំដីដោយសារពុំទាន់មានប័ណ្ណកម្មសិទ្ធិ និងពុំមានផែនទីកំណត់ព្រំប្រទល់រដ្ឋបាលច្បាស់លាស់។

-បទល្មើសនេសាទនៅកើតមានដូចជាប្រើឧបករណ៍ឆក់ត្រី ស្បៃមុងក្រឡាល្អិត នេសាទខុសច្បាប់ ការ ដុតព្រៃដែលជាហេតុធ្វើឲ្យបាត់បង់ពូជសត្វជាពិសេសការធ្វើដំណាំកសិកម្មដោយប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិត ការបង្ហូរកាក់សំណល់ពីរោងចក្រ សហគ្រាស សិប្បកម្មចូលក្នុងបឹង ទន្លេ អូរ ព្រែកនានាដែលជាប្រភពនៃការបំផ្លាញធនធានធម្មជាតិ។

- ការបញ្ចេញឧស្ម័នពុលតាមរោងចក្រ សិប្បកម្ម អាជីវកម្ម ចំហេះយានយន្ត ការគ្រប់គ្រងកាកសំណល់រឹង រាវ ការយល់ដឹងជាសាធារណៈអំពីអនាម័យ បរិស្ថាននៅមានកម្រិត។

**១.៤.រដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

-មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានបានចូលរួមថែរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅមូលដ្ឋានបានល្អ តាមរយៈការអនុវត្តន៍គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ការអនុវត្តន៍ច្បាប់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។

-បានអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅមូលដ្ឋានទៅតាមគោលការណ៍ដែលបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

-សមត្ថភាពស្ថាប័ន និងមន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធរដ្ឋបាល ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក៏ត្រូវបានលើកកម្ពស់ និងពង្រឹងពង្រីកថែមមួយកម្រិតទៀតតាមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលានានា។

-ដំណើរការនៅការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត ក្រុង ស្រុក បានរួមចំណែកលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ដោយផ្តោតលើគុណភាពសេវា អាចកាត់បន្ថយបានពេលវេលា និងការបង់កម្រៃមិនផ្លូវការដែលនាំឲ្យមានការថ្កោលថ្កាក់ពីប្រជាពលរដ្ឋ។

ទន្ទឹមនឹងការរីកចម្រើន វិស័យរដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ មានបញ្ហាមួយចំនួនរួមមាន៖

-ការយល់ដឹងអំពីច្បាប់ និងការគោរពច្បាប់នៅមានកម្រិត ក្នុងចំណោមប្រជាពលរដ្ឋទូទៅធ្វើឲ្យការអនុវត្តច្បាប់មិនទាន់បានពេញលេញ។

-ការផ្លាស់ប្តូរផ្នត់គំនិត និងឥរិយាបថក្នុងការបំពេញការងាររបស់មន្ត្រីខ្លះនៅពុំទាន់ជាអ្នកបម្រើសេវាសាធារណៈល្អប្រសើរនៅឡើយ។ អគាររដ្ឋបាលមន្ទីរ ក្រុង ស្រុក ឃុំ សង្កាត់សម្ភារៈបរិក្ខា និងមធ្យោបាយសម្រាប់បម្រើការងារនៅមិនទាន់ឆ្លើយតបនឹងតម្រូវការការងារជាក់ស្តែង។

## ២.គោលបំណង និងទិសដៅសំខាន់ៗនៅឆ្នាំខាងមុខ

ក្រុមប្រឹក្សាខេត្តកណ្តាលអាណត្តិទី៣ បានសម្រេចដាក់ចេញនូវ "គោលនយោបាយណែនាំ ផ្នែកគោលនយោបាយ" ដែលជាឧបករណ៍សម្រាប់តម្រង់ទិសរៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ(២០២០-២០២៤) និងសេចក្តីណែនាំសម្រាប់រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលដើម្បីជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច ឈានទៅសម្រេចនូវចក្ខុវិស័យក្នុងផែនការអភិវឌ្ឍន៍ខេត្តដូចខាងក្រោម៖

### ២.១ ផ្នែកសេដ្ឋកិច្ច

-ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចឲ្យសម្រេចបានកំណើនខ្ពស់ ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋយ៉ាងតិច១% ក្នុងមួយឆ្នាំតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

-លើកកម្ពស់ការអភិវឌ្ឍ ទាំងគុណភាព និងបរិមាណផលិតកម្មកសិកម្មរបស់ខេត្ត ដូចជាស្រូវ បន្លែ ផ្លែឈើ និងផលិតផលពីសត្វ ដើម្បីបំពេញតម្រូវការក្នុងខេត្ត និងការនាំចេញ។

-ពង្រឹងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រកែទម្រង់ការហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលពិសេស នៅថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់។

-លើកកម្ពស់ផលិតភាព និងសហគ្រិនភាពរបស់សហគ្រាសធុនធំ មធ្យម និងតូចព្រមទាំងពង្រីកលទ្ធភាព ទទួលបានបច្ចេកវិទ្យាជឿនលឿន ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់កម្មករ។

-ជំរុញការពង្រីកខ្សែបណ្តាញផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់ភូមិ ដោយផ្តល់សេវាអគ្គិសនីថ្លៃលក់ថាមពលអគ្គិសនីស្របតាមច្បាប់អគ្គិសនី។

-អភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធ័ផ្លូវថ្នល់គ្រប់ប្រភេទទាំងផ្លូវទីប្រជុំជន និងផ្លូវជនបទ និងពង្រីកការគ្រប់គ្រងការងារថែទាំផ្លូវថ្នល់។បន្តខិតខំធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកសាងផ្លូវជនបទជាជំហានៗ ពីផ្លូវក្រាលគ្រួសក្រហមមកជាផ្លូវបេតុង និងក្រាលកៅស៊ូ។

-លើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទឲ្យមានលក្ខណៈសម្បត្តិខាងបច្ចេកទេសគ្រប់គ្រាន់ដើម្បីចរាចរណ៍នៅលើផ្លូវសាធារណៈ។ ផ្សព្វផ្សាយអប់រំដល់ប្រជាជនទូទៅឲ្យបានយល់ដឹងច្បាស់អំពីច្បាប់ចរាចរណ៍ផ្លូវគោក។

-លើកកម្ពស់ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព តាមរយៈការពង្រឹងសមត្ថភាពសហគមន៍កសិករប្រើប្រាស់ទឹក ការស្តារ កសាង ថែទាំដើម្បីបង្កើនលទ្ធភាពស្រោចស្រព ជំរុញការងារបង្កបង្កើនផលពង្រីកវារីវប្បកម្ម និងការកាត់បន្ថយមហន្តរាយដែលបង្កឡើងដោយគ្រោះធម្មជាតិ និងមនុស្ស។

-អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ កាត់បន្ថយការធ្វើចំណាកស្រុកស្វែងរកការងារ ការបង្កើនកម្មវិធីបណ្តុះបណ្តាលអាជីវកម្មខ្នាតតូច មុខជំនាញគ្រួសារ ផ្តល់បច្ចេកទេសជំនាញ និងការយល់ដឹងអំពីការបង្កើនមុខរបរ។

-ផលិតផល និងទំនិញធ្វើចរាចរនៅគ្រប់ទីកន្លែង តាមគោលការណ៍ប្រកួតប្រជែងតាមតម្លៃទីផ្សារ ពិសេសយកចិត្តទុកដាក់លើថ្លៃទំនិញកសិផលរបស់កសិករ។ ពង្រឹងការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាព លើផលិតផលទំនិញ និងសេវាទប់ស្កាត់សកម្មភាពផលិត ការចែកចាយផលិតផលក្លែងក្លាយ និងផលិតផលគ្មានគុណភាព ឬខូចគុណភាព និងបន្តជំរុញចលនាភូមិមួយផលិតផលមួយ។

-គ្រប់គ្រងអភិវឌ្ឍន៍គោលដៅទេសចរណ៍សំខាន់ៗ ការកែលម្អសេវាទេសចរណ៍ និងបង្កើនផលិតផលទេសចរណ៍។ ចូលរួមការអនុវត្តទិសដៅនៃការអភិវឌ្ឍន៍បៃតង តាមរយៈការបន្តជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត ទីក្រុងបៃតង បំផុសចលនាសកម្មភាពប្រើប្រាស់បច្ចេកវិទ្យាបៃតងដូចជាបង្កើនអនាម័យ ការដាំដើមឈើជាដើម។

-កែលម្អហេដ្ឋារចនាសម្ព័ន្ធព្រំដែនសំដៅបង្កើនកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច សន្តិសុខសណ្តាប់ធ្នាប់។

**២.២. ផ្នែកសង្គមកិច្ច**

-ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

-លើកកម្ពស់ភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

-ជំរុញការសាងសង់ ជួសជុលសាលារៀន និងហេដ្ឋារចនាសម្ព័ន្ធអប់រំនៅកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ពិសេសសាងសង់អនុវិទ្យាល័យក្នុងឃុំ ដែលនៅមិនទាន់មានអនុវិទ្យាល័យ។

-លើកកម្ពស់គុណភាពអប់រំនៅគ្រប់កម្រិតសិក្សា រួមទាំងសនិទានកម្មបុគ្គលិកអប់រំ គ្រូបង្រៀន និងសិស្សពូកែទាំងនៅបឋមសិក្សា និងមធ្យមសិក្សា ។ ការផ្តល់សៀវភៅសិក្សាគោល សម្ភារៈបង្រៀន និងរៀន។

-អភិវឌ្ឍន៍ការងារអប់រំកាយ និងកីឡាសំដៅរួមចំណែកដល់ការលើកកម្ពស់សុខភាពប្រជាជនពង្រឹងសាមគ្គីភាព និងត្រៀមលក្ខណៈសម្បត្តិដើម្បីចូលរួមប្រកួតក្នុងព្រឹត្តិការណ៍កីឡាជាតិធំៗ។

-យកចិត្តទុកដាក់ផ្តល់សេវាសុខាភិបាលប្រកបដោយប្រសិទ្ធភាព សមធម៌ គុណភាពដល់ប្រជាជនទូទៅពិសេសគ្រួសារក្រីក្រ និងជនងាយរងគ្រោះ។

-ពង្រីកវិសាលភាពនៃសេវាសុខាភិបាលសាធារណៈឲ្យកាន់តែខិតជិតប្រជាជន ពង្រឹងសកម្មភាពចុះផ្តល់សេវាសុខភាពតាមភូមិ អប់រំផ្សព្វផ្សាយពីជំងឺឆ្លងផ្សេងៗពិសេសជំងឺកូវីដ១៩ ពង្រីកយន្តការលើកលែងការបង់ថ្លៃសម្រាប់គ្រួសារក្រីក្រតាមរយៈការពិនិត្យព្យាបាលជំងឺគ្រួសារក្រីក្រ និងការពង្រីកមូលនិធិសមធម៌បង់ថ្លៃជំនួស។

-អភិវឌ្ឍន៍ការងារ និងបណ្តុះបណ្តាលតម្រង់ទិសវិជ្ជាជីវៈធ្វើឲ្យប្រជាជនមានការងារធ្វើ និងសិទ្ធិទទួលបានផលប្រយោជន៍ស្របច្បាប់របស់និយោជក និងកម្មករនិយោជិតត្រូវបានការពារដោយស្របច្បាប់ការងារ។

-ពង្រីកទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករនិយោជិត និងនិយោជកព្រមទាំងពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាព ការងារនៅតាមរោងចក្រសហគ្រាសនានានៅក្នុងខេត្តឲ្យបានល្អប្រសើរ។

-លើកកម្ពស់ អភិរក្ស អភិវឌ្ឍន៍វប្បធម៌ជាតិ និងថែរក្សាការពារបេតិកភ័ណ្ឌវប្បធម៌ជាតិទាំងរូបី និងអរូបីឲ្យស្ថិតស្ថេរគង់វង្ស។បង្កើនផលិតផលវប្បធម៌ ផ្សព្វផ្សាយផលិតផល សិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ពង្រីកសកម្ម ភាពវប្បធម៌លើគ្រប់ជំនាញ។បង្កើនការអប់រំដល់ស្រទាប់យុវជន និងកុមារឲ្យបានយល់ដឹងច្បាស់អំពីតម្លៃនៃវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីខ្មែរ ដែលជាអត្តសញ្ញាណរបស់ជាតិ ។

-លើកកម្ពស់សេរីភាពខាងជំនឿ និងសាសនា ពង្រឹងសុខដុមនីយកម្មរវាងសាសនិកនៃគ្រប់សាសនា និងបន្តពង្រីកពុទ្ធិកសិក្សានៅគ្រប់កម្រិត។

-លើកកម្ពស់ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សំដៅរួមចំណែកធ្វើឲ្យសុខុមាលភាពរបស់ប្រជាជនមានស្ថានភាពកាន់តែប្រសើរ ដោយមានសេវាសង្គមកិច្ចសម្រាប់ជួយជនរងគ្រោះ ជនងាយរងគ្រោះគ្រប់ប្រភេទ ពិសេសសេវាថែទាំកុមារ អ្នករងផលប៉ះពាល់ពីជំងឺកូវីដ១៩ គ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងការពង្រីកសមាគមន៍មនុស្សចាស់។

-ពង្រឹងកម្មវិធីដោះស្រាយបញ្ហាជនអនាថា ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការជួយជនរងគ្រោះ និងជនងាយរងគ្រោះគ្រប់ប្រភេទ ការទប់ស្កាត់បទល្មើសគ្រឿងញៀន និងបង្កើតមណ្ឌលបន្សាបគ្រឿងញៀន។

-ពង្រឹងស្ថានភាពតួនាទីស្ត្រីឲ្យកាន់តែទទួលបាននូវកាលានុវត្តន៍ភាពការងារទូលំទូលាយ និងខ្លាំងក្លាថែមទៀតតាមរយៈការជំរុញការបណ្តុះបណ្តាលការប៉ប៉ិនជំនាញ ការជំរុញភាពអង់អាចក្លាហានបង្កើនឱកាសរៀនសូត្រ សម្រាប់ស្ត្រី ការបង្កើនសមាមាត្រការចូលរួមរបស់ស្ត្រីឲ្យបានកាន់តែច្រើនឡើង ក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្តនានា និងអភិបាលកិច្ចនៅក្នុងខេត្ត។

### ២.៣.ធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

១.ជំរុញការចុះបញ្ជីដីធ្លី ២.ផ្សព្វផ្សាយច្បាប់លិខិតបទដ្ឋានពាក់ព័ន្ធដីធ្លី ៣.រៀបចំកសាងប្លង់គោល ៤.គ្រប់គ្រងទប់ស្កាត់ការលោភលន់កាន់កាប់ដីរដ្ឋ និង៥.ពង្រឹងការអនុវត្តច្បាប់ឲ្យបានល្អប្រសើរជៀសវាងបាននូវទំនាស់ដីធ្លី។

-ពង្រឹងយន្តការគ្រប់គ្រងថែរក្សាការពារធនធានជលផលដើម្បីធានាដល់និរន្តរភាពដោយ ១)ធ្វើការផ្សព្វផ្សាយ បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ អំពីសារៈសំខាន់នៃធនធានធម្មជាតិចូលរួមដាំ និងថែរក្សាកូនឈើព្រៃលិចទឹក ២)ពង្រឹងកិច្ចសហការ ជាមួយអាជ្ញាធរមូលដ្ឋានទប់ស្កាត់ការចាប់ទន្ទ្រានយកផ្ទៃបឹង អូរព្រែក និងការនេសាទខុសច្បាប់ព្រមទាំងបង្កើតសហគមន៍ថែរក្សាអន្លង់ជ្រៅបង្កើតស្រះជម្រកត្រីការពារតំបន់អភិរក្សដើម្បីអភិរក្សជលផល ៣)ជំរុញការចិញ្ចឹមត្រីលក្ខណៈគ្រួសារ និងនៅតាមសហគមន៍ ៤)ពង្រឹងសហគមន៍នេសាទ។

-ពង្រឹងយន្តការ ថែទាំបរិស្ថាន និងធនធានធម្មជាតិដោយ ១)អប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋអំពីការបំពុលទឹក ការគ្រប់គ្រងកាកសំណល់រឹង រាវ និងការថែរក្សាការពារធនធានព្រៃឈើ និងព្រៃលិចទឹក ២)សហការជាមួយរកដ្ឋាករ ដែនដីរកទីលានរៀបចំរណ្តៅចាក់សំរាម និងពង្រឹងយន្តការគ្រប់គ្រងប្រមូលសំរាមនៅតាមទីផ្សារ និងទីប្រជុំជន និង៣)អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីរបៀបប្រើប្រាស់សារធាតុគីមីនានានៅក្នុងវិស័យកសិកម្មឱ្យបានត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស និងអំពីផលប៉ះពាល់របស់វា។

-ពង្រឹងយន្តការគ្រប់គ្រងគ្រោះមហន្តរាយ និងបម្រែបម្រួលអាកាសធាតុដោយ ១)បណ្តុះបណ្តាលគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់លំដាប់ថ្នាក់ បន្តការយកចិត្តទុកដាក់យន្តការប្រកាសអាសន្នពីស្ថានភាពទឹកជំនន់ និងផ្តល់ព័ត៌មានភាពរាំងស្ងួតឲ្យមានភាពប្រសើរឡើង និងទាន់ពេលវេលា ២)ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីគ្រោះថ្នាក់ និងការត្រៀមបង្ការពេលមានគ្រោះភ័យ ៣)គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ថ្នាក់ត្រូវត្រៀមមធ្យោបាយ សម្ភារៈ ទីទួលសុវត្ថិភាពសម្រាប់ជួយពេលមានគ្រោះអាសន្ននិងក្រោយពេលគ្រោះអាសន្ន ៤)អប់រំផ្សព្វផ្សាយបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋអំពីការប្រែប្រួលអាកាសធាតុ។

**២.៤.វដ្ឋបាលសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ**

-ពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឲ្យបានកាន់តែល្អប្រសើរដោយ ១)ពង្រឹងការផ្តល់សេវាចុះអត្រានុកូលដ្ឋាន ធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋខ្មែរ និងគ្រប់គ្រងសៀវភៅចុះអត្រានុកូលដ្ឋាន ២)បង្កើន សមត្ថភាពជំនាញរដ្ឋបាលដល់មន្ត្រី ៣)សាងសង់ពង្រីកអគាររដ្ឋបាល និងបំពាក់ឧបករណ៍ បរិក្ខា មធ្យោបាយ គ្រឿងសង្ហារឹម ៤)បង្កើនការយល់ដឹងពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទិន្នន័យ ព្រមទាំងបង្កើនសមត្ថភាពមន្ត្រី ពាក់ព័ន្ធអំពីការវិភាគទិន្នន័យស្ថានភាពខេត្ត ក្រុង ស្រុក ឃុំ សង្កាត់និងចូលរួមប្រមូលទិន្នន័យឲ្យមានភាពសុក្រិត្យ ៥)បង្កើនកិច្ចសហការជាមួយអង្គភាពពាក់ព័ន្ធផ្តល់ការបណ្តុះបណ្តាល និងគាំទ្រដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់។

-ពង្រឹងយន្តការអនុវត្តច្បាប់ដើម្បីរក្សាសុវត្ថិភាពជូនប្រជាពលរដ្ឋដោយ ១)ទប់ស្កាត់នូវការប្រព្រឹត្តិបទល្មើស នានា ២)អប់រំផ្សព្វផ្សាយការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស ការជួញដូរ ការប្រើប្រាស់ និងផលិតគ្រឿងញៀន ក្មេងទំនើង ៣)ផ្សព្វផ្សាយ និងពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក និងទឹកព្រមទាំងដំឡើងប៉ាណូ ស្លាកសញ្ញាចរាចរ ទាំងផ្លូវគោក និងផ្លូវទឹក ៤)ធ្វើការត្រួតពិនិត្យជាប្រចាំ ៥)រៀបចំ និងពង្រឹងក្រុមប្រជាការពារនៅតាមភូមិ ឃុំ សង្កាត់ ៦)កសាងសមត្ថភាពបន្ថែមដល់មន្ត្រីអនុវត្តច្បាប់។

**៣. តួនាទីរបស់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកិម្មវិធីវិនិយោគ**

ដើម្បីឲ្យទទួលបាននូវប្រសិទ្ធភាពក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦)របស់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់មានសង្គតិភាពជាមួយផែនការអភិវឌ្ឍន៍ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់រយៈពេល៥ឆ្នាំ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ត្រូវចាប់ផ្តើមដំណើរការរៀបចំកម្មវិធីវិនិយោគរបស់ខ្លួនចាប់ពី ខែមករា ឆ្នាំ២០២៣ ដែលមានការរៀបចំវេទិកាពិគ្រោះយោបល់សម្រាប់ និងសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់ក្រុង ស្រុក នៅអំឡុងខែវិច្ឆិកា ឆ្នាំ២០២៣ និងត្រូវរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ឲ្យបានចប់ជាស្ថាពរ និងដាក់ជូនក្រុមប្រឹក្សានៃរដ្ឋបាលនីមួយៗពិនិត្យអនុម័តដើម្បីអនុវត្ត។

ដូចនេះដើម្បីឲ្យការរៀបចំកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ប្រព្រឹត្តទៅបានទាន់ពេលវេលាតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ក្រុមប្រឹក្សាខេត្តកណ្តាល

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ជំហានទី២ | ការរៀបចំសេចក្ដីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | | | | | | | | |
| ២.១ | កិច្ចប្រជុំផ្សព្វផ្សាយសេចក្ដីណែនាំស្ដីពី ការរៀបចំកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ | | | | | | | | | | | | |
| ២.២ | ការពិនិត្យ និង ជាត់អាទិភាពគម្រោងកម្មវិធីវិនិយោគបីឆ្នាំរំកិលឡើងវិញ | | | | | | | | | | | | |
| ២.៣ | វេទិកាពិគ្រោះយោបល់ក្នុងការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | | | | | | | | |
| ២.៤ | ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅតាមបណ្ដាក្រុងស្រុក | | | | | | | | | | | | |
| ២.៥ | ការរៀបចំតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | | | | | | | | |
| ២.៦ | ចងក្រងសេចក្ដីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | | | | | | | | |
| ២.៧ | ការពិនិត្យផ្ដល់យោបល់ | | | | | | | | | | | | |
| ជំហានទី៣ | អនុម័តនិងការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | | | | | | | | |
| ៣.១ | កិច្ចប្រជុំពិនិត្យអនុមតិសេចក្ដីព្រាង កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | | | | | | | | |
| ៣.២ | ការបោះពុម្ពនិងការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | | | | | | | | |

ទទួលបានសេចក្ដីណែនាំនេះ សូមឯកឧត្ដមអភិបាល នៃគណៈអភិបាលខេត្ត លោកនាយករដ្ឋបាល លោក លោកស្រី ប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត សង្គមស៊ីវិល វិស័យឯកជន អ្នកពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលក្រុង/ស្រុក លោក លោកស្រីមេឃុំ ចៅសង្កាត់ ក្រុមការងារកសាងផែនការ ខេត្ត ក្រុង ស្រុក គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ ត្រូវរៀបចំចាត់ចែងសម្របសម្រួលអនុវត្តដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៤-២០២៦) ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងខេត្តកណ្ដាល ឲ្យទទួលបានជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ.ពុធ..៤.កើត ខែ.....ឆ្នាំ.....ព.ស២៥៦៦

កណ្ដាល ថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០២៣

ប្រធានក្រុមប្រឹក្សាខេត្តកណ្ដាល

ទេព អ៊ិនុណា

<u>កន្លែងទទួល៖</u>

-ក្រសួងមហាផ្ទៃ

-ក្រសួងផែនការ

*"ដើម្បីគោរពជូនជ្រាប"*

-អភិបាលនៃគណៈអភិបាលខេត្ត

-គ្រប់មន្ទីរ ស្ថាប័ន អង្គភាពពាក់ពន្ធ័

-គ្រប់រដ្ឋបាលក្រុង ស្រុក

-គ្រប់រដ្ឋបាលឃុំ សង្កាត់

*"ដើម្បីមុខការ និង សហការអនុវត្ត"*

-ឯកសារ កាលប្បវត្តិ